ការិយាល័យមេធាវីខ្មែរ

LAW OFFICE OF

Stewart H. Lim & Associates

ពិគ្រោះយោបល់ដោយមិនគិតកំរៃ

▸ច្បាប់គ្រោះថ្នាក់ចរាចរ, សំណងប្រាក់ចិញ្ចឹមកូន, ច្បាប់អន្តោប្រវេសន៍, បណ្តឹងលែងលះ, សេដ្ឋកិច្ចក្ស័យធន

▸បណ្តឹងមរតក, ការពារក្តី

Stewart H. Lim

Car Accident, Child Support, Immigration, Divorce, Bankruptcy, Living Trust, Defense you in Court

Main Office

100 Oceangate Blvd., Suite 1200, Long Beach, CA 90802

(562) 590-7181 FREE CONSULTATION


# ខ្មែរប៉ុស្តិ៍ Khmer Post


ឱសថស្ថាន ខ្មែរថ្ងៃនេះ

Today Pharmacy

សូមអញ្ជើញ !

Fast and Friendly Service

Today Pharmacy

FREE DELIVERY

•ទទួលយកទៅ Medicare & Medical និង Insurance ។

2200E. Anaheim St. #C Long Beach, CA 90804

Tel: (562) 438-2031 . Fax: (562) 438-2031

(2 Blocks East of Cherry Ave.)



KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE 10 March 01st- 15th 2008 ADVERTISING (562) 313-2129 WWW.THEKHMERPOST.COM


# ដំណើរមកកាន់ការវះកាត់បេះដូងកុមារី ដារិក

## ប្រវត្តិសាស្ត្រមួយមិនដែលកើតមានចំពោះអ្នកក្រ

▸ខ្ញុំមិនស្លាប់ទេ... អាមេរិកផ្តល់ក្តីសង្ឃឹម

Photo by: Vantha El



ការមកដល់ទឹកដីអាមេរិករបស់កុមារី ដារិក នៅព្រលានយន្តហោះ L.A.X

***ឡុង ប៊ិច : មាជ សុវណ្ណារ៉ា***

**នៅព្រលានយន្តហោះ L.A.X**

ក្នុងទឹកមុខដ៏ស្រស់ញញឹមជាអាការៈ មនុស្សមានជំងឺលេចមុខចេញពីព្រលានយន្តហោះអន្តរជាតិ Los Angeles រដ្ឋ California (L.A.X) កុមារី តេង ដារិក អាយុ ៩ឆ្នាំ ដែលកំពុងជួបប្រទះពីឆាកជីវិតនូវភាពទុក្ខសោកដង្ហោយហៅរកការជួយសង្គ្រោះ ព្រោះតែបេះដូងប្រហោងរបស់

( តទៅទំព័រទី៣៨ )

## លេខពិសេស

## ចិន-យួនដេញខ្មែរ ...ខ្មែរដេញខ្មោច !

***កម្ពុជា : គីមសារឿន***

ប្រជាជនខ្មែរស្ទើរគ្រប់គ្នា ( តទៅទំព័រទី ១២ )

## សុខ អាន ទំនងមិនអាចមកក្រុងខ្មែរឡុងប៊ិច

***ឡុងប៊ិច : មាជ សុវណ្ណារ៉ា***

រដ្ឋមន្ត្រីក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ដែលធ្វើការផ្ទាល់ជាមួយលោកឧបនាយករដ្ឋមន្ត្រី សុខ អាន បាននិយាយប្រាប់ខ្មែរប៉ុស្តិ៍តាមទូរស័ព្ទឱ្យដឹងថា ដំណើរទស្សនកិច្ចរបស់ សុខ អាន មកកាន់ក្រុងខ្មែរ Long Beach ដើម្បីចូលរួមជាគណៈអធិបតីក្នុងថ្ងៃបុណ្យព្យុហយាត្រាអបអរសារទរបុណ្យចូលឆ្នាំខ្មែរ ( តទៅទំព័រទី១១ )

## ជួបអ្នកនិពន្ធបទ "ស្រណោះដីខ្មែរ"



អាន ឈួ នៅក្នុងចំការរបស់គាត់នាខេត្តបាត់ដំបង

***ឡុងប៊ិច : មាជ សុវណ្ណារ៉ា***

បទស្រណោះដីខ្មែរ ( តទៅទំព័រទី១៥ )

## តុលាការច្រានចោលការប្តឹងមិនឱ្យមនុស្សចូលវត្ត IRAP

***ឡុងប៊ិច : មាជ សុវណ្ណារ៉ា***

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ( តទៅទំព័រទី១០ )


Law Offices of Boroth Chay

No Recovery . No Fees ! New Location

2501 Cherry Ave , Ste.245 , Signal Hill , CA 90755

Office: (562) 997- 8500 . Direct : (562) 453 - 5898

TOP AUTO INSURANCE AGENCY

Free Quote, Low Rates, LOW MONTHLY

AUTO-LIFE-HEALTH-HOME-COMMERCIAL

Tel: (562) 989-1800

Tiffany Prak

Agent/Broker Lic.0E44334

2760E. Spring St., Ste 140 . Long Beach, CA 90806

FARMER INSURANCE

Douglas Horn Agency

License #0B83665

Life Insurance, Home Insurance, Business Insurance, Auto Insurance, Health Insurance, One Stop Service, Bail Bond,

1360E Anaheim St., Ste 203 , Long Beach CA 90813

Tel: (562) 591- 3100 Fax : (562) 591- 3911

ក្រុមហ៊ុនធានារ៉ាប់រង State Farm

Peter Kong Insurance Agency

- Business Liability Insurance
- Auto Insurance
- Home Insurance
- Life Insurance
- Health Insurance
- Apartement Insurance
- Disability Insurance
- Family & Individual Coverage

(Notary Public)

Savannara + Sokha

2750E. Spring Street, Suite 201, Long Beach, CA 90806

Tel: (562) 426-9189 Fax: (562) 426-4669


EVA AIR
777-300ER
ក្រុមហ៊ុនអង្គរទេសចរណ៍
Angkor Travel
ការជ្រើសរើសតែមួយគត់សំរាប់ធ្វើដំណើរទៅកាន់ប្រទេសកម្ពុជា
ទទួលបំរើកិច្ចការធ្វើដំណើរក្នុងសហរដ្ឋ និងអន្តរជាតិ ។
តម្លៃសំបុត្រលក់ចុះថ្លៃជាពិសេសសំរាប់ការធ្វើដំណើរក្នុងស្រុកចេញពីចំណតយន្តហោះ LAX ទៅកាន់គ្រប់ទីក្រុងក្នុងសហរដ្ឋអាមេរិក ។
មានលក់កាតសំរាប់ទូរស័ព្ទជុំវិញពិភពលោក ( លក់ដុំ និងលក់រាយ) ។
ទទួលធ្វើ Re-Entry Permit លិខិតឆ្លងដែន ។
ទទួលធ្វើ Re-Entry Permit ប្រញាប់ជូនភ្លាមៗ!!!
ជួយរកតម្លៃសំបុត្រយន្តហោះថោកជាងគេទៅស្រុកខ្មែរតាមរយៈក្រុមហ៊ុន Eva Air , Cathay Pacific,Malaysia Air , Singapore Air.
បើលោកអ្នកចង់ដឹងតម្លៃពិសេស សូមអញ្ជើញទាក់ទងនាងខ្ញុំ
Tel: (562) 599-0877 , Fax: (562) 599 4758
1569 E. Anaheim St.,C Long Beach ,
CA 90813 (កាច់ជ្រុងផ្លូវ Anaheim & Walnut)
Cellphonatic
Wireless Super center
យើងខ្ញុំមានលក់កាតទូរស័ព្ទ ទិញដាក់បញ្ចូលទឹកលុយទៅក្នុងទូរស័ព្ទដៃ និងទូរស័ព្ទនៅផ្ទះបានភ្លាមៗ!!!
NO CONNECTION FEE !
NO EXPIRATION DATE !
metroPCS
No te limites.
FREE PHONE !!!
តម្លៃត្រឹមតែ $30 ក្នុងមួយខែ !
NOKIA 5300
NOKIA 5200
NOKIA N93
NOKIA N91
NOKIA 6070
NOKIA 6233
NOKIA 6288


TOYOTA
HOOMAN
TOYOTA
Of Long Beach
On the Road to 2 MILLION Sold!
CHUCK CHET
Cambodian Sale Manager
LINDA HING
► គ្មានក្រេឌីត, ខូចក្រេឌីត, ក្ស័យធន, អត់មានបញ្ហា
► យើងខ្ញុំជួយសំរួលកិច្ចការជូនលោក-អ្នក
► យើងខ្ញុំជាខ្មែរ មានបទពិសោធន៍ជាង 20 ឆ្នាំ
ជាមួយជំនាញលក់ឡាន និងមានទំនាក់ទំនងល្អ
ក្នុងសហគមន៍ខ្មែរ ។
► សូមមេត្តាទូរស័ព្ទផ្ទាល់មកលេខខ្ញុំ : (562) 325-9647
បើលោកអ្នកមានបំណងចង់ទិញឡានពីក្រុមហ៊ុន TOYOTA យើងខ្ញុំ ។
UP TO $4,000 Rebate
LAKEWOOD
AT THE CIRCLE
TRAFFIC CIRCLE
7TH STREET
PCH
710
405
605
91
22
4401E. Pacific Coast Highway Long Beach, CA 90804
Phone: (562) 494- 4444 / Fax: (562) 494-1350


DARANY'S FASHION
ហាងយើងខ្ញុំមានលក់
.Beauty Suplies . Phone Card .
ម្សៅលាបបំបាត់មុន.ជាំមុខ. ឡេចិញ្ចឹមស្បែកឱ្យបានស្អាត
ហាងយើងខ្ញុំមានសំលៀកបំពាក់ខ្មែរដែលរចនាម៉ូដដោយជាងចំណានៗ ធ្វើពី
ហូល ផាមួង និងក្រណាត់ប៉ាក់ មានគុបតែងមុខសំរាប់ពិធីផ្សេងៗ.មានលក់ថ្នាំ
បញ្ចុះទម្ងន់ មានទទួលផ្ញើរអីវ៉ាន់ និងគ្រឿងសម្ភារៈផ្សេងៗទៅកាន់ស្រុកខ្មែរ ។
.ថ្នាំម៉ាស្សាត្រាំទឹកដោះគោ .ឡេម្សៅល្បៀតលាបខ្លួន
.គ្រឿងអលង្ការធ្វើពីប្រាក់ .គ្រឿងលំអគ្រប់ប្រភេទ
Open 10:00 AM-6:00PM
( MON,SAT )
& 10:00 AM-5:00 PM
( SUNDAY )
មានសំលៀកបំពាក់ស្អាតៗ
គ្រប់ម៉ូដសំរាប់ពិធីមង្គលការ,
ជប់លៀង និងសំរាប់ទៅវត្ត នៅ
ឱកាសបុណ្យចូលឆ្នាំថ្មី ខ
DARANY'S FASHION
បញ្ចុះតម្លៃពិសេស
១៥%ពីថ្ងៃនេះ
រហូតដល់ថ្ងៃបុណ្យចូលឆ្នាំ
2201E. Anaheim St.# 102 . Long Beach, CA 90804
Store : (562) 438-2488 . Cell: (562) 786-2095

## វិចារណកថា

# បុព្វសិទ្ធិពលរដ្ឋខ្មែរ_អាមេរិកាំង

*ដោយ : ពិន សំខុន*

ខ្មែរយើងមុននឹងក្លាយទៅជាខ្មែរ-អាមេរិកាំង គឺមានរូបរាងខ្មែរ ហើយការគិតក៏ជាខ្មែរ តែដល់បានសញ្ជាតិជាអាមេរិកាំងហើយ បានទទួលបន្ថែមនូវអត្តសញ្ញាណប័ណ្ណជាជនជាតិអាមេរិកាំង ទទួលបុព្វសិទ្ធិថ្មីមួយចំនួន ហើយនឹងការគិតជាអាមេរិកាំងក៏មានបន្ថែមខ្លះមកទៀត ។

យុវជនខ្មែរជាច្រើន បានផ្តាច់ខ្លួនចេញពីអតីតកាលនៃការគិតថា "ខ្លួនអញជាខ្មែរ" ដោយសារតែប្រវត្តិនៃកម្ពុជា ជិតដាមដោយអំពើអាក្រក់មួយចំនួន ដែលការផ្សព្វផ្សាយស្តីពីកម្ពុជានៅអាមេរិកនេះ និយាយហើយនិយាយទៀត តែអំពើកាប់សម្លាប់រង្គាលរបស់ក្រុមខ្មែរក្រហម ហើយនឹងអំពើរំលោភ ឬប្រវ័ញ្ចរបស់រដ្ឋអំណាចបន្តបន្ទាប់គ្នា ហាក់ដូចជាកម្ពុជា មានតែប្រវត្តិសាស្ត្រ ជាពូជសាសន៍ដ៏កំសត់បំផុតតែប៉ុណ្ណោះ ។

ចាស់ៗជាច្រើនដែលស្គាល់ច្បាស់ថា "ពូជសាសន៍ខ្មែរជាអ្វីពិតប្រាកដ" ក៏ពុំបានជួយឱ្យការវិវត្តន៍ពីខ្មែរទៅអាមេរិកាំងនោះ មានដំណើរបន្តគ្នានោះទេ ដោយសារតែរវល់ប្រកបរបរចិញ្ចឹមជីវិត ដោយសារយល់ឃើញថា សាលារៀន និងសំណាងកូនចៅខ្លួនសមសួនរួចហើយ ដោយសារ ដោយសារភ្លេចជួយកូនចៅឱ្យបាននៅគិតជាខ្មែរ " ។ បុព្វហេតុទាំងនេះ បានជួយជំរុញយុវជន យុវតីខ្មែរឱ្យទៅជាអាមេរិកាំង ដោយមិនយកការ "គិតជាខ្មែរ" ទៅជាមួយនោះទេ ។ ការឃ្លាតពី "គំនិតជាខ្មែរ" នេះ ពុំបានផ្តាច់ខ្លួនពី "រូបរាងជាខ្មែរ" នោះទេ ដែលជាហេតុធ្វើឱ្យដំណើរទៅរក "ភាពជាអាមេរិកាំង" នោះ ចូលមិនចុះ ហើយត្រឡប់ជាខ្មែរវិញក៏មិនបាន ។ នៅហ្វីឡាដែលហ្វីយ៉ា នៅឡុងប៊ិច នៅឡូវែល មានយុវជនអាយុពី១៥ ទៅ ៣៥ឆ្នាំ រស់នៅក្នុងជីវភាពដាច់ពីខ្មែរ "តែចូលអាមេរិកាំងមិនចុះ" នេះ ស្ទើរតែទាំងអស់ ដោយខ្លះរស់នៅជាក្រុម "ហ្គេង" " Gang" ឬក៏នៅដាច់តែឯង មិនថាខ្លួនជាខ្មែរទេ ។

តែសហគមន៍ខ្មែរ ឬខ្មែរ-អាមេរិកាំងនេះ ចង់បានជាបុព្វសិទ្ធិជាអាមេរិកាំងនេះ ខ្លាំងក្លាណាស់ ដោយសារតែឥទ្ធិពលនៃសញ្ជាតិនេះល្បីល្បាញគ្របដណ្តប់លើពិភពលោក ដោយសារសញ្ជាតិនេះ តំណាងឱ្យភាពចេះដឹងសម្បូរសម្បត្តិ គួរឱ្យស្រឡាញ់ តែមនុស្សជាច្រើនយកបានតែក្រដាស់ដែលមានទ្រង់ទ្រាយជាលិខិតឆ្លងដែនពណ៌ខៀវជាអត្តសញ្ញាណប័ណ្ណជនជាតិអាមេរិកាំង តែប៉ុណ្ណោះ ។

ការពិតសិទ្ធិជាពលរដ្ឋអាមេរិកាំង គឺជាសង្គមខ្មែរមួយ ដែលនាំមកនូវការគោរពច្បាប់ គោរពសីលធម៌ ការជួយយកអាសារ ការសំអិតសំអាងសង្គមល្អ ឬចំរើន ។ នរណាចូលសង្គម "អាមេរិកាំងបាននោះ នឹងទទួលផលដែលបុព្វសិទ្ធិជាអាមេរិកាំងនោះបាន ។ តែសង្គមនោះពុំមែនត្រឹមតែជាលិខិតពណ៌ខៀវតែប៉ុណ្ណោះនោះ គឺជាការខិតខំប្រឹងរៀងរាល់ថ្ងៃ រាល់នាទី នៅក្នុងជីវិតជាពលរដ្ឋ "អាមេរិកាំង" នោះ ។

រៀងរាល់បួនឆ្នាំម្តង ពលរដ្ឋអាមេរិកាំងអនុវត្តន៍ក្បួនជ្រើសរើសមគ្គុទេសក៏ ដ៏ប្រសើរកំពូលរបស់គេ ដែលគេត្រូវតែទទួលស្គាល់ថា ជាមនុស្សអាចដឹកនាំ "អាមេរិកាំង" ទាំងអស់បាន ។ រីឯពលរដ្ឋខ្មែរ-អាមេរិកាំង នៅតែគ្មានក្បួន គ្មានមគ្គុទេសក៏ ឬក៏មានដែរ តែទទួលស្គាល់មិនបាន ។ ជាខ្មែរ-អាមេរិកាំង គេចូលចិត្តធ្វើនយោបាយស្រុកខ្មែរ ហើយធ្វើសកម្មភាពតិចតួចជាអាមេរិកាំង ដោយពុំអាចចងគ្នាជាចង្កោមនៃកម្លាំងបាន ដោយពុំមានអ្នកចេះដឹងច្រើន និងដោយខ្មែរជាសហគមន៍ក្រខ្សត់ ។ រូបភាពនេះ ពុំមែនជាលទ្ធផលនៃបុព្វសិទ្ធិជា "អាមេរិកាំង" នោះទេ តើហេតុក៏ខ្មែរអាមេរិកាំងមានសិទ្ធិជា "អាមេរិកាំង" ហើយពុំទទួលបាននូវបុព្វសិទ្ធិដ៏ថ្លៃថ្លារបស់គេបាននោះ ?

ឈរនៅលើទស្សនៈជាច្រើន អាចឱ្យយើងនិយាយបានថា ទទួលបុព្វសិទ្ធិជាអាមេរិកាំង បានត្រូវគោរពជាមូលដ្ឋានច្បាប់របស់គេឱ្យបាន១០០% ជួសជុលទស្សនៈ "ផ្តាច់ពីខ្មែរឱ្យជ្រះស្រឡះ" ឡើងវិញ ដើម្បីឱ្យវប្បធម៌ដើម ដែលជាខ្មែរអាចជួយសហគមន៍យល់គ្នាទៅវិញបាន តែទម្រង់ការយោគយល់ជាមិត្តភ័ក្តិ បងប្អូន ឱ្យមកទៅជា "ត្រូវ ឬខុស" ឱ្យបាន ។

ខ្មែរ-អាមេរិកាំងមួយចំនួនបានទទួលបុព្វសិទ្ធិ និងមានជោគជ័យក្នុងជីវិតបន្តបន្ទាប់គ្នាហើយ តែពុំបានទទួលផលទាំងស្រុងនៅឡើយទេ គេក៏ត្រូវងាកទៅសិក្សាប្រភពដើម នៃជីវិតជាខ្មែររបស់ខ្លួនឡើងវិញស្ទើរគ្រប់គ្នា ។ ចរន្តនៃគំនិតគ្រប់គ្រងគ្រួសារ បានតម្រូវឱ្យមាតាបិតា ឬអាណាព្យាបាលយកចិត្តទុកដាក់ពី "ចំណេះវប្បធម៌" របស់កូនចៅ និងបង្ហាញ "ការស្រឡាញ់" ឱ្យបានគ្រប់គ្រាន់ ។ គឺប្រាកដជាពុំមែនចំណេះតិចតួចរបស់មាតាបិតាទេ ដែលធ្វើឱ្យកូនចៅ "ធ្លាក់ទឹក" នៅក្នុងការសិក្សារបស់ខ្លួននោះ ។ កូនខ្មែរ សង្គមខ្មែរ ពុំបានទទួលបុព្វសិទ្ធជាខ្មែរ-អាមេរិកាំង បើតាមសេចក្តីសន្និដ្ឋានរបស់វិទ្យាល័យនៅសហរដ្ឋអាមេរិកនេះ គេអាចនិយាយថា "ការដាច់ឬសគល់" និង "គ្មានស្រឡាញ់ថែរក្សា" ជាបរាជ័យរបស់សហគមន៍ខ្មែរអាមេរិកាំងនាបច្ចុប្បន្ននេះ ៕

# គណបក្សខ្មែរមួយយកឥទ្ធិពលអាមេរិក រិះគន់របប ហ៊ុន សែន

*ឡុងប៊ិច : មាជ សុវណ្ណារ៉ា*

ឥទ្ធិពលអាមេរិកនោះធំដុំណាស់ កាលពីចុងសប្តាហ៍មុន ក្នុងកិច្ចសម្ភាសន៍ជាមួយខ្មែរប៉ុស្តិ៍ នៅការិយាល័យគណបក្សសង្គមខ្មែរនិយម លោក អឿន សារ៉ាត់ ដែលជាប្រធានបក្សអង្គុយពីមុខត្រាដ៏ធំ ដែលភ្ជាប់នឹងជញ្ជាំង ក្រោយខ្នងគាត់ គឺត្រាគណបក្សសង្គមខ្មែរនិយមស្រដៀងទៅនឹងត្រារបស់ប្រធានាធិបតីអាមេរិក។



លោក អឿន សារ៉ាត់ ប្រធានគណបក្សសង្គមខ្មែរនិយម

លោក អឿន សារ៉ាត់ បានសំដៅខ្លួនលោកជា "សម្តេច" នាំលទ្ធិប្រជាធិបតេយ្យពីសហរដ្ឋអាមេរិក ទៅធ្វើនយោបាយនៅកម្ពុជា តើវាគួរប្រសើរជាង "សម្តេច" ហ៊ុន សែន ដែលនាំលទ្ធិកុម្មុយនិស្តហូជីមិញមកដឹកនាំប្រទេសជាតិជិត៣០ឆ្នាំ បង្កឱ្យបាត់បង់បូរណភាពដែនដី និងលំហូរចូលនៃជនជាតិយួនរាប់លាននាក់ មកតាំងទីលំនៅខុសច្បាប់ទៀតនោះ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ជាមួយគណបក្សប្រជាជនកម្ពុជា និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន, លោក អឿន សារ៉ាត់ មិនប្រកាន់ទោសបន្ថែមទេ ព្រោះជាការជំពាក់គុណយួនច្រើនណាស់ ដោយពួកគេគ្មានជំរើសនៃបំណុលដឹងគុណរបស់យួន ។

លោក អឿន សារ៉ាត់ ក៏បានប្រៀបធៀបខ្លួនលោកទៅនឹងព្រះមហាក្សត្រជ័យវរ្ម័នទី៧ ដែលបានគេចខ្លួនពីការសំលាប់របស់ខ្មែរក្រហម ទៅរៀនមន្តអាគមពីសហរដ្ឋអាមេរិក ។ ដូច្នេះ ប្រសិនបើលោកអ្នកពេញចិត្តប្រជាធិបតេយ្យបែបអាមេរិក "កុំភ្លេចខ្ញុំ. ខ្ញុំសុំសន្លឹកឆ្នោតពីអស់លោក" ។

ប្រទេសកម្ពុជាគ្រោងរៀបចំការបោះឆ្នោតសកលឆ្នាំ២០០៨ នាថ្ងៃទី២៧ កក្កដា ដែលជាខែមួយក្នុងអតីតកាលរដ្ឋប្រហារបង្ហូរឈាម រវាងសហនាយករដ្ឋមន្ត្រីទី១ និងទី២ គឺលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ដែលបានបណ្តេញសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ចេញពីប្រទេសកម្ពុជា កាលពី១១ឆ្នាំមុន ដោយមានគណបក្សជាង៤០ នឹងចូលរួមប្រកួតប្រជែង ដណ្តើមតំណែងលោក ហ៊ុន សែន ។ ប៉ុន្តែ មាន ឬគ្មានលទ្ធភាព សន្លឹកបៀត្រូវកំពុងស្ថិតនៅក្នុងដៃប្រជាជន និងការគួបផ្សំទៅនឹងយុទ្ធសាស្ត្រ ពីគោលនយោបាយរបស់គណបក្សនីមួយៗក្នុងការឃោសនា ។ ហើយក៏យើងមិនត្រូវភ្លេចដែរ ពីស្ថេរភាពសន្តិសុខសុវត្ថិភាព និងអព្យាក្រិត្យភាពសំរាប់ការបោះឆ្នោត តើអាចមានលទ្ធិប្រជាធិបតេយ្យត្រឹមត្រូវទេ បើគ្មានទេ (តទៅទំព័រទី០៨ )


BBS ACCOUNTING

BETTER BUSINESS SERVICES= LEGAL-ACCOUNTING-INCOME TAX

❖សូមអញ្ជើញជាមួយសេវាកម្មការិយាល័យពន្ធដារយើងខ្ញុំ:

- បំពេញសំណុំរឿងពន្ធដារ បុគ្គល ពាណិជ្ជកម្ម សហគ្រាស និងក្រុមហ៊ុន
- ទទួលរក្សាសំណុំរឿងគណនេយ្យ និង Payroll
- ធានាទាមទារប្រាក់ពន្ធដារជូនលោក-អ្នកបានច្រើនបំផុត ដោយស្របច្បាប់ពីក្រសួងពន្ធដារ ។

ធ្វើតាក់: 1040 Individual, 1065 Partnership, 1020 Cooperation and Electronic filling

☞Sale Tax : Monthly, Quarterly, yearly
☞All words Guaranted .
☞មានទទួលនូវការធានាក្រៅឃុំ (BAIL BOND)
☞ចែកទ្រព្យសម្បត្តិ ☞លក់ដូរហាងទំនិញ ☞ធ្វើកុងត្រាជាដើម ។
☞យើងខ្ញុំមានបទពិសោធន៍ និងកេរ្តិ៍ឈ្មោះល្បីយូរឆ្នាំមកហើយ ជាមួយការពិគ្រោះយោបល់ ដោយមិនគិតកម្រៃ ដោយមានអ្នកនិយាយភាសាខ្មែររងចាំជួយសំរួលលោកអ្នក! (Open Year Round)!

Tel: (562) 434-1199 ឬ 883-2089. Fax: (562) 433-0349
3024E. Anaheim Street .Long Beach, CA 90804

# តើសម្ដេចក្រុមព្រះ មាន ឬគ្មាន ឱកាសចូលរួមក្នុងការបោះឆ្នោតឆ្នាំ ២០០៨ ?

***កម្ពុជា : សុភាឫទ្ធិ***

សម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ អតីតប្រធានរដ្ឋសភា និងអតីតប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ដែលមានកិត្តិនាមល្បីល្បាញ ក្នុងឆាកនយោបាយ ។ ព្រះអង្គកំពុងតែជាប់ចោទពីបទរំលោភសេចក្ដីទុកចិត្ត ហើយត្រូវរស់នៅប្រទេសម៉ាឡេស៊ី និរទេសព្រះកាយ ។

សម្ដេចក្រុមព្រះ ទោះបីជាត្រូវតុលាការចោទប្រកាន់ឱ្យជាប់ទោសរយៈពេល១៨ខែ មិនឱ្យយាងចូលប្រទេសយ៉ាងណាក្ដី ព្រះអង្គបានបង្កើតគណបក្សនរោត្តម រណឫទ្ធិ ដើម្បីចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។

គណបក្សរាជានិយមនេះ ទោះបីប្រធានអវត្តមានយ៉ាងណាក្ដី តែក្រុមអ្នកស្មោះត្រង់នឹងព្រះអង្គនៅតែបន្តសកម្មឃោសនារកការគាំទ្រពីប្រជាពលរដ្ឋទៀត ។ លទ្ធផលជាផ្លូវការនៃការបោះឆ្នោត ក្រុមប្រឹក្សាឃុំ-សង្កាត់ កាលពីឆ្នាំ២០០៧ កន្លងមកឃើញថា ទទួលបានលទ្ធផលតិចតួចណាស់ ។

សម្លេងគាំទ្ររបស់ប្រជាពលរដ្ឋបានធ្លាក់ចុះជាបន្តបន្ទាប់ ចំពោះគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ដោយសារតែការឈ្លោះទាស់ទែងគ្នាមិនឈប់ឈរ រវាងថ្នាក់ដឹកនាំមួយចំនួន ។

ម្យ៉ាងទៀត ចំនួនអ្នកគាំទ្រមានការអស់សង្ឃឹមចំពោះមេដឹកនាំនៃគណបក្សទាំងពីរ ដែលគិតតែហែកហួរគ្នា ហើយគណបក្សហ៊្វុនស៊ិនប៉ិច បានដាក់ពាក្យបណ្ដឹងសម្ដេចក្រុមព្រះឱ្យជាប់ចោទ នៅតុលាការពីបទលក់ទីស្នាក់ការគណបក្ស ។

ចំណែកសម្ដេចក្រុមព្រះបានបដិសេធថា ព្រះអង្គមិនបានធ្វើអ្វីស្រេចតែចិត្តនោះទេ គឺមានការឯកភាពគ្នាពីថ្នាក់ដឹកនាំទាំងអស់ ទើបព្រះអង្គហ៊ានសម្រេច ហើយព្រះអង្គមិនបានកាន់លុយនោះដែរ ។

ចាប់តាំងពីធ្វើបក្សប្រហារទំលាក់សម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ ពីព្រះប្រធានបក្សហ៊្វុនស៊ិនប៉ិច នៅថ្ងៃទី១៨ តុលា ឆ្នាំ២០០៦ មក ស្ថានការគណបក្សហ៊្វុនស៊ិនប៉ិច ធ្លាក់ចុះដុនដាបកាន់តែខ្លាំង រហូតមន្ត្រីស្មោះត្រង់មួយចំនួន រត់ទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ។

ដោយមានការក្រពុលមុខខ្លាំង លោក ញឹក ប៊ុនឆៃ អគ្គលេខាគណបក្សហ៊្វុនស៊ិនប៉ិច បានដាក់ពាក្យទៅតុលាការប្ដឹងព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ពីបទលក់ទីស្នាក់ការបក្ស ។





សកម្មភាពរបស់សម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ កាលនៅជាប្រធានរដ្ឋសភា



ចំណែកសម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ ក៏បាននិរទេសព្រះកាយទៅរស់នៅប្រទេសម៉ាឡេស៊ី ជាមួយភរិយាក្មេង គឺអ្នកម្នាង អ៊ុក ផល្លា និងបុត្រាមួយអង្គគួរឱ្យស្រឡាញ់ ។

ការប្ដឹងផ្ដល់នេះ តុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍ បានសម្រេចកាត់ទោសឱ្យសម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ ជាប់គុកកំបាំងមុខ១៨

( តនៅទំព័រទី១០ )


## LAW OFFICES OF FRANK G. PIAZZA, JR. & ASSOCIATES

**-PROFESSIONAL AGRESSIVE. DISCREET,EXPERIENCE, REPRESENTATION**

**CRIMINAL LAW AND FAMILY LAW ARE STRICTLY HANDLED BY AN UNASSOCIATED ATTORNEY**

- Serious accident **Required Experienced and Compentent Representation** to make sure you received adequate compensation for your injuries. Otherwise, you(the injured person) could lose thousands of dollar with **the Incompentent and Unexperienced Representation.**
- I Speak Combodian/English fluently, I have many years of experience on dealing and negotiating for maximum settlement possible with insurance compenies for our clients.
- Appointments are available for you to come in office after working hour and weekend. Please call in advance.

100 OCEANGATE,SUITE 525,
LONG BEACH.CA 90802
TEL:(562) 708-3721, Fax: (562) 437-8425,
Email:MORALAW5@YAHOO.COM



MORA MAO FRANK PIAZZA DOUGLAS MELSON

- ត្រូវរបួសធ្ងន់ធ្ងរត្រូវឱ្យមានអ្នកតំណាងមានសមត្ថភាព និងមានការពិសោធន៍យ៉ាងបរិបូណ៌ ដើម្បីទារសំណងឱ្យបានសមរម្យនឹងរបួសលោកអ្នកពុំនោះទេ លោកអ្នកនឹងត្រូវខាតបង់ប្រាក់ច្រើនពាន់ដុល្លារ កាលបើអ្នកតំណាងក្ដីរបស់លោកអ្នកអសមត្ថភាព និងខ្វះការពិសោធន៍ ។
- ខ្ញុំបាទស្ទាត់ជំនាញខាងភាសាខ្មែរ,អង់គ្លេសមានទេពកោសល្យខាងពិភាក្សាចរចាក្នុងរឿងក្ដីរបស់លោកអ្នក ជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងជាច្រើនកន្លែងមកហើយ ។
- កិច្ចការ ហ្មត់ចត់ ម៉ឺងម៉ាត់ រហ័សទាន់ចិត្តទាំងក្នុង និងក្រៅតុលាការ ។
- លោកអ្នកអាចធ្វើការណាត់ជួបខ្ញុំបាទ ក្រៅម៉ោងធ្វើការ ឬចុងសប្ដាហ៍ ។

***Our Recent successful cases :***

- **$1,000,000.00,** Bicylist Vs Truck Case, Guranteed annuity.
- **$100.,000.00,** Dog Bites Vs Home Owner Insurance of the apt.complex.
- **$250,000.00,** Auto Vs Auto, Settlement
- **$100,000.00** Motorcycle Vs. Auto, Settlement, 2/2008

**INJURY / DEATH CASES:**

- Wrongful death
- Broken / fracture bones
- Amputation / Paraplegia
- Auto / Bicycle / Motorcycle
- Uninsured Motorist
- Dog Bites
- All insurance Disputes

**CRIMINAL/STATE &FEDERAL:**

- Drug offense
- Murder
- Rape
- Kidnapping
- Fraud
- DMV Hearings
- Hit & Run
- Assault & Battery

**FAMILY LAW:**

- Child Custody
- Divorce
- DA Child Support
- Legal Separation



# អ្នកនយោបាយផ្លាស់ប្តូរបក្ស ដើម្បីបំរើជាតិ ឬដើម្បីអំណាចលាភសក្ការៈផ្ទាល់ខ្លួន ?

***កម្ពុជា: សុភាបុទ្ធិ***

●●●ការបោះឆ្នោតជ្រើសរើសអ្នកតំណាងរាស្ត្រ អាណត្តិទី៤ បានខិតជិតមកដល់ ហើយគេសង្កេតឃើញមេដឹកនាំនៃគណបក្សនយោបាយនីមួយៗ បានរៀបចំយុទ្ធសាស្ត្រប្លែកៗគ្នា ដើម្បីដណ្តើមការគាំទ្រពីប្រជាពលរដ្ឋ ។



លោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី



លោក លី ធុច អនុប្រធានរៀបចំបោះឆ្នោត

ចំណែកអ្នកនយោបាយទាំងថ្មី និងចាស់មួយចំនួនបានផ្លាស់ប្តូរបក្សទៅវិញទៅមក គួរឱ្យកត់សំគាល់ ។ ចលនានៃការផ្លាស់ប្តូរបក្សរបស់ខ្លួនទៅចូលរួមជាមួយបក្សដទៃ ជាពិសេសគណបក្សប្រជាជនកម្ពុជាត្រូវបានអង្គការសង្គមស៊ីវិលហៅថា ជាការស្វែងរកលាភសក្ការៈ និងមុខតំណែងតែប៉ុណ្ណោះ ។

ការរត់ពីបក្សមួយទៅចុះចូលជាមួយបក្សមួយទៀត របស់អ្នកនយោបាយមួយចំនួន កាន់តែមានភាពផុសផុលគួរឱ្យចាប់អារម្មណ៍ ដែលធ្វើឱ្យប្រជាពលរដ្ឋអ្នកគាំទ្រពិបាកនឹងជឿ ។ សកម្មភាពនេះ ត្រូវបានអ្នកវិភាគនយោបាយ និងអង្គការសង្គមស៊ីវិល ហៅថា ជាការស្វែងរកបុណ្យសក្តិ និងលាភ

( តទៅទំព័រទី១៥ )


## G.M. Tax Services

**ការិយាល័យគណនេយ្យ និងពន្ធដារ**

2201 E. Anaheim St., Suite 103
Long Beach, CA 90804
Cell: (562) 881-4021,
Office: (562) 439-30
E-mail: GMtaxsevices@verizam.net

**បំពេញសំណុំរឿងពន្ធដារប្រចាំឆ្នាំ២០០៧**

▶ តំណាងលោក-អ្នកនៅក្រសួងពន្ធដារ នៅពេលលោក-អ្នកត្រូវក្រសួងសើរើ, វិភាគកិច្ចការ ហិរញ្ញវត្ថុ, គណនេយ្យ ។
▶ ណែនាំ ពន្យល់លោក-អ្នកយ៉ាងក្បោះក្បាយគ្រប់ភារកិច្ចទាំងឡាយទាក់ទងនឹងពន្ធដារ ។
▶ សូមមេត្តាទាក់ទងជាមួយអ្នកជំនាញឯកទេសគណនេយ្យ និងពន្ធដារ Gary Ung ក្នុងរដូវធ្វើតាក់ (Tax) ដោយមិនឱ្យលោក-អ្នកខុសបំណងឡើយ ។

Jim Suos
Realtor, Loan Consultant
jimsuos@hotmail.com
Fax (562) 426-1880
(562) 427-0767



First AMERICAN TEAM REALTY ™

**ក្រុមហ៊ុនលក់_ទិញគេហដ្ឋាននិងខ្ចីប្រាក់**

Cell: (562) 884-0892

ជំនាញឯកទេសជាទីទុកចិត្តនិងស្មោះត្រង់ចំពោះលោក-អ្នកក្នុងការរកស៊ីលក់ដូរពិគ្រោះយោបល់ ជាមួយបទពិសោធន៍ជាង១២ឆ្នាំក្នុងកិច្ចការលក់-ទិញផ្ទះ-ហាងជំនួញ និងខ្ចីលុយព្រមទាំងផ្នែកសាងសង់សំណង់ជិត៣០ឆ្នាំ

| LONG BEACH | LOS ALAMITOS | HUNTINGTON BEACH |
|---|---|---|
| 2501 CHERRY AVE. SUITE100 | 10704 LOS ALAMITOS BLVD. | 2100 MAIN ST. STE.225 |
| SIGNAL HILL, CA 90755 | LOS ALAMITOS, CA 90720 | HINTINGTON BEACH, CA 92648 |

## ចង់ឃើញសម្តេចសីហនុ...

អត់ហ៊ាននិយាយអត់ហ៊ាន លូកដកកូរកកាយ ទៅលើព្រំដែនជាមួយលាវ ភូមា និងម៉ាឡេស៊ី ពីព្រោះប្រទេសទាំងនោះ គេមានរដ្ឋាភិបាលមួយ ដែលមានជំហររឹងមាំ ។ យើងមិនកាន់ជើងរដ្ឋាភិបាលលាវ ឬភូមា នោះទេ ដែលជារដ្ឋាភិបាលកុម្មុយនិស្ត ប៉ុន្តែអ្វីដែលយើងចង់ដៅសំខាន់ គឺភាពជាម្ចាស់ការគ្រប់គ្រងទៅលើដែនដីរបស់ខ្លួន ។



ប្រាសាទព្រះវិហារដែលបែកបាក់ដោយសារសង្គ្រាម

សម្តេចសីហនុ ដែលអតីតកាលជាម្ចាស់ឈ្នះក្តីជាមួយសៀម រឿងប្រាសាទព្រះវិហារ ធ្លាប់មានព្រះរាជបន្ទូលថា តំបន់ព្រំដែនខ្មែរ-យួន-សៀម គ្មានតំបន់ស-ខ្មៅអ្វីទេ ។ មានតែការចង់រំលោភយកដីខ្មែរពីជនបរទេសតែប៉ុណ្ណោះ ទើបបានគេចោទប្រកាន់ថា ជាតំបន់ស-ខ្មៅ ដើម្បីបង្កើតទំនាស់ ។

រដ្ឋាភិបាលសៀមអះអាងថា បញ្ហាការដាក់បញ្ចូលប្រាសាទព្រះវិហារ ទៅក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោករបស់អង្គការ UNESCO គឺជាបញ្ហាធំ ដែលកម្ពុជាគិតអ្វីតាមដែលគេចង់គិត ហើយយើងជាជនជាតិថៃ ក៏មិនគិតអ្វីខុសពីហ្នឹងដែរ ។ នេះជាសំដីរបស់នាយកមន្ត្រីថៃ សាម៉ាក់ ស៊ុនថនវ៉ាយ៉េត ដែលថ្លែងប្រាប់កាសែតបាងកកប៉ុស្តិ៍ ។

ឧបនាយករដ្ឋមន្ត្រីខ្មែរ សុខ អាន គ្រោងនឹងជួបជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសថៃ នៅចុងខែកុម្ភៈនេះ ដើម្បីលើបញ្ហាសំណើរថៃ ដែលលើកម្តងហើយម្តងទៀត ជុំវិញការចង់ចូលរួមចាត់ចែងជាមួយកម្ពុជាក្នុងសំណើរដាក់ប្រាសាទព្រះវិហារខ្មែរជាបេតិកភ័ណ្ឌពិភពលោក ។

ទស្សនៈនេះ និងមតិរបស់ពលរដ្ឋខ្មែរក្នុងស្រុក និងក្រៅប្រទេស សុទ្ធតែបានបង្ហាញថា រដ្ឋាភិបាលថៃ កំពុងតែលូកដៃ និងរំលោភទៅនឹងអធិបតេយ្យភាពរបស់ខ្មែរខ្លាំងពេកហើយ ។ ហើយរដ្ឋាភិបាលខ្មែរ មិនត្រូវទទួលយកការលើកឡើង របស់ប្រទេសសៀមនោះទេ ពីព្រោះប្រាសាទព្រះវិហារ ជាប្រាសាទរបស់ខ្មែរ ដែលពិភពលោកបានដឹងហើយថា ជាកេរមរតក សម្បត្តិវប្បធម៌របស់ខ្មែរ ដែលរដ្ឋាភិបាលខ្មែរ មិនត្រូវបន្ទន់ឥរិយាបថណាមួយ ចំពោះការលើកឡើងរបស់រដ្ឋាភិបាលសៀម ជាដាច់ខាត ដែលសៀម គ្មានសិទ្ធិណាមកលូកលាន់ធ្វើការបែងចែកអ្វីទេ ។ ( តទៅទំព័រទី១៤ )

Unipaq Realty & Financial
Complete Real Estate Services
សូមអញ្ជើញដោយមេត្រីភាព !
-បំរើកិច្ចការរ៉ាររលក់ដូរទិញផ្ទះទូទៅ
-អ្នកប្រឹក្សាពិគ្រោះយោបល់នៃការខ្ចីប្រាក់



David Kuoch
*Real Estate Agent*
*Loan Consultant*

Cell: (714) 351-2803
Office: (714) 892-2070
Fax: (714) 893-2059
Residence: (714) 774-4061
12062 Valley View St., Suite 204B
Garden Grove, CA 92845
Email: davidkuoch@sbcglobal.net

សោភារីតន្ត្រី Sopheary Band

ក្រុមតន្ត្រីសោភារី
រីករាយបំផុតក្នុងការប្រគំតូរ្យតន្ត្រីជូនលោក-អ្នកក្នុងពិធីបុណ្យផ្សេងៗ ។
សូមទាក់ទងអ្នកគ្រប់គ្រង :
Charlie Ouk 562-591-2011
Cell: 562-400-7678




សមាគមខ្មែរនៅអាមេរិក

2 Hearts, 2 Hands, 1 Purpose
Building a Strong, Healthy Marriage

CAMBODIAN ASSOCIATION OF AMERICA
A Nonprofit Human Services Organization

## លំនាំសុភមង្គលនៃស្វាមីភរិយា និងគ្រួសារ

***តពីលេខមុន***

ហើយការអប់រំនេះទៀតសោត ក៏អាចជួយដល់ស្វាមីភរិយា ក្នុងកិច្ចការពារ និងដោះស្រាយបញ្ហាសំខាន់ៗជាច្រើន ដែលកើតមានឡើងក្នុងរង្វង់គ្រួសារ ។

-និយាយឱ្យត្រង់ ហើយអស់សេចក្តី កុំគិតស្មានថា គេយល់យើងដោយប្រើសំដីបញ្ចិតបញ្ចៀង

-និយាយអ្វីដែលគួរឱ្យនិយាយ ហើយកុំនិយាយអ្វីដែលគ្មានហេតុផល

-អ្វីៗដែលត្រូវយកមកដោះស្រាយត្រូវតែឱ្យមានការទំនាក់ទំនងនឹងខ្លួនឯងផ្ទាល់

-សាកសួរពីគំនិតគេ កុំនឹកគិតថា អ្នកបានយល់ច្បាស់ពីគំនិត និងអារម្មណ៍របស់ភាគីអ្នកឱ្យសោះ

-កុំនិយាយពាក្យអកុសល

-ស្តាប់ស្ទង់កិរិតចេះដឹងរបស់អ្នក

-រំលឹកចំណុចសំខាន់ៗ ធ្វើការព្រមព្រៀងគ្នា ហើយធ្វើការសំរេចចិត្តឱ្យបានត្រឹមត្រូវ បើសិនជាចង់និយាយម្តងទៀត ។

**ទង្វើទាំងឡាយដែលនាំឱ្យរាក់ខានដល់ការយកចិត្តទុកដាក់ស្តាប់ក្នុងកិច្ចសន្ទនា :**

-រអ៊ូរទាំ

-ត្អូញត្អែរច្រំដែលៗ

-ស្រែកឡូឡា ដោយគ្មានហេតុផល

-រៀបរាប់ប្តឹងផ្តល់ឥតឈប់ឈរ

-បញ្ចេញរឿងរ៉ាវច្រើនហួសហេតុពេក ក្នុង ពេលតែមួយ

**របៀបស្តាប់មានពីរយ៉ាង :**

១-ស្តាប់ដើម្បីបង្កើតឱ្យមានបញ្ហាបន្ថែម :

-ស្តាប់ដើម្បីទំនាស់ (ព្រោះមានការល្មៀសខ្លួន)

-ស្តាប់ដើម្បីចាប់កំហុស

-ស្តាប់ប្រមែប្រមូលចំណុចខ្សោយសំរាប់ផ្ចាញ់ផ្ចាល

-ប្រើពាក្យ "ប៉ុន្តែៗ" គ្រប់ការឆ្លើយតប

-មិនធ្វើការឆ្លើយតបទាល់តែសោះ

-ស្តាប់គ្រាន់តែចាប់ចំណុចសំរាប់តែឆ្លើយតប

២-ការយកចិត្តទុកដាក់ស្តាប់ ដែលមានប្រសិទ្ធិ ភាព :

-ស្តាប់ដើម្បីយកមករៀនសូត្រ (រើសរកគំនិតល្អៗដើម្បីកសាងស្ថាបនា)

-ស្តាប់ដើម្បីដកស្រង់យកអត្ថន័យ និងខ្លឹមសារ យ៉ាងត្រឹមត្រូវ

-ប្រមូលយកព័ត៌មានណាដែលផ្តល់ប្រយោជន៍ដល់កិច្ចសន្ទនានេះ

-ប្រើពាក្យ "និង" ក្នុងការឆ្លើយតប

-ធ្វើការឆ្លើយតបជាញឹកញាប់

-ស្តាប់ដោយយកចិត្តទុកដាក់លើពាក្យ សំខាន់

**ស្តាប់ដោយបន្ទន់ឥរិយាបថ ហើយសម្របតាមៈ**

-សំឡឹងមើលគ្នា

-ងាយខ្លួនទៅរកអ្នកដែលកំពុងនិយាយជាមួយ

-ងាយក្បាលនៅពេលអ្នកយល់ ឬជ្រួតជ្រាប ព័ត៌មាន

-ឆ្លើយជារបៀប "បាទ! ចាស់" យល់ហើយ

-ស្តាប់ហើយយកចិត្តទុកដាក់ តែកុំធ្វើពើ ដូចជាកំពុងស្តាប់

***នៅមានត***

Funding for This project is provided by U.S Department of Health and Human Services Administration for Children and Families Grant #90FE0065

# សុខ អាន ទំនងមិនអាច...

និងការសម្តោចកាត់ខ្សែបូរក្រុងខ្មែរ នាខែមេសា ឆ្នាំ២០០៨ ស្ថិតនៅក្នុងការមិនច្បាស់លាស់នៅឡើយទេ ដែលគេគិតថា ទំនងអាចមិនមកតាមការអញ្ជើញ ខណៈដែលពលរដ្ឋខ្មែរ-អាមេរិកាំងមិនតិចជាងពាន់នាក់ គ្រោងនឹងធ្វើបាតុកម្មប្រឆាំងនឹងវត្តមាន សុខ អាន នៅក្នុងសហគមន៍ខ្មែរក្រុងឡុង-ប៊ិច ។

កាលពីដើមខែធ្នូ ក្រុមគណៈប្រតិភូក្រុងខ្មែរ



លោក សុខ អាន



លោក ឆាំង សុខ

ដែលដឹកនាំដោយអ្នកស្រីប្រធាន សិទ្ធា សាន បានចូលជួបសវនាការជាមួយលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដោយក្រុមគណៈប្រតិភូក៏បានអញ្ជើញលោក សុខ អាន ឱ្យមកទស្សនកិច្ចក្រុងខ្មែរ និងធ្វើជាគណៈអធិបតី ។ ក្នុងឱកាសនោះ លោកជំនួយការជំនិតបំផុតរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានយល់ព្រមតាមការអញ្ជើញដោយផ្ទាល់មាត់ ប៉ុន្តែ មិនមានលាយល័ក្ខអក្សរជាផ្លូវការណានៅឡើយទេដែរ ។

លោក ឆាំង សុង រដ្ឋមន្ត្រី ដែលមានកិច្ចការងារធ្វើជាមួយលោកឧបនាយករដ្ឋមន្ត្រី សុខ អាន បានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា រូបលោកបានធ្វើសេចក្តីរាយការណ៍ ចំពោះស្ថានការណ៍នៃសកម្មភាពទាំងសងខាង គឺខាងក្រុមគណៈកម្មការក្រុងខ្មែរ និងខាងក្រុមទំទាស់ ។

ការត្រៀមធ្វើបាតុកម្មប្រឆាំងនឹងការអញ្ជើញមករបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យជ្រាបជាដំណឹងសំរាប់លោក សុខ អាន ពិចារណាក្នុងការថ្លឹងថ្លែង និងការសម្រេចចិត្ត។ ប៉ុន្តែ រហូតមកដល់ថ្ងៃនេះ មិនទាន់មានសេចក្តីឆ្លើយប្រាប់ពីរូបលោកអំពីដំណើរទស្សនកិច្ចនោះទេ ។

ដូច្នេះ ការមកកាន់ក្រុងខ្មែររបស់លោក សុខ អាន នៅមិនទាន់ច្បាស់លាស់នៅឡើយទេ ។

លោក ឆាំង សុង បានបន្តថា លោកឧបនាយកមន្ត្រី សុខ អាន មិនទាន់មានផែនការការងារជាផ្លូវការណាមួយទៅកាន់សហរដ្ឋអាមេរិក ឬតាមការអញ្ជើញពីក្រសួងការបរទេស និងសេតវិមានរបស់រដ្ឋបាល Bush នៅឡើយទេដែរ មកដល់ពេលនេះ ។

ខ្មែរប៉ុស្តិ៍បានទាក់ទងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន តាមទូរស័ព្ទចំនួន២ដង ដើម្បីសុំការបំភ្លឺឱ្យច្បាស់ពីដំណើរទស្សនកិច្ចថា តើមកកាន់ក្រុងខ្មែរ ឬក៏មិនមក? ប៉ុន្តែ ចម្លើយឆ្លើយតបរបស់លោក សុខ អាន បានត្រឹមតែ "ជាប់ប្រជុំ និងរវល់ជួបភ្ញៀវSic ។

អ្នកស្រី សិទ្ធា សាន ប្រធានក្រុងខ្មែរ បានប្រាប់ខ្មែរប៉ុស្តិ៍ឱ្យដឹងថា តាមដែលអ្នកស្រីបានទាក់ទងបានផ្តល់ព័ត៌មានថា លោកឧបនាយករដ្ឋមន្ត្រី សុខ អាន នឹងមកចូលរួមជាគណៈអធិបតី តាមការអញ្ជើញដដែល ។

ប៉ុន្តែ ក្រុមគណៈកម្មការក្រុងខ្មែរ មិនទាន់បានទទួលលិខិតជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជានៅឡើយទេ ។ ដោយអ្នកស្រី សិទ្ធា សាន បញ្ជាក់សំដីថា វាក៏អាចមានការផ្លាស់ប្តូរក្នុងដំណើរទស្សនកិច្ចនាថ្ងៃនោះផងដែរ ប្រសិនបើរូបលោក សុខ អាន ផ្លាស់ប្តូរចិត្ត និងជាប់ភារកិច្ចមមាញឹកការងារជាឧបនាយករដ្ឋមន្ត្រី ដែលទទួលបន្ទុកស្អេកស្កះ ។

ការទៅអញ្ជើញលោក សុខ អាន ត្រូវទទួលរងនូវប្រតិកម្មប្រឆាំង ពីសំណាក់មហាជនខ្មែរ នៅក្រុង Long Beach រហូតដល់មានការបង្កើតក្រុមគណៈកម្មការខ្មែរមួយឡើងបំណងស្វែងរកមេដៃប្រឆាំងតវ៉ា ឬធ្វើបាតុកម្មចំពោះការមកកាន់ក្រុងខ្មែររបស់លោក សុខ អាន ដែលរហូតមកដល់ថ្ងៃនេះ មានហត្ថលេខាផ្ទាល់ផង និង On Line ផងជាង ១000 នាក់ រួចទៅហើយ ។

អគ្គលេខាធិការក្រុមប្រឹក្សាអន្តរជាតិឃ្លាំមើលកម្ពុជា លោក អ៊ា ចាន់ណា បានជំទាស់ថា អ្នកដឹកនាំក្រុងខ្មែរគួរគិតឡើងវិញ ពីវត្តមាន សុខ អាន មិនមែនជាការចាំបាច់ក្នុងការមកចូលរួមជាគណៈអធិបតីទេ ពីព្រោះពលរដ្ឋខ្មែរនៅក្រុងឡុងប៊ិចមិនមែនទទួលបាននូវការឱ្យតំលៃពីរដ្ឋាភិបាលកម្ពុជានោះទេដែលជាទង្វើមួយផ្ទុយពីស្មារតីច្បាប់ និងឆន្ទៈប្រជាជន ។

ប្រសិនបើបងប្អូនខ្មែរនៅសហរដ្ឋអាមេរិក នៅតែទទួលយកវត្តមាន សុខ អាន ឬក្រុមប្រតិភូលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺមានន័យថាយើងបានចូលរួមបំផ្លាញជាតិយើង គាំទ្រឱ្យមានការកាប់សម្លាប់ទៅលើពលរដ្ឋខ្មែររបស់យើង គាំទ្រឱ្យមានអំពើពុករលួយនៅក្នុងប្រទេសកម្ពុជារបស់យើង គាំទ្រឱ្យមានការចុះហត្ថលេខាកាត់ដីឱ្យយួន គាំទ្រឱ្យមានការកាប់បំផ្លាញ និងលួចទ្រព្យសម្បត្តិជាតិរបស់យើង ។

ដូច្នេះខ្ញុំគិតថា យើងមិនគួរណាគាំទ្រ ហើយសូមឱ្យគោរពសំលេងភាគច្រើន ដែលពលរដ្ឋយើងជាម្ចាស់នៃសហគមន៍ទាំងមូលគេសំរេចយ៉ាងដូចម្តេច ? យើងត្រូវតែគោរពទៅតាមនោះ ដែលនេះជាគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។

នៅក្នុងលិខិតផ្ញើជូនទៅចៅហ្វាយក្រុង Bob Foster ដែលកាសែតខ្មែរប៉ុស្តិ៍ទទួលបាន គឺធ្វើក្នុងបំណងតវ៉ាចំពោះវត្តមានរបស់លោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលនឹងអញ្ជើញមកចូលរួមក្នុងពិធីព្យុហយាត្រាអបអរសាទរបុណ្យចូលឆ្នាំខ្មែរ នាខែមេសា ឆ្នាំ២០០៨ ។

នៅក្នុងលិខិតនោះ ក្រុមគណៈកម្មការជំទាស់ក៏បានបង្ហាញនូវស្ថានការណ៍នយោបាយប្រទេសកម្ពុជា ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ហ៊ុន សែន ដែលបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស. អំពើពុករលួយខ្លាំងបំផុត នៅក្នុងពិភពលោកសព្វថ្ងៃនេះ ដោយបានទទួលចំណាត់ថ្នាក់ទី១៦២ ក្នុងចំណោមប្រទេសទាំង ១៨០ ដែលជាប្រទេសកំពុងបង្កអំពើពុករលួយ ។ ការដែលមានចុះហត្ថលេខា ដោយជនជាតិខ្មែរនេះ មិនមែនមានន័យថា ជាជាតិខ្មែរមានការតក់ស្លុតខ្លាំង ដោយមើលឃើញថា បុរសដៃស្តាំដ៏មានឥទ្ធិពលម្នាក់នោះ ត្រូវបានអញ្ជើញមកចូលរួមក្នុងក្បួនព្យុហយាត្រា ដែលជាពិធីមួយប្រារព្ធធ្វើឡើង ដើម្បីភាពផ្សេងៗពីគ្នារវាងសហគមន៍ ព្រមទាំងសេរីភាពរបស់បុគ្គលម្នាក់ៗ ថាតើគេអាចនឹងប្រារព្ធធ្វើពិធីនោះ ប្រកបដោយគុណតំលៃបានដោយរបៀបណា ។

ជាមួយការស្វាគមន៍ចំពោះ អ្នកដែលឆ្មៀតជ្រែកប្រឆាំងនឹងគុណតំលៃទាំងនោះ តើបងប្អូនខ្មែរ ដែលកំពុងប្រារព្ធពិធីសហគមន៍អ្វី នឹងសេរីភាពអ្វីនៅប្រទេសកម្ពុជាជាទីកន្លែងដែលលោក សុខ អាន ព្រមទាំងអ្នករួមការងាររបស់គាត់គ្រប់គ្រងប្រជាជន តាមរយៈនៃការដេញចេញដោយបង្ខំ ព្រមទាំងមានការរំលោភបំពានយកដីធ្លីយ៉ាងធ្ងន់ធ្ងរ ពេលដែលសេរីភាពនៃការបញ្ចេញមតិត្រូវរងនូវការចាប់ដាក់គុក និងស្លាប់នោះ ។

ចុងបញ្ចប់នៃញត្តិ ក៏បានស្នើសុំឱ្យលោកអភិបាលក្រុង មេត្តាយោគយល់ និងមានក្តីមេត្តាចំពោះបញ្ហានេះ ដោយសង្ឃឹមថា ចៅហ្វាយក្រុងនឹងចាត់ទុកជាមោឃៈ ចំពោះសេចក្តីអញ្ជើញលោក សុខ អាន ជាមិនខាន ។

រហូតមកដល់ពេលនេះគេពុំទាន់ឃើញមានការឆ្លើយតបណាមួយពីចៅហ្វាយក្រុង Long Beach នៅឡើយទេ ។

ប្រភពព័ត៌មានថា សាលាក្រុង Long Beach គ្រោងនឹងអញ្ជើញ គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាមកទស្សនកិច្ច នៅក្រុង Long Beach ក៏មិនទាន់ច្បាស់លាស់ទៀត ព្រោះកិច្ចការរដ្ឋបាលការទូត វាជាភារកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធពោលគឺការអញ្ជើញណាមួយ រវាងថ្នាក់ដឹកនាំ និងថ្នាក់ដឹកនាំ ត្រូវធ្វើតាមផ្លូវការទូត ប្រទេស និងប្រទេស ។

គណៈកម្មការក្រុងខ្មែរ គ្រោងយកថ្ងៃទី០៦ ខែមេសាខាងមុខរៀបចំពិធីព្យុហយាត្រាអបអរសាទរទទួលទេវតាឆ្នាំថ្មី និងចង់បង្ហាញមុខមាត់ខ្មែរ ជាមួយតម្លៃវប្បធម៌ អរិយធម៌ថ្លៃថ្លារបស់ខ្មែរឱ្យឆាកអន្តរជាតិយល់ដឹងកាន់តែច្បាស់។

ប៉ុន្តែ ប្រសិនបើព្រឹត្តិការណ៍នាថ្ងៃនោះ មានឧបសគ្គមានវត្តមាន លោក សុខ អាន ការសប្បាយរីករាយនឹងជួបនូវការស្រែកប្រឆាំងតវ៉ា ចំពោះលោក សុខ អាន ផងដែរ ហើយអ្នកឱ្យតំលៃខ្មែរទិដ្ឋភាពនៃក្បួនហែពីមតិជនបរទេសនឹងមើលឃើញនូវភាពអៀនខ្មាស និងបាត់សេចក្តីថ្លៃថ្នូររបស់ខ្មែរ នាឱកាសថ្ងៃនោះដែរ ។ គេពុំទាន់ឃើញមានដំណោះស្រាយណាមួយ ដើម្បីធ្វើការរួមជាមួយគ្នា អំពីបញ្ហាប្រឆាំង ចំពោះវត្តមាន សុខ អាន រវាងក្រុមអ្នកដឹកនាំក្រុងខ្មែរ និងក្រុមអ្នកជំទាស់នោះទេ ។ បើទោះបីមានក្រុមនិស្សិតបញ្ញវន្តដែលជំទាស់ធ្លាប់បានចូលរួមប្រជុំប្រចាំសប្តាហ៍ក្នុងការរៀបចំពិធីព្យុហយាត្រាជាច្រើនលើកមកក៏គេពុំទាន់ឃើញមានការយល់ស្របមតិគ្នានៅឡើយនោះទេ ព្រោះក្រុមអតីតនិស្សិត ឬបញ្ញវន្តទាំងនោះ ចង់ស្នើឱ្យមានប្រជាមតិពីប្រជាជនជាសាធារណៈ ប៉ុន្តែច្រានចោលដោយគណៈកម្មការក្រុងខ្មែរ ៕


## Nationwide
## Is on Your Side
## Insurance & Financial Serveice

Nationwide

• ធានារ៉ាប់រងទទួលបន្ទុកខាងពាណិជ្ជកម្ម • ធានារ៉ាប់រងរថយន្ត
• ធានារ៉ាប់រងគេហដ្ឋាន • ធានារ៉ាប់រងជីវិត
• ធានារ៉ាប់រងសុខភាព

- Business Liability Insurance
- Auto Insurance
- Home Insurance
- Life Insurance
- Health Insurance

**យើងនឹងផ្តល់ជូននូវតម្លៃយ៉ាងថោក :**

☞ បញ្ចុះ៣០% ពេលណាដែលលោកអ្នក-អ្នកទិញធានារ៉ាប់រងរថយន្ត និងផ្ទះរួមគ្នា ។

We Offer Cheap Price for Every Client:

☞ Discount 30% When You Purchase Home and Auto Insurance.

## New World Travel II

Công Try Bán Vé Máy Bay Và Cruise

• ជាអ្នកឯកទេសខាងលក់សំបុត្រយន្តហោះសំរាប់ធ្វើដំណើរក្នុង និងក្រៅប្រទេស ។
• យើងតំណាងឱ្យក្រុមហ៊ុនអាកាសចរចិន ឬ កូរ៉េ
• អាចធ្វើ Re-Entry Permit យ៉ាងប្រញាប់ជូន
• រកកន្លែងដំណើរកំសាន្តតាមកប៉ាល់ទឹក. រកសណ្ឋាគារ. រកឡានជួល
• តម្លៃសំបុត្រយន្តហោះយ៉ាងថោក សំរាប់ធ្វើដំណើរទៅគ្រប់ទីកន្លែង

- Specialized in Selling Flight Ticket Both National and International.
- Represented Various of Company Including China, Korea.
- Offer Rush Re-Entry Permit.
- Reserve Cruise, Hotels and Car Rentals.
- Best Price Air Ticket For Many Destinations.

600 Washington Ave Suit #8. Philadelphia, PA 19147
Tel: (215) 463-1257, Fax: (215) 463-2036
6603 Bustleton Ave. Philadelphia, PA 19149
Tel: (215) 335-2140, Fax: (215) 335-2147

# ចិន_យួនដេញខ្មែរ ..

ធ្លាប់បានឮពាក្យចាស់បុរាណតែងនិយាយថា "ចិនដេញខ្មែរ ខ្មែរដេញខ្មោច" ។ ពាក្យនេះពិតជាមានតំលៃគ្រប់សម័យកាល ជាពិសេសនាពេលបច្ចុប្បន្ននេះ ។

អ្នកមានលុយទិញដីភាគច្រើន ជាថៅកែចិនយួន និងអឺរ៉ុប បាននាំគ្នាទិញដីនៅជាប់ផ្លូវថ្នល់ជាតិ



សំណង់ផ្ទះល្វែងរីកច្រើនផ្គាតនៅទីក្រុងភ្នំពេញ

សំរាប់សាងសង់រោងចក្រសំណង់ផ្ទះល្វែង និងទិញទុកសំរាប់លក់យកចំណេញទៅថ្ងៃក្រោយ ។

ចំណែកប្រជាកសិករដែលរស់នៅទីប្រជុំជន និងតំបន់ដាច់ស្រយាលមួយចំនួន ដែលមានជីវភាពខ្សត់ខ្សោយ បានលក់ដីលំនៅដ្ឋាន និងស្រែចំការយកលុយទៅធ្វើដើមទុនរកស៊ី និងទិញសំភារៈប្រើប្រាស់ ។ នៅទីបំផុត ពួកគាត់ទាំងនោះភាគច្រើនផ្ទះក៏អស់ លុយក៏អស់ ហើយនាំគ្នាទៅកាប់ឆ្ការព្រៃ ដែលជាកន្លែងខ្មោច ធ្វើលំនៅដ្ឋានគួរឱ្យខ្លាច ។

នៅទីក្រុងធំៗ ក៏មិនខុសប្លែកពីទីប្រជុំជននានានៅប្រទេសកម្ពុជាទេ ទីទួល បឹងបួ ដែលធ្លាប់តែគ្រប់ដណ្តប់ទៅដោយភក់ជ្រាំ ឬទឹកសំអុយ ត្រូវបានគេចាក់ដីលុបហ៊ុមរបងព័ទ្ធជុំវិញ ឬមានសំណង់ផ្ទះល្វែងព័ទ្ធជុំវិញ ។

ដីនៅតាមផ្លូវជាតិភាគច្រើន សុទ្ធតែមានបង្គោលរបង និងស្លាកលេខទូរស័ព្ទសំរាប់ទាក់ទង ទិញ និងលក់ដីជាស្រេច ។ វាលស្រែភាគច្រើនរបស់អ្នកស្រុក បានក្លាយទៅជាកម្មសិទ្ធិរបស់អ្នកមាននៅទីក្រុងភ្នំពេញ និងនៅក្រៅប្រទេស ។

ដីនៅតាមបណ្តោយផ្លូវជាតិលេខ៤ ពីក្រុងភ្នំពេញឆ្ពោះទៅក្រុងព្រះសីហនុ ក៏មិនខុសប្លែកពីខេត្តក្រុងដទៃដែរ គឺកសិករលក់ដីអស់ហើយ ។ ដោយសារតែដីឡើងថ្លៃ និងតំរូវការគ្រួសារ ហើយពួកគេក្លាយទៅជាអ្នកចាំដីឱ្យពួកថៅកែទាំងនោះទៅវិញ ។

អ្នកស្រី គី សុខ អាយុ៣៥ឆ្នាំ រស់នៅស្រុកអង្គស្នួល ខេត្តកណ្តាល បានឱ្យដឹងថា គាត់បានលក់ដីឱ្យថៅកែអស់ទៅហើយ ប៉ុន្តែ គេជួលគាត់ឱ្យនៅចាំដី និងធ្វើស្រែចិញ្ចឹមជីវិត ។

អ្នកស្រីបន្តថា ការដែលគាត់សុខចិត្តលក់ដីបែបនេះ ដោយសារដីបានថ្លៃ និងតំរូវការគ្រួសារ ដូចជាបង់ថ្លៃសាលារៀនកូន សង់លំនៅដ្ឋាន និងយកលុយកាក់មួយចំនួនទុក ។



សំណង់ផ្ទះល្វែងរបស់ក្រុមហ៊ុនដែលកំពុងសាងសង់នៅជាយក្រុងភ្នំពេញ

លោក សេង តុលា អាយុ៦៤ឆ្នាំ រស់នៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បានឱ្យដឹងថា ដីស្រែរបស់ពួកគាត់បានលក់ឱ្យឈ្មួញក្នុងតំលៃថោក ស្ទើរអស់ទៅហើយ ។ លុយកាក់ដែលលក់បាននោះ គាត់យកទៅទិញសំភារៈផ្សេងៗ ដូចជា ម៉ូតូ ឡាន ទូរស័ព្ទសំរាប់ប្រើប្រាស់ឱ្យបានសប្បាយហ៊ុហារអស់ទៅវិញហើយដែរ ។ សព្វថ្ងៃនៅទីក្រុងភ្នំពេញ និងខេត្តសៀមរាប មានសំណង់រីកលូតលាស់ដូចផ្សិត ផ្ទះថ្មរាប់សិបជាន់ ។ ដីឡើងថ្លៃកប់ពពក នៅទីក្រុងភ្នំពេញ ដីមួយម៉ែត្រការ៉េ កន្លែងខ្លះតំលៃពី១៣០០ ទៅ១៨០០ ដុល្លារ ។ ( តនៅទំព័រទី៣៤ )

ឱសថស្ថានខ្មែរថ្ងៃនេះ
Today Pharmacy
2200 E. Anaheim St.#C Long Bach, CA 90804
Tel: (562) 438-2031 • Fax: (562) 438-2031
(2 Blocks East of Cherry Ave.)
Fast and Friendly Service
- Today Pharmacy គឺជាឱសថស្ថានបំរើការចែកចាយថ្នាំតាមវេជ្ជបញ្ជា ។
- ទទួលយកនៅ Medicare & Medical និង Insurance ។
- ដឹកជញ្ជូនថ្នាំផ្តល់ជូនឲ្យដល់គេហដ្ឋានដោយមិនគិតពីកំរៃផងដែរ ។
• FREE DELIVERY
TODAY:
ថ្ងៃល្អរបស់លោកអ្នក
សូមស្វាគមន៍!

# ស្វែងរកបេក្ខជនប្រធានាធិបតី អាមេរិកាំង២០០៨

***ហ៊ូឡាវែលហ៊ូឃាំ : ពិន សំខុន***

នៅពេលដែលខាងគណបក្សប្រជាធិបតេយ្យមានបេក្ខជនខ្លាំងប្រដេញកិតគ្នារវាង បារ៉ាក់ អូបាម៉ា និង ហ៊ីលឡារី គ្លីងតុន ខាងគណបក្សសាធារណរដ្ឋឯណោះ មានតែបេក្ខជនខ្លាំងតែម្នាក់ទេ គឺលោក ជន ម៉ាកេន តែបេក្ខជនរូបនេះ ទើបនឹងផ្តើមធ្លាយរឿងអាស្រូវមួយកើតឡើង ដែលអាចម៉ាកេន និង នារី វិគី អាយស្មាន បានប្រកែកថាមិនពិត តែសាក្សីមួយចំនួនក្នុងជួរឧបការីលោកម៉ាកេន បានរាយការណ៍ផ្ទុយគ្នា ។ ការចោទប្រកាន់ពីអ្នកកាសែតនោះ សំដៅទៅរកការប្រើឥទ្ធិពលជាសមាជិកព្រឹទ្ធសភារបស់លោក ម៉ាកេន ទៅបំរើទំនាក់ទំនង ដែលហៅថា "សម្ងាត់" នោះ ។ រង់ចាំការវិវត្តន៍នៃករណី "ទំនាក់ទំនងសម្ងាត់"



John Mcaim (Repuplican Party)



Hillary Clinton (Democratic Party)



Obama (Democratic Party)

ឱ្យលោក ម៉ាកេន រលូតបេក្ខភាពប្រធានាធិបតីនេះ ពីដៃខ្លួនបាន ។

លោក ជន ម៉ាកេន បានត្រូវកាសែតនូយ៉កថៃម លើកយករឿងទំនាក់ទំនងសម្ងាត់ និងផ្លូវចិត្តរវាង នារីអាយុ៤០ឆ្នាំម្នាក់ ឈ្មោះ វិគី អាយស្មាន ដែលលោកបានជ្រើសតាំងជាឧបការីខាងទំនាក់ទំនង តាំងពីឆ្នាំ២០០២ មក ។ លោក ជនគណបក្សសាធារណរដ្ឋបានបង្ហាញការទុកចិត្តកាន់តែខ្លាំង ថាលោក ជន ម៉ាកេន នឹងបានក្លាយជាបេក្ខជនប្រធានាធិបតីជាមិនខាន ដោយពិន្ទុដែលលោក ជន ម៉ាកេន ទទួលបាននាថ្ងៃអាទិត្យទី២៤ ខែកុម្ភៈនេះ បានឈ្នះលើបេក្ខជន ម៉ាយហកប៊ី ៥៧% ទល់នឹង ៣៩% ហើយ និងលើ

( តនៅទំព័រទី១៤ )

# ដំណើរមកកាន់ការវះកាត់...

ប្រោសប្រណីដល់ជីវិតសត្វលោកកំពុងតែមានទុក្ខ" ។

អ៊ំស្រីដែលជាអ្នកដំទៃសោះ ហើយស្គាល់តាមរយៈសាច់ថ្លៃនៃអ្នកស្រុកបាត់ដំបងដូចគ្នាបន្តថា "ខ្ញុំរីករាយនឹងឱ្យស្នាក់នៅ និងជួយមើលថែរក្សាព្រោះខ្មែរដូចគ្នា ហើយកុមារីរូបនេះ មានអំណោយទានគួរឱ្យអាណិតអាសូរទៀតផង" ។

ទិដ្ឋភាពក្នុងផ្ទះអ៊ំស្រីនោះ យើងឃើញកុមារីដារិក កំពុងតែផាត់រូបនៅលើសៀវភៅតុក្កតាជាមួយក្មេងខ្មែរ-អាមេរិកាំងពីរនាក់ អាយុ៣-៤ឆ្នាំ ដែលមើលទៅម្នាក់ៗ បាននិយាយរកគ្នាដោយស្តាប់មិនយល់ ដូចនិយាយឱ្យគោស្តាប់ដោយម្ខាងនិយាយអង់គ្លេស រីឯម្ខាងទៀតនិយាយភាសាខ្មែរ ។ ប៉ុន្តែពួកគេទាំងបីនាក់ អាចលេងសើចជាមួយគ្នាបាន ដោយភាពស្និទ្ធស្នាលមិនបង្ហាញទឹកមុខក្រញូវ ឬឈ្លោះគ្នាទេ ។

សៀវភៅមួយក្បាល ពួកគេអាចផាត់ពណ៌បានទាំងបីនាក់ ជាមួយសកម្មភាពដៃកាន់ក្រូចញាំុ នាងនិយាយថា "ខ្ញុំមិនធ្លាប់មានសៀវភៅគំនូរផាត់ពណ៌យ៉ាងដូចនេះទេពីមុន ព្រោះខ្ញុំគ្មានលុយទិញអង្ករច្រកឆ្នាំផង...។ តើមានលុយឯណាដល់ទៅទិញសៀវភៅល្អៗ យកមកមើលមករៀន... គូសលេងយ៉ាងដូច្នេះ" ។

**● នៅភោជនីយដ្ឋានសូភី :**

ការទៅកាន់ទីនោះ ដើម្បីទទួលទានបាយល្ងាច កុមារី ដារិក ដែលអង្គុយនៅចន្លោះកណ្តាលម្តាយ និងបុរសដែលជួយនាងយកមកព្យាបាល និងវះកាត់បេះដូងក្នុងតុបាយ កុមារី ដារិក បានបង្ហាញទឹកមុខស្រស់ថ្លា ញញឹមជាមួយដៃលើកសំពះចំពោះភ្ញៀវ មិនថាខ្មែរ ឬបរទេស ដែលសួរសុខទុក្ខនាង នូវអ្វីដែលភ្ញៀវបានដឹងពីអាការៈរោគនាង ។

ក្បាលរបស់នាងបានផ្អែកទៅនឹងដងខ្លួនរបស់ Peter Chhun មើលទៅទំនងជាឪពុកកូន ដែលផ្ចិតមនោសញ្ចេតនាជាមួយគ្នា ដោយកុមារី ដែលសំដីបានដូចមនុស្សចាស់បង្ហើបវាចាថា "ខ្ញុំមិនដែលជួបប្រទះម្ហូបអាហារច្រើនមុខបែបនេះទេក្រៅតែពី អំបិល ប្រហុក ដែលយូរៗមានសាច់គោ សាច់ជ្រូកម្តង" ។

រីឯម្តាយនាង បានស្រក់ទឹកភ្នែកនៅចំពោះមុខម្ហូបដ៏ច្រើនស្កេកស្កុះនោះ ដែលទឹកភ្នែកនេះបានបង្ហាញពីអតីតកាលរបស់នាង ដែលមានតែបាយ និងអំបិលបុកម្ទេសនោះទេ ក្នុងស្ថានភាពដែលប្តីកំពុងធ្វើបាប និងចុះចោលពីរូបគាត់បាត់ទៅ ខណៈដែលកុមារី ដារិក នៅវ័យអាយុ២ឆ្នាំ ។

លោក Peter Chhun បានប្រាប់ខ្មែរប៉ុស្តិ៍ក្នុងសំដីអួលដើម.កជាមួយការស្រក់ទឹកភ្នែកចំពោះមុខសប្បុរសជន ចូលរួមតុបាយជាមួយបានបង្ហើបថា "ខ្ញុំគ្មានសេចក្តីអរណា ក្រៅពីទឹកចិត្តដែលសម្រេចជួយកុមារីបានដល់ទីបញ្ចប់នៃភាពជោគជ័យរបស់ខ្ញុំយ៉ាងដូច្នេះទេ"។ ទឹកភ្នែកខ្ញុំបានស្រក់ជាប្រចាំស្ទើររហូតដល់អស់ទឹកភ្នែក បន្តយំទៀតហើយ ព្រោះក្តីរំជួលចិត្ត និងការរំភើបបានធ្វើឱ្យខ្ញុំនឹកឃើញកាលវ័យកុមារ ដែលខ្ញុំនៅវ័យកុមារ ( តនៅទំព័រទី៣០ )


BELMONT SHORE TRAVEL
ក្រុមហ៊ុនទេសចរណ៍ និងលក់សំបុត្រយន្តហោះ
● យើងខ្ញុំរីករាយក្នុងការ បំរើសេវាជូន
លោកអ្នកអាចទិញ និង ទទួលសំបុត្រយន្តហោះបានភ្លាមៗមួយរំពេច ។
តម្លៃសំបុត្រទៅកាន់ប្រទេសកម្ពុជា សមរម្យមិនថ្លៃមិនថោក ។
EVA Airline
Cathay pacific Airline
China Airline
ប្រភេទយន្តហោះ Boeing ថ្មីទំនើប , បំរើភ្ញៀវដោយហ្មត់ចត់ ដែលធ្វើឱ្យលោកអ្នកមិនខុសបំណងឡើយ !
បើលោកអ្នកមាន Green Card ហើយ មានអាសន្ន ឬបន្ទាន់ក្នុងករណីណាដែលត្រូវធ្វើដំណើរទៅកាន់ស្រុកខ្មែរ សូមទាក់ទងយើងខ្ញុំ ដោយរង់ចាំតែពីរសប្តាហ៍តែប៉ុណ្ណោះ ។
ក្រុមហ៊ុនយើងខ្ញុំជួយសំរួល និងយកចិត្តទុកដាក់រាល់កិច្ចការដែលទាក់ទងនឹងការធ្វើដំណើរសំរាប់លោកអ្នកប្រកបដោយសុវត្ថិភាពគ្មានការភ័យព្រួយ ។
長榮航空
EVA AIR
777-300ER
ទទួលធ្វើ :
លិខិតឆ្លងដែនខ្មែរបន្តឆ្នាំ
លិខិតឆ្លងដែនខ្មែរ ដែលផុតកំណត់
Cambodia passport ,
Cambodia passport Extension
Notary Public
744 Redondo Ave
Long Beach , CA 90804
1-800 - 732 - 9363
Phone : (562) 439-2129
FAX : (562) 439- 2550
belmontshoretravel@charter.net
www. belmontshoretravel.net
M-F : 9:00AM - 6:00 PM
SAT : 10:00 AM - 4:00PM

## ចង់ឃើញសម្តេចសីហនុ...

អ្នកវិភាគមើលឃើញថា ឥរិយាបថរបស់ថៃ ក្នុងន័យទាមទារចំណែកក្នុងវិស័យទេសចរ ជារឿងធំពីប្រទេសកម្ពុជា ព្រោះមិនមែនមានន័យថា ថៃណាល្ងីពកថ្វាស មិនដឹងពីច្បាប់អន្តរជាតិ ដែលកាត់ឱ្យខ្លួនចាញ់ក្តីនោះទេ ។

កាលឆ្នាំ២០០១ ប្រទេសកម្ពុជា បានស្នើសុំអង្គការយូណេស្កូ ឱ្យដាក់បញ្ចូលប្រាសាព្រះវិហារក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក ដែលការស្នើសុំនោះ មិនមានកាចូលរួមពីភាគីថៃឡើយ ហើយត្រូវបានភាគីថៃធ្វើការជំទាស់ កាលពីឆ្នាំ២០០៧ ។

រដ្ឋាភិបាលកម្ពុជា ធ្លាប់បានធ្វើការប្រឆាំងដាច់ខាត ចំពោះការរាំងខ្ទប់ ក្នុងដំណើរការចុះបញ្ជីប្រាសាទព្រះវិហាររបស់ខ្មែរ ជាបេតិកភ័ណ្ឌពិភពលោក ពីសំណាក់រដ្ឋាភិបាលថៃ ដែលតែងតែសម្តែងភាពមិនសប្បាយចិត្ត នៅពេលកម្ពុជាប្រកាសសម្រេចជាឯកតោភាគី ។

ប្រាសាទព្រះវិហារ គ្រោងនឹងដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក នៅឆ្នាំ២០០៨ ដោយតម្រូវឱ្យកម្ពុជា ពង្រឹងកិច្ចអភិរក្ស និងធ្វើការគ្រប់គ្រងរមណីយដ្ឋានឱ្យមានវឌ្ឍនភាព ។

លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង ធ្លាប់អះអាងថា ការលើកហេតុផលថា ជម្លោះព្រំដែនគ្មានអស្ថេរភាព ជាទឡ្ហីករណ៍ ក្នុងបំណងធ្វើឱ្យរាំងស្ទះដល់ការដាក់បញ្ចូលប្រាសាទព្រះវិហារ ជាបេតិកភ័ណ្ឌពិភពលោកនោះ គឺជាការរំលោភយ៉ាងច្បាស់ក្រឡែត លើសាលក្រមតុលាការអន្តរជាតិ ដែលបានសម្រេចនៅឆ្នាំ១៩៦២ ៕


# ហាងលក់គ្រឿងបន្លាស់រថយន្ត
LONG BEACH AUTO PARTS
Imports & Domestics




សំរាប់អតិថិជនដែលមានបំណងផ្លាស់ប្តូរគ្រឿងបន្លាស់រថយន្ត សូមអញ្ជើញមកជាវគ្រឿងបន្លាស់ហាងយើងខ្ញុំដែលមានច្រើនប្រភេទតាមតម្រូវការរបស់អតិថិជន

1310B Stanley Ave
Long Beach, CA 90804 (562) 433-8090,(562) 433-8093



## TOYOTA OF LONG BEACH

-ត្រូវការជ្រើសរើសអ្នកលក់ឡានចំនួន ៣នាក់ (Sales person) មិនថាប្រុស ឬស្រី ដែលជាជនជាតិខ្មែរ មានស្ទាត់ជំនាញភាសាខ្មែរ និងអង់គ្លេស ។
-មានទំនាក់ទំនងសាធារណៈល្អក្នុងទីផ្សារ និងមហាជននៃសហគមន៍ក្រុង Long Beah និងទីតំបន់ខ្មែរដទៃទៀត ។
-អ្នកលក់ឡាន (Sales Person) ត្រូវទទួលបានភាគរយក្នុងឡានមួយ ៣៥%(Commission) ។
-បើលោកអ្នកមានការចាប់អារម្មណ៍ចង់ធ្វើការជាមួយក្រុមហ៊ុនយើងខ្ញុំ សូមអញ្ជើញទាក់ទងនូវអាស័យដ្ឋានខាងក្រោម :

4401E. Pacific Coast Highway Long Beach, CA 90804
Phone: (562) 494-4444 /Fax: (562) 494-1350


## ស្វែងរកបេក្ខជន...

បេក្ខជនម្នាក់ទៀតឈ្មោះ រ៉ន ផល បាន៦% ។

រីឯខាងគណបក្សប្រជាធិបតេយ្យវិញ បេក្ខជនខ្លាំងទាំងពីរ គឺខាងស្បែកខ្មៅ បារ៉ាក់ អូបាម៉ា កំពុងមានប្រៀបលើលោកស្រី ហ៊ីឡារី គ្លីងតុន ប្រមាណ ១០ពិន្ទុប៉ុណ្ណោះ តែគំលាតអាចនឹងធំឆ្ងាយនៅពេលខាងមុខអ្នកទាំងពីរបានធ្វើការវាយប្រហារដោយសំដីថ្លោស១ដាក់គ្នាទៅវិញទៅមក ដែលគេយល់ថា ពុំមែនជាទម្លាប់របស់គណបក្សប្រជាធិបតេយ្យនោះ ទេ លោក អូបាម៉ា បានបញ្ចេញបទចម្រៀងនៅក្នុងកិច្ចឃោសនារបស់លោកថា "Yes We Can Change" (គេប្រាកដជាអាចផ្លាស់ប្តូរ) ដែលនៅ ក្នុងចម្រៀងនោះមានសុទ្ធតែពាក្យស្លោក ដែលលោកបានថ្លែងសុន្ទរកថាទាំងអស់ ដែលជាហេតុ ធ្វើឱ្យប្រជាប្រិយភាពរបស់លោកកាន់តែឡើង តែ ហ៊ីឡារី វិញ ក៏កាន់តែស្រុតចុះណាស់ដែរ អ្នកវិភាគនិយាយថា លោកស្រីត្រូវយករដ្ឋតិចសាស (Texas) និងអូហាយ្យូ (Ohaio) នៅថ្ងៃអាទិត្យខាងមុខឱ្យបាន ហើយនៅខែមីនាត្រូវយករដ្ឋផែនស៊ីវ៉ាញ៉ា មួយទៀតឱ្យបាន ទើបប្រជាប្រិយភាពឡើងមកតទល់ បារ៉ាក់ អូបាម៉ា វិញបាន ។ រដ្ឋផែនស៊ីវ៉ាញ៉ា បានត្រូវគេមើលឃើញថា ជារដ្ឋគន្លឹះមួយសំរាប់ចង្អុលថា នរណាមួយដែលនឹងក្លាយជាបេក្ខជនប្រធានាធិបតី ខាងគណបក្សប្រជាធិបតេយ្យបាន ។

រួមសេចក្តីទៅ បើយោងទៅតាមទស្សនៈនយោបាយសប្តាហ៍នេះ គេយល់ថា មានបេក្ខជនប្រធានាធិបតីរួចហើយ គឺ ជន ម៉ាកេន គណបក្សសាធារណរដ្ឋ និងជួបប្រកួតជាមួយនឹង បារ៉ាក់ អូបាម៉ា នាខែវិច្ឆិកា ខាងមុខនោះហើយ ។ នេះគ្រាន់តែជាការស្រម័យទេ រីឯការពិតនោះ នឹងមានកត្តាថ្មី១ ដែលអាចផ្លាស់ប្តូរដំណើរវិវត្តន៍របស់ការបោះឆ្នោតនោះបានដែរនៅឡើយ ។

សហគមន៍អាស៊ី ដែលបានមករស់ជ្រកកោននៅសហរដ្ឋអាមេរិកប្រមាណ៣០ឆ្នាំ ហើយក៏មានប្រជាជនច្រើនគ្រប់គ្រាន់សម្រាប់ធ្វើនយោបាយ ដូចគេឯងដែរ តែសហគមន៍នេះ មិនចុះសម្រុងគ្នាទេ ។ រីឯខ្មែរយើងវិញ មិនត្រឹមតែបែកបាក់គ្នាទេ ថែមទាំងមិនចង់ដឹងចង់ឮពីនយោបាយថែមទៀត មកទល់ពេលនេះ គេនៅពុំទាន់មានឃើញខ្មែរចេញមុខទៅគាំទ្របេក្ខជនណាមួយនៅឡើយទេ ៕


# វិមានមាស ភោជនីយដ្ឋាន និង រង្គសាល

1360 E , Anaheim St., Long Beach, CA 90813
Tel: (562) 591-7300 Fax: (562) 591-7331
Mon., Wed., Thu, 10AM- 10PM
Fri, Sat, Sun, 9 AM -2 AM (LIVE ! BAND )
Tuesday (Closed)



សូមអញ្ជើញភ្ញៀវសជាតិម្ហូប ខ្មែរ ថៃ នៅភោជនីយដ្ឋាន **វិមានមាស** ដែលបានបើកទ្វារបំរើអស់លោកអ្នក ចាប់តាំងពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នេះហើយ !!!




ចំណែកឯរង្គសាល **វិមានមាស** ក៏បានបើកទ្វារបំរើអស់លោកអ្នក រាំកំសាន្តជាមួយក្រុមតន្ត្រី **វិមានមាស** រៀងរាល់ចុងសប្តាហ៍ ចាប់ពីថ្ងៃ សុក្រ រហូតដល់ថ្ងៃ អាទិត្យ

ភោជនីយដ្ឋាន និង រង្គសាល វិមានមាស មាន ទទួលសំអាងការ ទទួលរៀបអាពាហ៍ពិពាហ៍ បុណ្យខួបកំណើត និង ពិធីជប់លៀងផ្សេងៗ...

## អ្នកនយោបាយផ្លាស់ប្តូរ...

សក្ការៈនៅពេលបច្ចុប្បន្ន និងទៅអនាគត ។

នៅប្រទេសកម្ពុជាមានកត្តាជាច្រើន ដែលជំរុញឱ្យមានគណបក្ស និងអ្នកនយោបាយប្លែកៗ គិតមិនសូវចុះសំរុងគ្នាខាងទស្សនៈ ។ ដូច្នេះ ការចាកចេញពីគណបក្សមួយទៅគណបក្សមួយ ដើម្បីទៅ



លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី

បង្កើតបក្សមួយទៀត វាស៊ើរតែក្លាយទៅជាទំនៀមទំលាប់ប្រពៃណីទៅហើយ ដែលកើតមានជាញឹកញាប់ ។

ជាឧទាហរណ៍នៅឆ្នាំ១៩៩៥ លោក សម រង្ស៊ី បានចាកចេញពីគណបក្សហ៊្វុនស៊ិនប៉ិច ហើយទៅបង្កើតគណបក្សជាតិខ្មែរ ។ ក្រោយមកលោក ងួន សឿ និងលោក គង់ មុនី បានដណ្តើមយកបក្សនេះ ។

ចំណែកលោក សម រង្ស៊ី បានបង្កើតបក្សថ្មីដាក់ឈ្មោះគណបក្ស សម រង្ស៊ី ។ រីឯសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានសមាជបណ្តេញចេញពីបក្ស ហើយព្រះអង្គបានទៅបង្កើតគណបក្ស នរោត្តម រណឫទ្ធិ ដើម្បីចូលរួមការបោះឆ្នោតឃុំ-សង្កាត់ ឆ្នាំ ២០០៧ និងតំណាងរាស្ត្រថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ។

ថ្មីៗនេះលោក កឹម សុខា បានចាកចេញពីគណ-បក្សហ៊្វុនស៊ិនប៉ិច ទៅបង្កើតអង្គការសិទ្ធិមនុស្ស ហើយ ក្រោយមកបានទៅបង្កើតគណបក្សសិទ្ធិមនុស្ស ។ ពេលនេះ គណបក្សនេះកំពុងតែទទួលការទាក់ទាញប្រជាពលរដ្ឋយ៉ាងខ្លាំង ហើយសង្ឃឹមថា អាចដណ្តើមបានអាសនៈក្នុងរដ្ឋសភា ដើម្បីដឹកនាំរដ្ឋាភិបាល ។

រឿងដែលគួរឱ្យចម្លែកនោះ នៅស្រុកខ្មែរអ្នកនយោបាយទាំងនៅជាយដែន និងក្នុងស្រុកមិនថាក្មេង ឬចាស់ទេ គឺពួកគេ ដែលធ្លាប់តែប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជានោះ ។ ពេលនេះ ពួកគេទាំងនោះបែរជាក្បត់នឹងឧត្តមគតិ ដែលធ្លាប់មាន និងធ្លាប់បានឃោសនាប្រាប់ប្រជាពលរដ្ឋ ហើយទៅចុះចូលនឹងគណបក្សប្រជាជនកម្ពុជា ។ ដោយទទួលបានមុខនាទីមុខតំណែងជារដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាល ហើយចោទគណបក្សចាស់ដែលធ្លាប់រស់នៅជាមួយគ្នាថា "ពុករលួយ" បក្ខពួក និយមលុយកាក់ និងខ្វះសមត្ថភាព" ទៅវិញ ។

កាលពីដើមខែមករា ឆ្នាំ២០០៨ នេះ សមាជិកជាន់ខ្ពស់នៃគណបក្សហ៊្វុនស៊ិនប៉ិច ប្រមាណ១០ រូប និងមន្ត្រីថ្នាក់ក្រោមៗ បានដើរចេញពីបក្សទៅរួមជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីរក្សាមុខនាទីរបស់ខ្លួន ។

អតីតអ្នករាជានិយមលោក លី ធុច អនុប្រធានគណៈកម្មាធិការរៀបចំការបោះឆ្នោត, លោក គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ច-ការនារី, លោក ឈា ប៉េងឈាង រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក ម៉ៅ ហាវ៉ាន់ ណាល់ រដ្ឋលេខាធិការអាកាសចរណ៍ស៊ីវិល ។

អ្នកនយោបាយទាំងនេះបានអះអាងថា ពួកគេចាកចេញពីហ៊្វុនស៊ិនប៉ិច ដោយសារភាពទន់ខ្សោយក្នុងការដឹកនាំរបស់បក្ស ។ ទោះជាយ៉ាងនេះ មេដឹកនាំបក្សបានច្រានចោលនូវហេតុផលរបស់ពួកគេ ហើយបានថ្លែងថា ពួកដែលចាកចេញពីបក្សទាំងនោះ គឺជាក្រុមឱកាសនិយម ។

លោក គឹម វ៉េន ទីប្រឹក្សារបស់ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច បានអះអាងថា ការផ្លាស់ប្តូរគណបក្សរបស់មន្ត្រីទាំងនេះ ធ្វើឡើងពីផលប្រយោជន៍សុទ្ធសាធ ។

ចំណែកគណបក្ស សម រង្ស៊ី ដែលជាគណបក្សប្រឆាំងនាំមុខគេក្នុងប្រទេស ដែលជាក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋអាចដណ្តើមបានជ័យជំនះនោះ ។ នាពេលនេះ អ្នកនយោបាយមួយចំនួនបានចាកចេញពីបក្ស ដើម្បីស្វែងរកតួនាទី និងលាភសក្ការៈ ហើយចោទបក្សរបស់ខ្លួនថា បក្ខពួកទៅវិញ ។

រហូតមកដល់ពេលនេះ មានមន្ត្រីសំខាន់ៗ របស់គណបក្ស សម រង្ស៊ី ទៅចុះចូលជាមួយគណ-បក្សប្រជាជនកម្ពុជា រួមមាន : លោក លន់ ភុន តំណាងរាស្ត្រមណ្ឌលបាត់ដំបង, លោក កឹង ម៉ៅ សមាជិក គណៈកម្មាធិការនាយក, លោក លី ឈុង គណៈកម្មាធិការនាយក, លោក មុំ ប៊ុនថន បេសកជន លោក សម រង្ស៊ី, លោក ឡេង តេង សមាជិកគណៈកម្មាធិការនាយក, លោក គៀង វ៉ាង តំណាងរាស្ត្រមណ្ឌលកំពត, លោក ង៉ោ សុវណ្ណ តំណាងរាស្ត្រមណ្ឌលកណ្តាល, លោក សុខ ផេង តំណាងរាស្ត្រមណ្ឌលកំពង់ធំ និងលោក អះម៉ាត់ អះយ៉ាយ៉ា តំណាងរាស្ត្រមណ្ឌលកំពង់ចាម ព្រមទាំងមន្ត្រីមួយចំនួនទៀត ។

អ្នកចុះចូលទាំងនោះ សុទ្ធតែបានអំណាចបុណ្យស័ក្តិ ហើយត្រូវបានលោក ហ៊ុន សែន ចេញមុខការពារថែមទៀត ។

លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងបានបញ្ជាក់ថា អ្នកដែលចុះចូលជាមួយគណបក្សប្រជាជនកម្ពុជាបានបោះបង់មនសិការរបស់ពួកគេ ហើយបានបង្ហាញ

( តទៅទំព័រទី៣១ )

## ជួបអ្នកនិពន្ធបទ...

គ្មានអ្នកណាមួយមិនដឹង មិនឮនោះទេ ចំពោះមនុស្សវ័យចាប់ពីអាយុជាង៣០ឆ្នាំឡើងទៅ ពិសេសបងប្អូនជនភៀសខ្លួនខ្មែរ ដែលមានជីវិតអតីតកាលជូរចត់រត់លូនឆ្លងកាត់គ្រាប់រំសេវក្នុងភ្នក់ភ្លើងសង្គ្រាម ព្រោះតែបំណងប្រាថ្នារកសេចក្តីសុខ និងការរស់រានមានជីវិតក្នុងសន្តិភាព ។



ឆាន ឈូ រំលឹកពីអតីតកាលជាអ្នកស្រែចំការ



ឆាន ឈូ នៅក្នុងចំការរបស់គាត់នាខេត្តបាត់ដំបង

បទនេះ បានបង្កប់នូវអត្ថន័យ និងអត្ថរស ចំពោះបេះដូងនៃយើងរាល់គ្នាជាខ្មែរ ជាពិសេសបងប្អូនដែលចំណាកស្រុករស់នៅក្រៅប្រទេស ដូចជាខ្មែរ-អាមេរិកាំង ។ ពួកគេតែងតែស្រមៃ និងនឹកគិតដល់ស្រុកទេសនៃមាតុភូមិកំណើតរបស់ខ្លួន បន្ទាប់ពីបានស្តាប់នូវបទចម្រៀងមួយបទក្រោមចំណងជើងថា "**ស្រណោះដីខ្មែរ**" ។

វគ្គទី២ ដែលបានបង្ហាញនូវឃ្លាឃ្លោងថា ស្រណោះដីខ្មែរដីស្រែចំការ... ចិត្តខ្ញុំស្នេហាគ្មានភ្លេចឡើយ... បើសិនបានរួមរស់កៀកកើយ... ជីវិតខ្ញុំអើយម្ល៉េះសែនរីករាយ ។ តែកម្មអកុសលផ្តល់អប្បលក្ខណ៍... ឱ្យខ្ញុំបែកបាក់ពីគ្រួសារ ម៉ែឪ បងប្អូន ជីដូនជីតា... ព្រាត់ទាំងសង្សារស្នេហ៍ស្មើជីវិត ។

ក្នុងន័យនេះ អ្នកនិពន្ធចង់បញ្ជាក់ពីការឆ្លុះបញ្ចាំងក្នុងប្រវត្តិសាស្ត្រពិតៗ នៅកម្ពុជា ដែលសង្គមខ្មែរយើងរស់នៅក្រោមឥទ្ធិពលអ្នកដឹកនាំ និងសំពាធនយោបាយពីប្រទេសជិតខាង មិនថា ចិន-យួន-អាមេរិក ក្នុងសម័យសង្គ្រាមឥណ្ឌូចិន នា-ទសវត្សរ៍ឆ្នាំ៦០ និង៧០ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភ្លើងសង្គ្រាម ដែលបណ្តាលឱ្យប្រទេសត្រូវខ្ទេចខ្ទីអន្តរាយ ធ្លាក់ដុនដាប រហូតស្ទើររលាយប្រទេសទាំងមូល នៅក្រោមរបបខ្មែរក្រហម ដែលបានកាប់សម្លាប់មនុស្សស្ទើរផុតពូជសាសន៍ និងវប្បធម៌ជាខ្មែរអង្គរ បន្តរហូតមានជនបរទេសជាយួនចូលត្រួតត្រាប្រទេសកម្ពុជា ។

តរហូតមកទៀត ដែលអ្នកនិពន្ធបទចម្រៀងនេះ គឺជាជនចំណាកស្រុកម្នាក់មិនចង់ឃ្លាតពីស្រុកកំណើតជាអ្នកស្រែចំការ ដែលសប្បាយនឹងកំណើតជាតិខ្លួនជាមួយស្រែចំការ ម្ហូបក្តាមខ្យង និងការបង្ហើរ អារម្មណ៍ជាមួយទេសភាពវាលស្រែ រុក្ខជាតិស្រស់បំព្រង ពណ៌បៃតងក្នុងការកៀកកើយជាមួយគូស្នេហ៍ ឬការរស់ជួបជុំជាមួយបងប្អូនឪពុកម្តាយ ជីដូនជីតា ។

ខណៈដែលខ្លួនឃ្លាតចាកចោលស្រុកមករស់នៅលើទឹកដីគេ មិនជារឿងងាយស្រួលប៉ុន្មានទេ ក្រោមការតស៊ូប្រឹងប្រែងក្នុងឆាកជីវិត និងស្ថិតក្នុងការមើលងាយមើលថោកពីសាសន៍ជាតិដទៃទៀតនោះ ។

( តទៅទំព័រទី ៣៣ )

មន្ទីរពេទ្យគីតា ផេង
Khemara Family Medical Group
OPEN: Mon.-Fri. 9am - 5pm • Sat 9am - 1pm
❖ ពិនិត្យជម្ងឺទូទៅ ជាពិសេសរោគមនុស្សចាស់ៗ
❖ ចាក់ថ្នាំការពារចូលរៀន
❖ ទៅមើលថែរក្សាអ្នកជម្ងឺដល់មន្ទីរពេទ្យ និងទៅដល់ផ្ទះ
Pacific Hospital
L.B Memorial
1533 Alamitos Ave.,#B ▪ Long Beach, CA 90813
Tel: (562) 218-5350 ▪ Fax : (562) 218-1630

# ទំព័រហ្វីឡាដែលហ្វីយ៉ា

នាទី ប្រវត្តិសាស្ត្រ

## ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

***តពីលេខមុន***

**ឆ្នាំ១៩៥០**

ថ្ងៃ១៤មករា ប្រធានរដ្ឋសភាជាតិ លោក អៀវ កើស បានត្រូវជនមិនស្គាល់មុខលបធ្វើឃាតដោយការគប់គ្រាប់បែក ។

ថ្ងៃ១០ មិនា មានការបះបោរដ៏សំខាន់មួយនៅ "ជុប" ។

ថ្ងៃ១២-២២មិនា ជួបប្រជុំជាសន្និបាតនៅហាទៀង វៀតណាមខាងត្បូង រវាងបក្សកុម្មុយនិស្តខ្មែរដឹកនាំដោយ សឺង ង៉ុកមិញ និងបក្សកុម្មុយនិស្តវៀតណាម ដឹកនាំដោយ ឡេឌឹកថូ ។

ថ្ងៃ១៧-១៩មេសា ចលនាឥស្សរៈមួយបានបង្កើតឡើងដោយ សឺង ង៉ុកមិញ នៅកំពង់សោមលើមានឈ្មោះថា "រណសិរ្សរួបរួមឥស្សរៈ" ចលនានេះ បានតែងតាំងរដ្ឋាភិបាលបណ្ដោះអាសន្នមួយសម្រាប់រំដោះជាតិ ដែលមានរស់សម័យជាអនុប្រធាន សៀវ ហេង ជារដ្ឋមន្ត្រីការពារជាតិ , ទូ សាមុត ជាអនុប្រធាន, សឺង ភឿករតនា និងនងសួន ។ នៅក្នុងកិច្ចប្រជុំសន្និបាត ដែលមានមនុស្សជាង២០០នាក់ ចូលរួម មានព្រះសង្ឃ១០៥អង្គនៅពេលនោះ មានការបង្ហាញទង់ជ័យសញ្ញាបក្សពណ៌ក្រហម ហើយមានអង្គរវត្តកំពូល៥ ពណ៌លឿង ប៉ាក់នៅចំកណ្ដាល ។

ថ្ងៃទី៣ ឧសភា រដ្ឋាភិបាលថ្មី ដឹកនាំដោយព្រះមហាក្សត្រ នរោត្តម សីហនុ ។

**៨-រដ្ឋាភិបាលនរោត្តម សីហនុ (៣-៥-១៩៥០-៣១-៥-១៩៥០) :**

-នាយករដ្ឋមន្ត្រី : នរោត្តម សីហនុ
-ទេសរដ្ឋមន្ត្រី : តាន់ ម៉ៅ
-ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : ប៉ែន នុត
-រដ្ឋមន្ត្រីការបរទេសសាធារណការ និងគមនាគមន៍ : សុន ម៉ម
-រដ្ឋមន្ត្រីមហាផ្ទៃ : យិត ស្រុន
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ធូ ឈីន
-រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ : ឃួន ណៃ
-រដ្ឋមន្ត្រីយុត្តិធម៌ : ច័ន្ទ ណាក
-រដ្ឋមន្ត្រីអប់រំជាតិ : ពីទូដីម៉ុងតេរ៉ូ
-រដ្ឋមន្ត្រីសាធារណសុខាភិបាល-ការងារ និងសង្គមកិច្ច : នាល ផ្លែង
-រដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ : អ៊ិន ង៉ិន

ថ្ងៃទី០១ ខែមិថុនា ប្តូររដ្ឋាភិបាលថ្មីដឹកនាំដោយទ្រង់ ស៊ីសុវត្ថ មុនីវង្ស :

**៩-រដ្ឋាភិបាលស៊ីវត្ថ មុនីវង្ស (១៦-៦-១៩៥០ - ៣១-១២-១៩៥០) :**

-នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីមហាផ្ទៃ និងព័ត៌មាន : ស៊ីសុវត្ថ មុនីវង្ស
-រដ្ឋមន្ត្រីកិច្ចការសេដ្ឋកិច្ច និងផែនការ : រ៉ាយ លុត
-រដ្ឋមន្ត្រីការពារជាតិ : សុន វ៉ិនសៃ
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : អ៊ូ ឈីន
-រដ្ឋមន្ត្រីយុត្តិធម៌ : ច័ន្ទ ណាក
-រដ្ឋមន្ត្រីសុខាភិបាល និងសង្គមកិច្ច : នាល ផ្លែង
-រដ្ឋមន្ត្រីធម្មការ និងវិចិត្រសិល្បៈ : មាស ហ៊ែល
-រដ្ឋមន្ត្រីការបរទេស : សឺន សាន
-រដ្ឋមន្ត្រីឧស្សាហកម្ម និងពាណិជ្ជកម្ម : ទឹម កេន
-រដ្ឋមន្ត្រីអប់រំជាតិ និងយុវជន : ពីទូដីម៉ុងតេរ៉ូ
-រដ្ឋមន្ត្រីកសិកម្ម និងចិញ្ចឹមសត្វ : ឃួន ណៃ

ថ្ងៃទី១៩ មិថុនា ចលនារំដោះជាតិ សឺង ង៉ុកមិញ ផ្សាយថា ខ្លួនត្រួតត្រានៅលើកម្ពុជាបាន១ភាគបី ហើយប្រកាសឯករាជ្យនៃកម្ពុជាចេញពីបារាំង ។ នៅប្រទេសបារាំងឯណោះ ចលនាកុម្មុយនិស្តម៉ាស៊ីសប្រមូលបាន អៀង សារី, ខៀវ ធីរិទ្ធ, ហ៊ូ យុន, កេង វ៉ាន់សាក់, ជួង មុំ, សាឡុតស, មុី ម៉ន, មុី ផាត, រ័ត្ន សំអឿន ។ ចលនានេះប្រយុទ្ធដើម្បីទស្សនៈជាតិនិយម និងទស្សនៈប្រឆាំងរាជានិយមរបស់ពួកគេ ច្រើនជាងទស្សនៈសង្គមនិយម ។ បន្ទាប់ពី សាឡុតស បានត្រឡប់មកកម្ពុជាវិញ ទើបគេឃើញ កែវ មាស, ខៀវ សំផន ចូលរួមដែរ ។

ថ្ងៃទី ១៤ តុលា កម្ពុជាបានចុះហត្ថលេខាចូលរួមជាមួយអង្គការសហប្រជាជាតិ ក្នុងការទប់ស្កាត់ និងប្រឆាំងអំពើសម្លាប់រង្គាល ។

ថ្ងៃទី ០១ វិច្ឆិកា វ៉ាន់ ម៉ូលីវ៉ាន់ ឡើងជាប្រធានសមាគមនិស្សិតខ្មែរ នៅប្រទេសបារាំង ។

ថ្ងៃទី ២២ វិច្ឆិកា ជំនួបរវាងតំណាងបក្សកុម្មុយនិស្តខ្មែរ សៀវ ហេង ជាមួយតំណាងបក្សកុម្មុយនិស្តឡាវ គីទ្រង់ សុផានុវង្ស និងតំណាងបក្សកុម្មុយនិស្តយួន តុង ឌិកត្រាង ដើម្បីកែទម្រង់បក្សកុម្មុយនិស្តឥណ្ឌូចិន ឱ្យមានទំនាក់ទំនងជិតស្និត ថ្វីត្បិតឯករាជ្យតែរៀង១ខ្លួន ។

**ឆ្នាំ១៩៥១**

ថ្ងៃទី ០១ មករា រដ្ឋាភិបាលថ្មីមួយទៀត ដឹកនាំដោយទ្រង់ ស៊ីសុវត្ថ មុនីពង្ស ដដែល ។

**១០-រដ្ឋាភិបាលស៊ីសុវត្ថ មុនីពង្ស (១.១.១៩៥១-១.៣.១៩៥១) :**

-នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសុខាភិបាល ការងារ និងសង្គមកិច្ច : ស៊ីសុវត្ថ មុនីពង្ស
-រដ្ឋមន្ត្រីកសិកម្ម និងចិញ្ចឹមសត្វ : ឃួន ណៃ
-រដ្ឋមន្ត្រីយុត្តិធម៌ : ពីទូដីម៉ុងតេរ៉ូ

**តទៅលេខក្រោយ**

នាទី ព្រះពុទ្ធសាសនា

## អត្ថបទស្តីអំពីខន្ធ៥ និងសមាធិវិបស្សនា

***ដោយ : ម៉ៅ ច័ន្ទសំណុំ***

អត្ថបទសាសនាខ្លះចែងថា គេប្រៀបធៀបគំនរកម្មនេះ ជាស្នាមគំនូសពីអតីតកាល ស្នាមលើទឹក ស្នាមលើខ្សាច់ ស្នាមលើថ្ម ។ តើស្នាម ឬកម្មយ៉ាងណា ?

**ស្នាមលើទឹក** : មានន័យថា សកម្មភាពណាមួយដែលមនុស្សធ្វើទៅហើយ គ្មានស្នាមក្នុងខន្ធសញ្ញារលប់បាត់ភ្លាម១ ក្រោយពេលប្រព្រឹត្តិចប់ ។ ឧទាហរណ៍ ខ្ញុំទទួលបានបាយព្រឹកនេះ ដល់យប់ឡើងខ្ញុំពុំចាំអ្វីទាំងអស់ អំពីការទទួលបាយពីព្រឹក ។

**ស្នាមលើខ្សាច់** : សកម្មភាពណាដដែល១ ឡើង៤-៥ដង ហើយមានចេតនាចូលរួមផង ។ អ្វីដែលមនុស្សធ្វើម្តង សញ្ញាខន្ធកត់ត្រាម្តង ហើយកត់ត្រាទាំងប្រតិកម្មទៀតផង លើកទី២ លើកទី៣ លើកទី៤ លើកទី៥ ក៏ដូច្នោះដែរ ។ ការកត់ត្រាបែបនេះតទៅ យូរទៅ ទៅជាគំនរនៅក្នុងខ្លួនមនុស្សយើងម្នាក់១ (ទំលាប់) ។ ឧទាហរណ៍ ខ្ញុំលេងឆ្នោតលើកទី១ត្រូវបាន៥ដុល្លារ ប្រតិកម្មសង្ខារសប្បាយ លើកទី២ត្រូវ១០០ដុល្លារ សប្បាយណាស់ លើកទី៣ខុស ខកចិត្ត លើកទី៤ត្រូវ២០ដុល្លារ ត្រូវ... គំនរក្នុងសញ្ញាខន្ធកើតឡើងហើយ ។

អត្ថបទខន្ធប្រាំនេះ ជាអត្ថបទបន្តពីវិបស្សនាមុន ដែលខ្ញុំបានសរសេរកាលពីលេខមុន១ ខ្ញុំបានលើកការប្រណិបត្តិវិបស្សនា ក្នុងន័យបង្ហាញអ្វីដែលខ្ញុំបានទទួលដោយផ្ទាល់ ជាការពិសោធន៍បានដឹងផ្ទាល់អ្នកអនុវត្តន៍នូវបច្ចេកវិជ្ជារបស់ព្រះពុទ្ធ ។ គឺជាអត្ថបទស្តីអំពីរង្វាន់ ដែលខ្ញុំទទួលបានក្នុងនាម នៃអ្នកដែលពុំដែលពឹងផ្អែកអ្វីទៅលើវត្ថុអច្ឆរិយៈ ដើម្បីជាជំនួយក្នុងការស្វែងរកភាពជោគជ័យអ្វីមួយ ក្នុងជីវិតអ្វីតិចតួចឡើយ ។ ហើយជាបន្តទៅទៀតនេះ ជាអត្ថបទសរសេរដោយស្នេហម្នាក់ទៀត ដែលមានលក្ខណៈស្រដៀងគ្នា តែជាមនុស្សស្វែងរករំដោះទុក្ខ ដែលបានកើតដល់ខ្លួនតែដោះមិនបានមុនពេលដែលបានជួបព្រះធម៌ ។ មនុស្សនោះពុំមែនជាអាចារ្យវត្ត ឬគ្រូសាលាបាលីណាមួយនោះទេ តែបទពិសោធន៍ទើបតែប៉ុន្មានឆ្នាំប៉ុណ្ណោះ អនុញ្ញាត្តិឱ្យមនុស្សនោះ អាចនិយាយពីខន្ធប្រាំរបស់មនុស្សលោកបានយ៉ាងជ្រៅជ្រះ ។ មនុស្សនោះឈ្មោះ ម៉ៅ ច័ន្ទសំណុំ ជាពាណិជ្ជករតូចតាចមួយរស់រនៅហ្វីឡាដែលហ្វីយ៉ា ។

តែមុននឹងអញ្ជើញចាប់អារម្មណ៍ទៅលើអត្ថបទអ្នកនិពន្ធ ម៉ៅ ច័ន្ទសំណុំ ជាបន្តទៅទៀតខ្ញុំសូមជម្រាបថា នៅពេលចុងបញ្ចប់អត្ថបទរបស់លោក ច័ន្ទ សំណុំ ទៅ ខ្ញុំនឹងត្រឡប់មកវិញ ដើម្បីបន្តជូនសក្ខីកម្ម ដែលសហរដ្ឋអាមេរិក និងប្រទេសឥណ្ឌាបានយកបច្ចេកវិជ្ជារបស់ព្រះពុទ្ធសមណគោត្តម ទៅអនុវត្តន៍ ដើម្បីកាត់បន្ថយឧក្រិដ្ឋកម្ម និងភាពអវិជ្ជារបស់មនុស្សរបៀបណា ?

ម្យ៉ាងទៀត រៀមច្បងនៃវិបស្សនា តែងនិយាយថា "វិបស្សនា" ជាសិល្បៈនៃការរស់នៅ ហើយក៏ជាសិល្បៈនៃការស្លាប់ដែរ ។ កាលពីថ្ងៃអង្គារ ទី៨ មករា ២០០៨នេះ សមាជិកសំខាន់ម្នាក់នៃសិស្សវិបស្សនានៅប្រទេសបារាំង បាននាំក្រុមគ្រួសារចូលមរណភាព ដោយអាគារពាទ្យ ដោយពុំមានអាការៈឈឺចាប់ ដូចអ្នកជម្ងឺដទៃទៀតណាមួយឡើយ ។ នេះជាសេចក្តីជូនដំណឹងរបស់គ្រួសារសិស្សវិបស្សនា គួច សុម៉ាលី ។

ដុះទំលាប់ ហាក់មានអ្វីមួយប្រាប់ពីក្នុងមកថា កុំនៅស្ងៀមទៅលេងឆ្នោតទៅ ! (នេះហើយជាគូកម្ម) ខ្ញុំរសាប់រសល់នៅមិនសុខ ដូចជាចង់ទៅលេងឆ្នោត ។ ដោយមានមូលហេតុណាមួយ ដូចជា ត្រូវរវល់ខ្លាំងពេក ធ្វើឱ្យខ្ញុំអាកខានពុំបានទៅលេងឆ្នោតទៀត ១ខែ ២ខែ ១ឆ្នាំ ២ឆ្នាំ... ភាពរសាប់រសល់ ចង់ទៅលេងឆ្នោតក៏រលប់បាត់ទៅ (នេះ គឺជាស្នាមលើខ្សាច់) ។

ស្នាមលើថ្ម សកម្មភាពដដែល១ ជាច្រើនដងរាប់ឆ្នាំ ឬក៏សឹងពាក់កណ្តាលអាយុជីវិតមនុស្ស ហើយក្នុងនោះមានចេតនាឱ្យផង ។ នោះសញ្ញាខន្ធបានកត់ត្រាជានិច្ច ទាំងសកម្មភាព និងប្រតិកម្មដដែល១ យូរ១ទៅក្លាយជាទំលាប់ ទៅជាកម្លាំងជំរុញពីខាងមុខ យ៉ាងខ្លាំងក្លា ក្លាយទៅជាកម្លាំងប្រព័ន្ធប្រតិកម្មហួសពីការគ្រប់គ្រងរបស់មនុស្សម្ចាស់ខ្លួន (ញៀន) ។

ឧទាហរណ៍១ : ការជក់បារីរាល់ថ្ងៃ ប្រតិកម្មឆ្ងាញ់ស្រួលខ្លួន បាត់ជូរមាត់រាប់ឆ្នាំ... ទៅទីណាក៏នឹកតែបារីដែរ (ញៀន) ពិបាកកែ ពិបាកបញ្ឈប់ណាស់ស្នាមលើថ្ម ។

ឧទាហរណ៍ទី២: មនុស្សរស់នៅក្នុងទុក្ខភ័យ ដូចជាស្ថានភាពសង្គ្រាម គេឃើញតែការកាប់សម្លាប់ ការអត់ឃ្លាន ភ័យតក់ស្លុត កេងប្រវ័ញ្ចលួចឆក់ប្លន់ ជីវិតរស់នៅក្រោមច្បាប់ព្រៃជាច្រើនឆ្នាំទៅ ទាំងអស់នេះក្លាយទៅជាគំនរប្រព័ន្ធសង្ខារមួយ គឺការភ័យតក់ស្លុត ។ ជននេះដើររទៅណា ទឹកមុខព្រួយជាប់ ភ័យជាប់ គ្រាន់តែឮអ្វីក្តុងសឹងតែដួលផ្ងារក្នុងជីវិតជននេះ ត្រាំក្នុងទុកព្រួយរហូត... ព្រោះប្រព័ន្ធសង្ខារក្លាយទៅជាគំនូសលើថ្ម (ប្រព័ន្ធសង្ខារនេះបានគ្រប់គ្រងជននេះទាំងស្រុង) ។

ពាក្យខ្មែរ : កុំពត់ស្រឡៅ កុំប្រដៅមនុស្សខូចឆ្អែកន្ទុយក្មេងពុំអាចពត់បាន តាមគម្ពីព្រះពុទ្ធសាសនា ប្រព័ន្ធប្រតិកម្ម ឬកម្ម ឬ សង្ខារខន្ធពុំមែនទើបតែកើតមាននៅជាតិនេះទេ ។ គឺមានបន្តពីជាតិមុខ១មក ។ គេតែងប្រទះឃើញក្មេងខ្លះទើបតែដឹងក្តី មានភាពរីករាយចម្លែក ឬតក់ម៉ក់ចូលចិត្តសិល្បៈ ចូលចិត្តរូបព្រះពុទ្ធ ឬចង់តែធ្វើអំពើបាប ចំណូលចិត្តទាំងនោះមានតាំងពីជាតិមុខមក។

មនុស្សម្នាក់១សុទ្ធតែមានប្រព័ន្ធប្រតិកម្ម ឬសំពាយកម្មផ្សេង១គ្នា ពុំមាននរណាចៀសរួចឡើយ ។

**តទៅលេខក្រោយ**




# ផ្ញើប្រាក់ទៅកាន់ខេត្តណាមួយនៅកម្ពុជា តាមរយៈ Western Union

## ជាមួយថ្លៃ* សេវាកម្មផ្ញើប្រាក់ទាប $11.99 ដុល្លារ

សម្រាប់ការផ្ញើប្រាក់ទៅកាន់ខេត្តក្រុង** ដែលបានជ្រើសរើសក្នុងចំនួនតិចជាង 500 ដុល្លារ

## ជាទូទៅប្រាក់អាចទទួលបានតែប៉ុន្មាននាទី*** ប៉ុណ្ណោះ

- ✓ ថ្លៃ* សេវាកម្មផ្ញើប្រាក់មិនមានការប្រែប្រួលទៅតាមទីកន្លែងរបស់ភ្នាក់ងារទទួលប្រាក់ឡើយ
- ✓ មានភ្នាក់ងារផ្ទេរប្រាក់ជាង 100 កន្លែងនៅ 24 ខេត្តក្រុងទូទាំងប្រទេសកម្ពុជា
- ✓ មិនចាំបាច់មានគណនីនៅធនាគារទាំងអ្នកផ្ញើ និងអ្នកទទួល
- ✓ មិនមានការគិតថ្លៃសេវាកម្មផ្ទេរប្រាក់ពីអ្នកទទួលឡើយ

WESTERN UNION®

សេវាកម្មផ្ទេរប្រាក់ទូទាំងពិភពលោក រហ័សទាន់ចិត្ត និងគួរឲ្យទុកចិត្ត

**សូមទាក់ទងទូរស័ព្ទ 1-800-325-6000**

ភ្នាក់ងារផ្ទេរប្រាក់នៅកម្ពុជាដែលទទួលបានការអនុញ្ញាតពី Western Union: ACLEDA Bank Plc. CAB BANK SBC Bank

| | | | | |
|---|---|---|---|---|
| **NHA THUOC THIEN NHIEN**<br>1299 E. ANAHEIM ST<br>LONG BEACH, CA 90813<br>TEL: 562-218-2328 | **MONEY MART #0772**<br>1001 E. PACIFIC COAST HWY<br>LONG BEACH, CA 90806<br>TEL: 562-599-0991 | **MONEY MART #0767**<br>2375 LONG BEACH BLVD<br>LONG BEACH, CA 90806<br>TEL: 562-427-0253 | **CONTINENTAL CURRENCY #704**<br>3106 SAN GABRIEL BLVD<br>ROSEMEAD, CA 91770<br>TEL: 626-280-0380 | **TOPANGA CHECK CASHING**<br>7239 TOPANGA CANYON BLVD<br>CANOGA PARK, CA 91303<br>TEL: 818-594-0057 |
| **CONTINENTAL CURRENCY #408**<br>1301 LONG BEACH BLVD<br>LONG BEACH, CA 90813<br>TEL: 562-599-1550 | **ANTOJITOS LATINOS LIQUOR**<br>25381 ALICIA PKWY STE N<br>LAGUNA HILLS, CA 92653<br>TEL: 949-215-9708 | **NADERS MARKET**<br>25227 REDLANDS BLVD # I<br>LOMA LINDA, CA 92354<br>TEL: 909-796-1660 | **CONTINENTAL CURRENCY #413**<br>237 LONG BEACH BLVD<br>LONG BEACH, CA 90802<br>TEL: 562-432-5883 | **SIAM MARKET**<br>2505 E. ANAHEIM ST<br>LONG BEACH, CA 90802<br>TEL: 562-607-8970 |

* សម្រាប់ការផ្ទេរប្រាក់ដុល្លារអាមេរិកប៉ុណ្ណោះ។

** ថ្លៃសេវាកម្មផ្ញើប្រាក់នេះមានសុពលភាពចាប់ពីថ្ងៃទី 22 ខែ តុលា ឆ្នាំ 2007 នេះនៅតាមបណ្តាភ្នាក់ងារនានាដែលបានចូលរួមក្នុងកម្មវិធីរបស់ខ្លួននៅតំបន់ប្រជុំជន Los Angeles និង Philadelphia ។ Western Union សូមរក្សាសិទ្ធិក្នុងការកែប្រែដោយមិនចាំបាច់ជូនដំណឹងជាមុន។ ថ្លៃសេវាកម្មផ្ញើប្រាក់អាចត្រូវបានគិតច្រើនជាងនេះសម្រាប់ការផ្ញើប្រាក់តាមរយៈទូរស័ព្ទ និង តាមរយៈគេហទំព័រ www.westernunion.com ។

*** រយៈពេលនៃការទទួលប្រាក់អាស្រ័យទៅលើកត្តាមួយចំនួននៃសេវាកម្មរួមទាំងម៉ោងធ្វើការ និងទីតាំងរបស់ទីភ្នាក់ងារផ្ទេរប្រាក់ព្រមទាំងភាពខុសគ្នារវាងម៉ោងនៅក្នុងតំបន់នីមួយៗផងដែរ។ ពិនិត្យមើលកត្តាកំណត់ និងលក្ខខណ្ឌនានានៅក្នុងបែបបទ "ផ្ញើប្រាក់"។

©2007 Western Union Holdings, Inc. All Rights Reserved.

C&B CROISSANTS
WHOLESALE ONLY

ORDER BY PHONE:
(562) 495-5713
(800) 974-3888
Cell: (562) 607-3258
Fax: (562) 495-7544

-ធានាគុណភាពទុកបាន ៣០ ថ្ងៃ
-ដឹកជញ្ជូនដោយមិនគិតថ្លៃ ពីថ្ងៃ ច័ន្ទ-សុក្រ
-ហាងយើងខ្ញុំមានលក់ដុំតែប៉ុណ្ណោះ
-អ្នកទិញត្រូវឱ្យដឹងមុន ១ថ្ងៃ

# ហាងខ្មែរផលិតនំ ក្រូសង់



| Item | Net Wt Each | Packaging | Price/Package |
|---|---|---|---|
| - Butter Croissant | 4.50 oz | 50 | $1 .00 |
| - Triangle Croissant | 5.00 oz | 50 | $1 .00 |
| - Square Croissant | 5.00 oz | 50 | $1 .00 |
| - Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Blueberry Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Strawberry Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Raisin Cinnamon Croissant | 6.00 oz | 50 | $2 .00 |
| - Raisin Custard Croissant | 6.00 oz | 50 | $2 .00 |
| - Apple Croissant | 6.00 oz | 50 | $2 .00 |
| - Chocolate Croissant | 6.00 oz | 50 | $2 .00 |
| - Chocotate Cream Cheese Croissant | 6.00 oz | 50 | $2 .00 |
| - Pineapple Cream Cheese Croissant | 6.00 oz | 50 | $2 .00 |

FREE DELIVERY
We guarantee our products up to 30 days. Order must be made 1 day in advance.
WHOLE SALE ONLY

1339 W. Gaylord Street• Long Beach, CA 90813

# ASIAN PACIFIC INTL TRAVEL

## ក្រុមហ៊ុនលក់សំបុត្រយន្តហោះ និងផ្ញើប្រាក់

### មានលក់សំបុត្រគ្រប់ក្រុមហ៊ុនទៅកម្ពុជាដូចជា:

-Eva Airways
-China Airlines
-Singapore Airlines
-Thai Airways
-Malaysia Airlines
-Cathay Pacific
-Korea Airlines
-Asiana Airlines

* មានលក់សំបុត្រទៅប្រទេសផ្សេងៗទៀត ដូចជា: អឺរ៉ុប
* មានលក់សំបុត្រក្នុងប្រទេស **USA**
* មានលក់សំបុត្រយន្តហោះពីភ្នំពេញមក **USA**

### កន្លែងនាងខ្ញុំមានប្រថាប់ត្រា

-Notary Public
-Phone Card ( Buy 4 get 1 free )

**$ 869** Tax included
**Eva**

ទទួលរៀបចំធ្វើ

Re-entry Permit Urgent ,
ធានាប្ដីប្រពន្ធ,គូដណ្ដឹង,ក្រុមគ្រួសារ
សូមលោកអ្នកអញ្ជើញមកដោយមេត្រី

Prepaid - Phone Cards
Toll Free 1-800- 359 -6698

**មានទទួល Pay Bill**

### ផ្ញើប្រាក់ទៅស្រុកខ្មែរធានាថោកជាងក្រុមហ៊ុននានា

➲ ផ្ញើ $100 យកកម្រៃ $4 ➲ ផ្ញើ $1.000 ឬ $10.000
យកឈ្នួលចុះថ្លៃច្រើនថែមទៀត !
➲ ផ្ញើទៅស្រុកខ្មែរលឿនរហ័សទាន់ចិត្ត
ប្រគល់ប្រាក់ដក់ដៃភ្លាមៗជាមួយ
បង្កាន់ដៃទទួលប្រាក់ជូនផងដែរ ។



Lésse passe
៣ថ្ងៃយកបាន
មិនបាច់ម្រើ
Re-entry Permit
និងធ្វើលិខិតឆ្លងដែនខ្មែរថ្មី
ឬបន្តឆ្នាំលិខិតឆ្លងដែនខ្មែរ
ដែលផុតកំណត់

ចុះថ្លៃពិសេសទៅ
ស្រុកខ្មែរ សំបុត្រត្រូវ
វិញឱ្យបានឆាប់បំផុត

**CAL -STATE**
**Realty & Lending**
Real Estate *Home Loans
*Residential * Commercial
You will get the best deal
Magaret (LiLy) Chung
Realtor
Sell your home at 3.5%
Buy your home at 1 % Rebate
ធ្វើការដោយស្មោះត្រង់និងយកចិត្តទុកដាក់ជានិច្ច

1065 E. Anaheim Street.
Long Beach, CA 90813
**Tel: (562) 599 - 5464**
**Fax : (562) 599-5604**
Tony's Cell : (562) 537-3546
LiLy's Cell : (562) 682-6588

4510 E. Pacific Coast Hwy,.
Ste.540 Long Beach, CA 90804
Tel: (562) 599-5464
Cell: (562) 682-6588
Fax: (562) 599-5604
Email : margaretchung@charter.net



Mr.CALVIN C.PAN



Mr.DAN SON

# WINSTAR CAPITAL

**A Residential Mortgage Lending**
**License: # 01834778**

**100% CONFORMING**
**SISA AVAILABLE**

## WANTED: LOAN OFFICER AND Sr. LOAN OFFICER!!!

**We're looking for:**

- Motivated and career minded individual to join our sales team
- Seasoned Loan Officers and Senior Loan Officers
- Opportunity to build your team and manage your own branch
- We provide leads and referrals
- Generous commission splits
- We provide friendly, supportive & beautiful working environment
- Khmer speaking preferred

**For confidential interview, please call Dan at:**
**(714) 594 - 5131**

## REAL ESTATE AGENTS & BROKERS COOPS

- Have an LO assigned to your office
- Coops Marketing plan
- Programs to boost your New Year 2008
- 100% Conforming Full Doc
- Jumbo Loan
- Hard Money

**For more info, contact our sales team:**
**(714) 594 – 5135**

17150 Newhope Street, Suite 503, Fountain Valley, CA 92708




# Quality Assured Collision Center

"We do what's right to ensure your vehicle gets back to pre - accident condition"

1427 long beach Blvd., Suite B
Long Beach , CA 90813
Tel : (562) 599 0766, Fax : (562) 599 6504
QACollison@yahoo.com



" Mission Statement "

To Provide the highest quality of workmanship in reasonable time , while building a lifetime relationship with our customers

ធ្វើតួ និង បាញ់ថ្នាំឡាន
ជាមួយជាងចំណានៗ មានបទពិសោធន៍ខ្ពស់
ធ្វើឱ្យលោកអ្នកមិនខកបំណងឡើយ !











" Services Offered "

- Fast repairs with State-of-the-art equipment .
- Lifetime warranty on body and paint .
- Free estimates .
- Shuttle service .
- Free loaner vehicles , up 7 days .
- Free towing with vehicle repairs .
- I-CAR certified technicians .
- Customer Friendly staff .
- Waiting room with wireless internet .
- Computerized frame measurement , print out .
- Expert color match .
- Auto mechanic on staff .
- 25 working bays .
- 65,000 square feet facility .
- We work with all insurance companies .

STATE -OF-THE-ART Equipment

- 2 chief EZ liner 3 post frame machine .
- Garmat downdraft Heated spray booth .
- PPG paint mixing room .
- Robinair air condition system reclaim ,evacuate and recharge equipment .
- CCC pathways estimating software .




KING KONG
STUDIO & DIGITAL LAB
Photography
"Capturing Moments..."
1617 E. Anaheim St. | Long Beach, CA 90813 | Tel.: (562) 591-2296
Hours: Monday - Sunday (9:30am - 6:00 pm)
Passport+Immigration Photos - in 5 min.
Wedding
Glamour
Family
Restoration
www.kksphotostudio.com
●ទទួលផ្ញើ លិខិតឯកសារតាម E-mail
●មានធ្វើ Flyer , Name Card ,Notary
Income Tax Service!!
Jocelyn C. Thav, C.P.A.
Certified Public Accountant
ElectronicFiling for both Federal &State!
Refunds for ALL 50 states!
Convenience of Direct Deposit!
Drop-off Service Available!
Walk-in or appointments!
មានទទួលធ្វើតាក់ សូមអញ្ជើញមកជួបអ្នកជំនាញឯកទេស CPA
Competitive pricing starting at
$75.00 per return!!!!!
1617 E. Anaheim St. Long Beach xsteet-Walnut |Tel.: (562) 591-2296
មានថតរូបសំរាប់ធ្វើលិខិតឆ្លងដែន ,និដ្ឋាការ និងកិច្ចការអន្តោប្រវេសន៍


ពី RHODE ILANDS
ហាង វីដេអូ ពិភពខ្មែរ
Khmer World Video Store (KW)
មានលក់
DVD & CD ខ្មែរ គ្រប់ផលិតកម្ម
រឿងកំប្លែងខ្លី, កុនខ្មែរ, កុនថៃ និងកុនចិនភាគ គ្រប់រឿង
ម៉ាស៊ីន Karaoke និងប្រព័ន្ធសំលេង
អនុស្សាវរីយ៍គ្រប់ប្រភេទ
ទូរស័ព្ទដៃ (Unlocked) ដែលអាចប្រើជាមួយ ទូរស័ព្ទគ្រប់ប្រព័ន្ធ
KW
Address: 301 Reservoir Ave. Providence RI 02907, Tell: (401) 467 5900


CATHAY PACIFIC
សូមស្វាគមន៍...
CATHAY PACIFIC
Cathay Pacific
ជានិច្ចកាលតែងតែនាំមកនូវ
ភាពងាយស្រួល និងទំនើប...!
LEAP Live Back Seat - features Office Chair technology to Provide active postural support.
9" Personal TV featuring "Audio Video On Demand"
Fixed seat back design-creates a fixed living space that no longer interrupts the space behind when a passenger reclines
Literture pocket relocated below the seat cushion to creat more room .
ក្រុមហ៊ុន CATHAY PACIFIC AIRWAYS បានផ្តើមការហោះហើរ
បំរើអតិថិជន ចាប់ពីខែ ធ្នូ ឆ្នាំ២០០៧ នេះទៅហើយ នូវប្រភេទយន្តហោះ BOEING ថ្មីដ៏ធំបំផុត ដែលរចនាតុបតែងឡើងយ៉ាងល្អប្រណិតក្នុងបច្ចេកទេស
ខ្ពស់ និងជាសុខភាពល្អ កៅអីធំទូលាយ ងាយស្រួលអង្គុយ និងចេញចូល ទូរទស្សន៍ផ្ទាល់ខ្លួន មានទំហំធំរហូតដល់៩អ៊ីង សំរាប់ថ្នាក់ជិះផ្នែក ECONOMY ។
ក្រុមហ៊ុន CATHAY PACIFIC ហោះហើរ៣ជើងក្នុងមួយថ្ងៃ ពី LOS ANGELES ទៅ HONG KONG ។ ពី HONG KONG ទៅ PHNOM PENH
រៀងរាល់ថ្ងៃ (រយះពេលហោះហើរតែ ២:៣០ នាទី តែប៉ុណ្ណោះ) ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅលើយន្តហោះមានជាភាសាខ្មែរផងដែរ ។


PHNOM PENH express
PHNOM PENH EXPRESS
ក្រុមហ៊ុនទទួលផ្ញើប្រាក់ និងលក់សំបុត្រយន្តហោះ
Mon-Sat 9am-6pm
Sunday: 10am-5pm
ទទួលផ្ញើប្រាក់ទៅកាន់ប្រទេសកម្ពុជា - វៀតណាម, មានលក់សំបុត្រយន្តហោះគ្រប់ក្រុមហ៊ុន,
ទៅគ្រប់ប្រទេស, លក់កាតទូរស័ព្ទគ្រប់ម៉ាក និងទទួលបង់វិក័យប័ត្រនានា ។ បំរើអតិថិជន៧ថ្ងៃក្នុងមួយសប្តាហ៍ ។
2140E. Anaheim St., Long Beach CA 90804 . Tel : (562) 434-3322, (562) 434-3760

# LAW OFFICES OF BOROTH CHAY

# ការិយាល័យមេធាវី



▶មេធាវីខ្មែរពូកែក្តីក្តាំនូវករណីគ្រោះថ្នាក់ចរាចររថយន្ត
◆អន្តោប្រវេសន៍ (ធានាប្តីប្រពន្ធ, គូដណ្តឹង, បងប្អូន) ◆ច្បាប់គ្រួសារ
◆បណ្តឹងលែងលះ ◆ប្រាក់ចិញ្ចឹមកូន ◆រដ្ឋប្បវេណី ◆ច្បាប់ក្ស័យធន
▶បើមិនឈ្នះក្តី គឺមិនគិតកម្រៃ .ពិគ្រោះយោបល់ ឬពិភាក្សាមិនគិតថ្លៃ
▶ករណីប្តឹងផ្តល់នឹងផ្តល់ចម្លើយជូនលោកអ្នក ថាតើបណ្តឹងរបស់លោកអ្នក
មានសង្ឃឹមឈ្នះឬយ៉ាងណា? តើគួរធ្វើការប្តឹងផ្តល់ដែរឬទេ? ។



## Up to 50% of Settlement to Clients

▸Bankruptcy ▸Family Law ▸Dissolution of Marriage
▸Child and Spousal Support ▸Immigration
▸Family Sponsor Petition ▸Auto Accident
▸Low Contingency ▸No Recovery ▸No Fee.

**Personal Injury:**

Auto Accident Free Consultation
How strong is your case?
Should you file a claim?

We'll answer your questions!

**Other Legal Representations:**

Family Law: Dissolution of Marriage,
Spousal and Child Support Bankruptcy
Immigration Law: Family sponsored petition

2501Cherry Ave , Ste.245 , Signal Hill , CA 90755
Office: (562) 997- 8500 . Direct : (562) 453 - 5898




# ឃុន ហេង

ឃុន ហេង គឺជាផ្សារខ្មែរដ៏ធំមួយតាមដងផ្លូវ
អាណាហែម មានលក់ទំនិញគ្រប់មុខ
☞សាច់ បន្លែ ផ្លែឈើស្រស់ៗ
☞ អាហារស្ងួត និងម្ហូបកំប៉ុងមកពីអាស៊ី
☞និងមានលក់ម្ហូបឆ្អិនស្រាប់ៗផងដែរ
☞ហើយនឹងមានលក់បាច់ផ្កាសំរាប់ពិធីបុណ្យនានា ។

ទោះទៅទីណា
សូមកុំភ្លេចផ្សារ ឃុន ហេង

915 E. Anaheim Street
Long Beach, CA 90813






apple tree LEASING.com

▸សំរាប់លោក-អ្នកដែលនឹងត្រៀមបើកមុខជំនួញ ឬបើកមុខជំនួញរួចហើយក្តី ដោយមិនចង់ចំណាយលុយផ្ទាល់ខ្លួន ក្នុងការទិញសម្ភារៈរៀបចំ ហាង ឬរោងចក្រ ដូចជា: ហាង Donut, Chinese Food, Computer Equipment, សម្ភារៈកសិកម្ម សម្ភារៈរោងចក្រ និងគ្រឿងប្រដាប់ប្រដាឡានធំៗដឹកជំនួញ ។

▸សូមលោក-អ្នកមេត្តាទាក់ទងជាមួយក្រុមហ៊ុនយើងខ្ញុំ ដោយក្រុមហ៊ុនយើងមានសម្ភារៈប្រដាប់ប្រដាររៀបចំ និងតម្លើងជូនលោក-អ្នក ។

▸សូមកុំឱ្យឱកាសដ៏ល្អសំរាប់របរជំនួញជួញដូររបស់លោក-អ្នកកន្លងផុត ក្រុមហ៊ុនយើងខ្ញុំរងចាំទទួលធ្វើការ និងទំនាក់ទំនងជាមួយលោក-អ្នកជានិច្ច ។

2338 E. Anaheim St., Suite 200, Long Beach, CA 90804
Cell: (562) 537-5552, Office: (562) 433-1130
Fax: (562) 433-1133, E-mail: info@appletreeleasing.com

## APPLE TREE WEALTH MANAGERMENT

▸ក្រុមហ៊ុនយើងខ្ញុំ ជាក្រុមហ៊ុនផ្នែកវិនិយោគទុន ក្នុង និងក្រៅប្រទេស រកស៊ីបណ្តាក់ទុនក្នុងផ្នែកជំនួញលក់ដូរអចលនៈទ្រព្យ ( ផ្ទះ,ដីធ្លី ) ។

▸ប្រសិនបើលោក-អ្នកចង់រកស៊ីជាមួយក្រុមហ៊ុនយើងខ្ញុំ សូមមេត្តាទាក់ទងយើងខ្ញុំ និងសហការរកស៊ីជាមួយគ្នា ដោយភាពស្មោះត្រង់ទៀងទាត់ តាមផ្លូវច្បាប់រដ្ឋ ។



▸Our Private Company is Seeking Private Investor Who Want to Buy House at Discount Wholes Price.

If You Are Interesting Please Contact Office.

2338 E. Anaheim St., Suite 200, Long Beach, CA 90804
Cell: (562) 537-5552, Office: (562) 433-1130
Fax: (562) 433-1133, E-mail: info@appletreeleasing.com

ppletree credit.com solution



⇨ក្រុមហ៊ុនយើងខ្ញុំរងចាំទទួលជួយសំរួលកិច្ចការលោក-អ្នកនៅពេលមានបញ្ហាជាមួយ Credit Card.

- ▸ការលួចបន្លំ ID. ▸ID Theft.
- ▸ក្ស័យធន ▸Bankruptcies.
- ▸ការរឹបអូសអចលនៈទ្រព្យ ▸Foreclosures.
- ▸ជំពាក់បំណុលរដ្ឋ ▸Tax Liens.
- ▸បង់សងប្រាក់មិនទៀតទាត់ ▸Late Payments.
- ▸ខូចឈ្មោះ ព្រោះជំពាក់Credit ▸Charge Offs.
- ▸បង់ប្រាក់ដាច់ស្រេចហើយ នៅតែមានឈ្មោះខូច Credit ▸Paid Collection.
- ▸ការបន្លំឈ្មោះនៅក្នុង Credit Report ▸In Correct Personal Info.
- ▸យើងខ្ញុំត្រូវការបុគ្គលិក ឬភ្នាក់ងារធ្វើការពេញម៉ោង ឬមិនពេញម៉ោង ។
- ▸NOW HIRING: No Experience Necessary Will Training - Full / Part Time, Please Contact.

2338 E. Anaheim St., Suite 200, Long Beach, CA 90804
Cell: (562) 537-5552, Office: (562) 433-1130
Fax: (562) 433-1133, E-mail: info@appletreecredit.com

## LENNY BUYS HOUSE.COM

⇨បើសិនលោក-អ្នក ចង់ទិញផ្ទាល់ពីក្រុមហ៊ុនយើងខ្ញុំ ដោយមិនចាំបាច់មានប្រវត្តិរូបល្អ, ខូចគ្រឌីត, មិនមានគ្រឌីត ឬមួយមានបញ្ហាខាងការរឹបអូសអចលនៈទ្រព្យ និងក្ស័យធន ។ ដោយលោក-អ្នកគ្រាន់តែមានលុយកាក់បន្តិចបន្តួច ក៏ក្រុមហ៊ុនយើងខ្ញុំអាចជួយឱ្យបានក្នុងការទិញផ្ទះសម្បែង ដោយបង់ថ្លៃផ្ទះប្រចាំខែ ក្នុងតម្លៃសមរម្យ ប្រសើរជាងជួលផ្ទះគេ ។

▸Our Company is a Private Real Estate Investor. We are Helping People Who has Credit Problem, Judgement, Tax Lien, Child Support, Late Payment, Collection, Charge Off, BK Problem, and Foreclosures Situation. We Can Help With Out Involve Real Estate Brokers, Banks, or Other Lender. You are Buying Direct From Individual Investor If You´re Interesting, Please Contact Our Company.

2338 E. Anaheim St., Suite 200, Long Beach, CA 90804
Cell: (562) 537-5552, Office: (562) 433-1130
Fax: (562) 433-1133




# អាថ៌កំបាំង៦យ៉ាងរបស់ស្ត្រីដែលបុរសត្រូវដឹង



ប្រហែលជាមានតែនៅក្នុងពិភពនៃក្តីសុបិន្ត ប៉ុណ្ណោះ ដែលនៅស្ងៀមៗ ស្រាប់តែសុភាពស្ត្រីដ៏ស្រស់សោភាម្នាក់ដែលអ្នកបានជួប នៅក្នុងពិធីជប់លៀងដើរសំដៅចូលមករកអ្នកព្រមទាំងជម្រុះមធុរសវាចាថា "ខ្ញុំពេញចិត្តលោក ហើយត្រៀមខ្លួនដើរលេងជាមួយលោកគ្រប់ពេល..."។ ប៉ុន្តែនៅក្នុងពិភពនៃការពិតវិញ គឺរូបអ្នកទេ ដែលស្ទុះចូលទៅរកនាង ហើយខំប្រឹងរាយល្បិចកលចែចង់ស្រីគ្រប់វិធីដោយជួនកាលមិនទាំងសូវបានសម្រេចជោគជ័យផង ហើយថែមទាំងត្រឡប់មកថែទាំរបួសបេះដូងតែម្នាក់ឯង ព្រោះតែការបដិសេធរបស់នាងទៀតផង ។

ហេតុផលងាយៗ គឺមកពីអ្នកមិនបានដឹងថា តើរូបអ្នកមានស្ថិតនៅក្នុងក្រសែភ្នែករបស់នាងខ្លះទេ? ថ្វីបើស្ត្រីខ្មែរ ពុំបានសម្តែងចេញនូវកាយវិការថា នាងបានស្រលាញ់បុរសម្នាក់នេះ ឬម្នាក់នោះ ប៉ុន្តែនាងមានសញ្ញាសម្ងាត់ប្រាប់ឱ្យអ្នកដឹងបានថា នាង "ចាប់អារម្មណ៍ " លើរូបអ្នកដោយពុំចាំបាច់ហាមាត់និយាយឡើយ ។ ដើម្បីទុកជាមេរៀន ឬបទពិសោធន៍ក្នុងការទាក់ទងស្រីស្រស់ក្នុងពេលក្រោយៗទៀតប្រកបដោយជោគជ័យនោះ អ្នកត្រូវតែស្វែងយល់ពីសញ្ញាដួងចិត្ត ដែលបញ្ជាក់ថា នាងមានចិត្តប្រតិព័ទ្ធលើរូបអ្នកដូចតទៅ :

### ១-ប្រសិនបើនាងបែរមុខយ៉ាងលឿន...

ឬផាត់សក់គ្របមុខបន្តិចបន្តួច ហើយផ្តោតភ្នែកសម្លឹងមករកអ្នកនេះបញ្ជាក់ថា រូបអ្នកកំពុងតែស្ថិតនៅក្នុងក្រសែភ្នែករបស់នាងហើយ ។

### ២-ប្រសិនបើនាងបង្ហាញកដៃ...

នេះជានិមិត្តសញ្ញាដែលប្រាប់ឱ្យដឹងថា នាងចាប់អារម្មណ៍លើរូបអ្នកមិនតិចទេ ប៉ុន្តែបុរសភាគច្រើន ច្រើនតែពុំបានសង្កេតដល់ចំណុចនេះ ។

### ៣-ប្រសិនបើនាងកន្ត្រាក់ជើង...

ឬអង្គុយកន្ត្រាក់ជើងចេញពីគ្នានោះ មានន័យថា នាងត្រៀមខ្លួនចូលទីលានប្រកួតជាមួយអ្នកហើយ ។

### ៤-ប្រសិនបើនាងទាញជើងចេញពីស្បែកជើង...

ឬរំកិលជើងចេញចូលក្នុងស្បែកជើង ដែលនាងកំពុងពាក់នោះមានន័យថា នាងកំពុងតែផ្តល់ភ្លើងសញ្ញាដល់រូបអ្នក ហើយដូច្នេះមិនត្រូវល្ងង់សួរនាងថា នាងរមាស់ជើងឬទេនោះឡើយ ព្រោះធ្វើបែបនេះវាជាការល្ងង់ខ្លៅ ហើយនាំឱ្យនាងខ្មាសអៀនទៀតផង ។

### ៥-ប្រសិនបើនាងបង្ហាញរស្មីពេជ្រចែងចាំងរបស់ខ្លួន...

បញ្ជាក់ថា នាងកំពុងបញ្ជូនសញ្ញាទាក់ទងចូលមករកអ្នកក្នុងលក្ខណៈដុតរោលអារម្មណ៍ ហើយប្រសិននាងផាត់សក់ទៅខាងក្រោយ ធ្វើឱ្យមើលឃើញគល់ដោះសស្អាតរបស់នាងផងនោះ គ្មានហេតុផលអ្វីដែលអ្នក និងនាងត្រូវនៅស្ងៀមទៀតទេ ។

### ៦-ប្រសិនបើនាងស្ទាបអង្អែលវត្ថុដែលមានរាងជាបំពង់

ឬប្រើម្រាមដៃអង្អែលលេងត្រង់ដៃកែវចុះឡើងៗ មិនត្រូវរារែកចិត្តទៀតទេ ព្រោះអ្នកគួរតែដឹងក្នុងចិត្តហើយថា នាងត្រូវការអ្វី? ៕

# វិធីបំបាត់មុន និងថ្ងៃវជ្រញដោយបន្លែ

បើទោះណាមុនជាំស្នាមជ្រីវជ្រួញជារឿងធម្មជាតិក៏ពិតមែន ក៏ប៉ុន្តែបើ វាកើតហើយក៏ធ្វើឱ្យយើងបាត់បង់សម្រស់មួយផ្នែកធំដែរ ។ តើអ្នកដឹងទេ សារធាតុក្នុងបន្លែអាចជួយសម្អាតរន្ធញើសកាត់បន្ថយបញ្ហាខាងលើបានយ៉ាងប្រសើរបំផុតដែលយើងស្មានមិនដល់ទៀតផង ។

### ●ប៉េងប៉ោះជួយព្យាបាលមុន

អ្នកត្រូវបកសម្បកប៉េងប៉ោះ រួចចិតជាបន្ទះៗ ហើយយកគ្រាប់ចេញ ។ បន្ទាប់មកយកទៅក្រឡុកឱ្យម៉ដ្ឋល្អ (បើគ្មានម៉ាស៊ីនក្រឡុកទេយើង អាចប្រើវិធីមួយទៀត គឺកិនសង្កត់រហូតទាល់តែសាច់ប៉េងប៉ោះបែកឡើងប៉ផ្លេច ក៏អាចប្រើបាន ដូចគ្នាដែរ) ។ រួចហើយលាបលើក្បាលមុន (សូមប្រយ័ត្នកុំឱ្យចូលភ្នែក) ទុកចោល១០ ទៅ១៥ នាទី រួចហើយលាងវាចេញដោយទឹកក្តៅឧណ្ហៗ ។

ក្នុងករណីដែលអ្នកជាមនុស្សដែលមានស្បែកឆាប់ប្រតិកម្ម ឬនៅមិនទាន់ប្រាកដក្នុងចិត្តថា តើអាចមានប្រតិកម្ម ឬអត់នោះ អ្នកអាចសាកល្បងអនុវត្តនៅលើខ្នងដៃសិនក៏បាន ។ (តទៅទំព័រទី២៧)

ក្រុមហ៊ុនធានារ៉ាប់រង
TOP AUTO INSURANCE AGENCY
នាងខ្ញុំនិយាយភាសាខ្មែរ
AUTO -LIFE-HEALTH-HOME-COMMERCIAL
រថយន្ត_ជីវិត_សុខភាព_គេហដ្ឋាន_ពាណិជ្ជកម្ម



Tiffany Prak
Broker/Agent Lic.# 0E44334
(562) 230-5100

-Immediate Coverage FREE QUOTE Instant SR22
-Any car, any driver LOW RATES Why pay more

-Low Cost. Low Down
. Low Monthly Payment
Tickets, accident,DUI=No Problem

- Multiple Car discount
- Good driver discount
• ធានារ៉ាប់រងជូនភ្លាមៗដល់អ្នកបើកបរគ្រប់រូប និងយានយន្តគ្រប់ប្រភេទ
• ចុះថ្លៃជូនអ្នកបើកបរមានសុវត្ថិភាព និងចុះថ្លៃជូនចំពោះរថយន្តច្រើន
• បង់កាត់ខែតិច • ជំរាបតម្លៃជូនជាមុន

2760 E. Sprint St., Suite 140 • Long Beach, CA 90806
Tel: (562) 989-1800 Fax: (562) 989-1899

ហាងខ្មែរលក់គ្រឿងបន្លាស់រថយន្ត
Parts For Less
Auto Parts & Accessories
1050 E. Pacific Coast Hwy.
Long Beach, CA 90806
562-599-6364

មានលក់គ្រឿងបន្លាស់រថយន្តគ្រប់ប្រភេទសម្រាប់ក្រៅនិងក្នុងស្រុក ។ ទំនិញយើងខ្ញុំលក់តម្លៃសមរម្យ និងធានារកជូនលោកអ្នកនូវទំនិញដែលមិនមានក្នុងហាងយើងខ្ញុំ ។
Complete Foreign & Domestic Parts
សូមអញ្ជើញដោយមេត្រីភាព!



សុខភាព

# វិធីព្យាបាលជំងឺមួយចំនួនដោយខ្លួនឯង

**ខាងក្រោមនេះគឺជាវិធីងាយៗដែលអាចធ្វើឱ្យអ្នកមានសុខភាពយ៉ាងរឹងមាំមិនគួរឱ្យជឿ :**

***1-ឈឺក្បាលជាប្រចាំ*** : មូលហេតុចម្បងនៃអាការឈឺក្បាលនោះ រួមមានអាការរលាកដាច់ដុំបរិវេណដើម-ក ការទទួលទានដំណេកមិនបានគ្រប់គ្រាន់ភាពតានតឹងក្នុងអារម្មណ៍ ឬ ការដែលមានរោគប្រចាំខ្លួន ដូចជារោគប្រកាំងឈឺមួយចំហៀងក្បាល ។

***-វិធីព្យាបាល*** : គួរតែថែរក្សាសាច់ដុំបរិវេណដើម-ក កុំឱ្យមានការប៉ះទង្គិច ។ ការប្រចាញ់ញីដើម្បីរំសាយការឈឺចាប់ក៏វិធីដ៏ល្អមួយដែរ ហើយត្រូវទទួលទានដំណេកឱ្យបានយ៉ាងហោចណាស់៦-៨ម៉ោងក្នុងមួយថ្ងៃ ។



***2-ងងឹតមុខពេលក្រោកឈរ*** : បើអ្នកទៅជាងងឹតមុខពេលក្រោកឈរ មូលហេតុអាចបណ្តាលមកពីខ្វះឈាមធ្វើឱ្យឈាមទៅចិញ្ចឹមទ្រទ្រង់ខួរក្បាលមិនបានគ្រប់គ្រាន់ ទើបធ្វើឱ្យទៅជាងងឹតមុខ ជាពិសេសច្រើនកើតមានក្នុងក្រុមពួកតមសាច់ ។ ការផឹកគ្រឿងស្រវឹងដែលមានជាតិអាល់កុល ដែលវាអាចទៅសង្កត់កៀបសរសៃខួរក្បាល ការជក់បារីក៏ធ្វើឱ្យសារធាតុនីកូទីន ចូលទៅច្របាច់សរសៃឈាមធ្វើឱ្យកើតការវិលមុខ ។

***-វិធីព្យាបាល*** : ការការពារអាការងងឹតមុខពេលងើបឈរ ធ្វើបានដោយការហាត់ប្រាណ ដូចជារត់ ឬធ្វើកិច្ចការផ្ទះ និងត្រូវទទួលទានដំណេកឱ្យបានយ៉ាងហោចណាស់៦-៨ម៉ោងក្នុងមួយថ្ងៃ ។

***3-មានអាការឈឺខ្នងជាប្រចាំ*** : អាការឈឺខ្នងញឹកញាប់អាចបណ្តាលមកពីការអង្គុយ ធ្វើការយូរៗពេក ដោយគ្មានការផ្លាស់ប្តូរឥរិយាបថ ឬដើរ អង្គុយ ដេក ដែលធ្វើឱ្យរាងកាយមិនស្ថិតនៅក្នុងលក្ខណៈមួយសមរម្យត្រឹមត្រូវដូចជាអង្គុយចំកោងខ្នង ។

***-វិធីព្យាបាល*** : ប្រសិនបើអ្នកចង់ការពារកុំឱ្យអាការឈឺខ្នងក្លាយជារោគប្រចាំខ្លួន គួរតែចាប់ផ្តើមធ្វើការសម្រួលឥរិយាបថផ្សេងៗមិនថា អង្គុយ ឈរ ដើរ ឬដេកឱ្យនៅក្នុងឥរិយាបថត្រឹមត្រូវ ដែលកត្តាសំខាន់ គឺខ្នងរបស់អ្នកត្រូវត្រង់ជានិច្ច ឬអ្នកអាចរកកន្លែងណាមួយសម្រាលអាការឈឺបែបងាយៗដោយខ្លួនអ្នកផ្ទាល់ឱ្យបានរយៈពេល៥-១០នាទី ។

***4-ទល់លាមក*** : ដំណើរទល់លាមកអាចបណ្តាលមកពីការបរិភោគអាហារដែលមិនមានកាកដូចជាមីស្រាប់ចំណីតេះលេងផ្សេងៗ ការលេបថ្នាំបញ្ចុះជាប្រចាំវានឹងធ្វើឱ្យប្រព័ន្ធបញ្ចេញចោលខូច រួមទាំងភាពតានតឹងក្នុងអារម្មណ៍ដោយសាររឿងរ៉ាវក្នុងជីវិតប្រចាំថ្ងៃ ក៏ជាមូលហេតុដែលធ្វើឱ្យទល់លាមកបានដូចគ្នា ។

***-វិធីព្យាបាល*** : គួរតែបរិភោគអាហារឱ្យបានគ្រប់គ្រាន់ទាំង៥ក្រុម ជាពិសេសអាហារ ដែលមានកាកសរសៃ ដូចជាបន្លែ និងផ្លែឈើ ។ ផឹកទឹកឱ្យបានច្រើនស្តាប់ចំរៀងដើម្បីកាត់រំសាយភាពតានតឹងក្នុងអារម្មណ៍ ៕

## វិធីបំបាត់មុន...

ប្រសិនបើមានអាការផ្សាខុសប្រក្រតីសូមប្រញាប់លាងចេញភ្លាម ហើយមិនគួរប្រើលើផ្ទៃមុខឡើយ ។

**●ត្រកួនជួយបំបាត់ស្នាមជ្រីវជ្រួញ**

ចូរត្រៀមត្រកួន២ដើម ពងមាន់ផ្នែកសមួយគ្រាប់ រួចយកត្រកួនមកកាត់ឫសចោល ហើយលាងទឹកឱ្យស្អាត ចិញ្ច្រាំ ឬហាន់ឱ្យជិត ម៉ដ្ឋ គោះពងមាន់ដាក់ពែង ដោយយកតែផ្នែកសមកប្រើ រួចយកទៅកិនក្រឡុកឱ្យម៉ដ្ឋ ។ បន្ទាប់មកលាងសម្អាតមុខឱ្យស្អាត ទើបលាបក្រែមថែរក្សាស្បែកដែលទើបនឹងធ្វើហើយ ដោយលាបរហូតដល់សព្វលើផ្ទៃមុខរួចទុកចោលប្រមាណ៥ទៅ១០នាទី ទើបលាងចេញដោយទឹកស្អាត ។ ប្រសិនបើប្រើក្រែមត្រកួននេះជាប្រចាំ វានឹងជួយលុបបំបាត់ស្នាមជ្រីវជ្រួញ និងអាចជួយព្យាបាលស្បែកឱ្យមើលទៅភ្លឺរលោងស្រស់ថ្លាបានទៀតផង ៕



MODERN FABRIC & SHOES

-ហាងយើងខ្ញុំមានលក់ ក្រណាត់ប៉ាក់ ស្បែកជើង សំលៀកបំពាក់
-ទទួលកាត់សំលៀកបំពាក់គ្រប់ម៉ូតសំរាប់បុរសនិងស្ត្រី
-សំអាងការតាមបែបបុរាណនិងសម័យថ្មីនិយម
សូមស្វាគមន៍ដោយក្តីញញឹម!






1636 E. ANAHEIM STREET LONG BEACH, CA 90813
Tel: (562) 599-3333 • (562) 599-3237

## តើសម្តេចក្រុមព្រះ...

គួរបញ្ជាក់ថា កាលពីបោះឆ្នោតឆ្នាំ១៩៩៣ ដែលរៀបចំដោយអង្គការសហប្រជាជាតិនោះ គណបក្សហ៊្វុនស៊ិនប៉ិច ដែលដឹកនាំដោយសម្តេចក្រុមព្រះបានឈ្នះឆ្នោតដល់ទៅ ៥៨កៅអី ។ ប៉ុន្តែពេលនេះ គណបក្សប្រជាជនកម្ពុជាមិនព្រមចង់បង្កើតតំបន់អប្បគម តែសម្តេចក្រុមព្រះបានយល់ព្រមឱ្យលោក ហ៊ុន សែន ធ្វើជាសហនាយករដ្ឋមន្ត្រី ។

ជាអកុសល នៅថ្ងៃទី៥-៦ កក្កដា ឆ្នាំ១៩៩៧ រដ្ឋាភិបាលចំរុះនេះ ឈ្លោះគ្នា រហូតដល់បង្ហូរឈាមកណ្តាលទីក្រុងភ្នំពេញ ទំលាក់សម្តេចក្រុមព្រះចេញពីអំណាច ធ្វើឱ្យមន្ត្រីស្មោះត្រង់នឹងព្រះអង្គស្លាប់អស់យ៉ាងច្រើននាក់ ។

ក្រោយមកសម្តេចក្រុមព្រះបានវិលត្រឡប់មកក្រុងភ្នំពេញវិញ ជាប់ឆ្នោតដឹកនាំរដ្ឋាភិបាលចំរុះជាមួយលោក ហ៊ុន សែន ដដែល ។ អ្វីៗដែលសម្តេចក្រុមព្រះ និងលោក ហ៊ុន សែន ធ្លាប់បានល្អកល្អឹននឹងគ្នាមិនយូរប៉ុន្មានក៏បានប្រេះស្រាំ រហូតដល់ព្រះអង្គសុំលាឈប់ពីប្រធានរដ្ឋសភា ។ គួរឱ្យឈឺចាប់ជាងនេះទៀត ព្រះអង្គបានមន្ត្រីក្រោមឱវាទមួយចំនួន រៀបចំធ្វើបក្សប្រហារព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិចទៀត ។

អ្នកវិភាគនយោបាយមួយចំនួន បានលើកហេតុផលថា ការដែលសម្តេចក្រុមព្រះមិនអាចវិលត្រឡប់ចូលប្រទេសបាននៅពេលនេះ វាជាយុទ្ធសាស្ត្ររបស់គណបក្សប្រជាជនកម្ពុជារួមដៃគ្នាជាមួយគណបក្សហ៊្វុនស៊ិនប៉ិចប៉ុណ្ណោះ ។ ដើម្បីឱ្យអំណាចព្រះអង្គចុះខ្សោយ និងធ្វើឱ្យអ្នកធ្លាប់គាំទ្រពីមុនបាក់ចិត្ត ហើយងាករកមកគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជាវិញ ។


លោក មុត ចន្ថា អ្នកនាំពាក្យគណបក្សនរោត្តម រណឫទ្ធិ

យុទ្ធសាស្ត្របំបែកបំបាក់ រវាងអ្នករាជានិយម និងអ្នកប្រជាធិបតេយ្យនេះគ្មានអ្វីក្រៅពីចង់បានអំណាចគ្រប់គ្រងអំណាចតែម្នាក់ឯងកុំឱ្យពួកទាំងនោះធ្វើការប្រឆាំងតវ៉ាច្រើនពេក ។

ពេលនេះក្រុមអ្នកតំណាងរាស្ត្រមួយចំនួនពីគណបក្ស សម រង្ស៊ី និងហ៊្វុនស៊ិនប៉ិចបានរត់ចុះទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា ដើម្បីបានលាភសក្ការៈ និងមុខដំណែង ។

លើសពីនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញមុខការពារ ចំពោះអ្នកដែលបានទៅចុះចូលទាំងនោះថែមទៀត ។

មជ្ឈដ្ឋានជាច្រើនបានឱ្យដឹងថា វាសនារបស់សម្តេចក្រុមព្រះមិនល្អ ដូចលោក ថាក់ស៊ីន ស៊ីណា វ៉ាត្រ នាយករដ្ឋមន្ត្រីថៃ ដែលគេទម្លាក់ចេញពីអំណាច ហើយត្រូវអ្នកស្រុកគាំទ្រឈ្នះឆ្នោតឱ្យនោះទេ ។ ឱកាសចុងក្រោយរបស់ព្រះអង្គនៅតិចណាស់ គឺមានតែព្រះមហាក្សត្រទេ ទើបអាចដោះស្រាយបញ្ហានេះបាន ៕

## ចិន_យួនដេញខ្មែរ...

ឧទាហរណ៍ថា នៅប្រទេសអេត្យូពីរដ្ឋាភិបាលគេមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋលក់ដីស្រែចំការទេ ។ គេមិនឱ្យលក់ ព្រោះគេមិនចង់ឱ្យកសិករធ្វើការផ្លាស់ទីលំនៅ ហើយការផ្លាស់ប្តូរទីកន្លែងច្រើន វាគ្មានប្រយោជន៍ ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានឱ្យដឹងថា យើងសូមស្វាគមន៍ចំពោះអ្នកវិនិយោគនៅស្រុកខ្មែរ ។ ប៉ុន្តែ អ្នកទាំងនោះមិនត្រូវអនុញ្ញាតិឱ្យទិញដីធ្លី និងសំណង់ផ្សេងៗជាសម្បត្តិផ្ទាល់ខ្លួននោះទេ ។

ចំណែកលោក ហ៊ុន សែន បាននិយាយកាលពីថ្ងៃទី ១៤ កុម្ភៈ ថា គ្មានការបន្ធូរបន្ថយចំពោះជនបរទេសមិនឱ្យមានដីក្នុងប្រទេសកម្ពុជាឡើយ ។ បច្ចុប្បន្ននេះ ជនបរទេសអាចមានសិទ្ធិទិញដីរួមគ្នាជាមួយជនកម្ពុជាមានសិទ្ធិភាគច្រើន ។ ចំពោះពាក្យចរចាមអារ៉ាមថា ការកែប្រែនយោបាយដីនេះ បាននឹងកំពុងតែសាយភាយហើយ ។

រីឯលោក ឌិត ចាន់ណា ធ្វើការនៅក្រុមហ៊ុន CPL បានមានប្រសាសន៍ថា បើជនបរទេសមានសិទ្ធិទិញដីដែលពួកគេចង់បាន យើងនឹងរកប្រាក់បានដោយងាយ ។ ប៉ុន្តែ ប្រជាពលរដ្ឋកម្ពុជានឹងត្រូវខាតចេញពីទីផ្សារ ។

បើសិនគ្មានការទប់ស្កាត់បញ្ហាដីធ្លី សំណង់ផ្ទះល្វែងអគារឱ្យទាន់ពេលវេលាទេ ប្រទេសកម្ពុជាទៅថ្ងៃអនាគតនឹងមានវិបត្តិអតិផរណាអចលនទ្រព្យ ដូចនៅសហរដ្ឋអាមេរិក កូរ៉េ ចិន ជប៉ុន មិនខានឡើយ ៕


GOLDEN MOON
97¢ up + UNIFORMS + CLOTHINGS + TOYS
Ken's Wireless
CELL PHONES, ACCESSORIES, REPAIRS & RING TONES
97¢+ KEN លក់ទូរស័ព្ទ
1617 E. ANAHEIM ST.
LONG BEACH, CA 90813 TEL: (562) 591-9209
cingular · NEXTEL · Sprint · O2 Wireless · verizon wireless · T-Mobile · PAGE PLUS Cellular · PLATINUMTEL · sidekick III · boost mobile
Long Beach Blvd. · Pacific Coast Hwy. · Alamitos Ave. · Walnut Ave. · Cherry Ave. · Anaheim St. · HERE! · North · "Where you At?"



ពេទ្យជំនាញខាងព្យាបាល
រោគឫសដូងបាត
▸ ជាគ្រូពេទ្យតែមួយគត់ដែលទទួលព្យាបាលរោគឫសដូងបាត យ៉ាងមានប្រសិទ្ធិភាព និងមានមុខជំនាញច្បាស់លាស់ !!
▸ ប្រើបច្ចេកវិជ្ជាថ្មី ទំនើប និង ទាន់សម័យ !!
▸ ធានាព្យាបាលដោយមិនយកប្រាក់មុនឡើយ លុះត្រាតែរោគនោះដាច់អស់ ទើបយកប្រាក់ !!
▸ រយៈពេលព្យាបាលពី ៤ ទៅ ៥ ថ្ងៃប៉ុណ្ណោះ !!
▸ សូមទូរស័ព្ទធ្វើការណាត់ជួបជាមួយលោកគ្រូពេទ្យ តាមរយៈលេខ :
(510) 387 9195 /(510) 532 5419
Hemorthoid Treatment Specialist


សេចក្តីជូនដំណឹង
Free- Free- Free
▸ចំពោះមនុស្សចាស់ ចាប់ពីអាយុ៦៥ឆ្នាំឡើងទៅ ដែលមាន Medicare និងត្រូវបានការស្នើសុំនូវទឹកដោះគោបំប៉នកម្លាំង, កៅអីប្រើកម្លាំងភ្លើង, គ្រែប្រើដោយកម្លាំងភ្លើង, ប្រដាប់ប្រដារវាស់សំពាធឈាម, សំភារៈពិនិត្យស្ករក្នុងឈាម ឬទឹកនោមផ្អែម ។
▸យើងខ្ញុំជួយស្នើសុំដោយឥតគិតកម្រៃ ដោយមានការដឹកជញ្ជូនទៅជួបវេជ្ជបណ្ឌិតទៀតផង ។
សូមមេត្តាទាក់ទងលេខទូរស័ព្ទ :

សូមអរគុណ !
(626) 476-3340 យើងខ្ញុំនិយាយភាសាខ្មែរ
(619) 261-2358 យើងខ្ញុំនិយាយភាសាអង់គ្លេស

# បច្ចុប្បន្នភាពរឿងមិនគួរកើតនៅកម្ពុជា

## កំពុងរួមរក្សាជាមួយសហាក្នុងទ្រុងគោប្រពន្ធមកទាន់

*ដោយ : សម្ផស្ស*

បុរស និងស្ត្រីមួយគូ ដែលមានប្តីប្រពន្ធ និងកូនរៀង១ខ្លួន បានលួចក្បត់ផិតលបលួចមានសហាយឆក់កណ្តៀតជាមួយគ្នា ។ ជាញឹកញាប់ រហូតដល់ប្រពន្ធតាមទាន់ កំពុងរួមរក្សគ្នាក្នុងទ្រុងគោប្រពន្ធខឹងពេកដេញកាប់ផ្អើលពេញភូមិ ។

ហេតុការណ៍ស្នេហាឆក់កណ្តៀតនេះ កើតនៅភូមិដំណាក់ទ្រព្យខាងជើង ឃុំត្រាំងស្វាយ ស្រុកឈូក ខេត្តកំពត កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ ២០០៨ ។

អ្នកស្រី ទីម លឿន អាយុ៣៦ឆ្នាំ រស់នៅភូមិ កើតហេតុខាងលើបានរៀបរាប់ទាំងកំហឹងថា ប្តីរបស់គាត់ឈ្មោះ ស៊ិន រ៉ុម អាយុប្រហែលគ្នា និងមានកូន២នាក់ទៀត ។

អ្នកស្រីបន្តថា ប្តីរបស់គាត់មានគំនិតក្បត់ផិត រយៈពេលជាង១ឆ្នាំមកហើយ ប៉ុន្តែគាត់មិនហ៊ានថា ឱ្យប្តីទេ ព្រោះវាគ្មានភស្តុតាងគ្រប់គ្រាន់ ។ ដោយសារអ្នកភូមិនិយាយពីមាត់មួយទៅមាត់មួយ និងមានការសង្ស័យផង នៅថ្ងៃទី១៨ ខែមករា គាត់ក៏កាន់កាំបិតដើររកប្តី ហើយប្រទះឃើញពួកគេកំពុងរួមរ័កក្នុងទ្រុងគោ ។

អ្នកស្រី ទីម លឿន បន្តទៀតថា នៅពេលនោះ គាត់ខឹងពេក ក៏ទាញកាំបិតដេញកាប់អ្នកទាំងពីរផ្អើលពេញភូមិ ។ ទីបំផុតប្តីគាត់ក៏នាំនាងម៉ុមនោះរត់ចោលស្រុកភូមិទៅក្រេបទឹកឃ្មុំបាត់ស្រមោលតែម្តង ។

លោក ជួប ឌុច អាយុ៣៧ឆ្នាំ ត្រូវជាប្តីនាង ម៉ុម បានរៀបរាប់ថា ប្រពន្ធរបស់គាត់លួចមានគំនិតក្បត់ផិតជាមួយសហាយជាញឹកញាប់ តែគាត់ចេះតែធ្វើការអប់រំខ្លាចកូនគ្មានម្តាយនឹងគេ ។

នៅយប់កើតហេតុនោះ ពេលអ្នកស្រុកផ្អើលដេញចាប់អ្នកមានសហាយស្មន់នោះ គាត់បានដេញទាន់ប្រពន្ធរបស់គាត់ ហើយវាយនាងជាការព្រមានទៀតផង ។

លោក ជួប ឌុច បានបន្តថា ប្រពន្ធរបស់គាត់បានរត់តាមឈ្មោះ រ៉ុម ទៅបាត់ទាំងយប់នោះបាត់ទៅ ។ ចំណែកគាត់ និងកូនលែងស្តាយស្រណោះទៀតហើយ ៕

## ព្យាបាលជំងឺដោយស្រោចទឹកក្តៅ

*ដោយ : សម្ផស្ស*

ការព្យាបាលដ៏អស្ចារ្យមួយ ដែលអ្នកផងមិនសូវបានឃើញ និងជួបប្រទះ គឺប្រើវេទមន្តតាមរយៈទឹកក្តៅស្រោចលើអ្នកជំងឺ ហើយបានជាសះស្បើយជាច្រើននាក់ ។

លោក អៃ សម្បត្តិ គ្រូវេទមន្តព្យាបាលដោយទឹកក្តៅបានឱ្យដឹងថា កាលពីតូចគាត់បានបួសរៀន នៅវត្តសាសនរង្សី ក្នុងភូមិអំបិល ឃុំព្រះស្តេច ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ នៅឆ្នាំ១៩៥៦ លោកបានសឹកមកវិញ ហើយដើររៀនមន្តអាគមនេះរហូតចេះ ហើយត្រូវបានគេអញ្ជើញឱ្យទៅព្យាបាលគេជាញឹកញាប់ ។

លោក អៃ សម្បត្តិ បន្តថា នៅថ្ងៃមួយពេលគាត់មកធ្វើសន្និសុខនៅរោងចក្រកាត់ដេរក្នុងក្រុងភ្នំពេញ ក៏ជួបនារីម្នាក់ឈ្មោះ ឃុល សុផល ដែលត្រូវគ្រូចាមធ្វើអំពើ ហើយនារីនោះត្រូវគ្រូចាមតំរូវឱ្យរៀបទ្រនិបអស់ចំនួន៨០ដុល្លារ ។

លោកបន្តថា នាង ឃុល សុផល ពេលអស់សង្ឃឹមក៏រកលោកព្យាបាលតែ១សប្តាហ៍ក៏បានជាសះស្បើយដោយការព្យាបាលស្រោចទឹកក្តៅ និងបញ្ចូលមន្តអាគម ។ នាង សុផល នោះមានជំងឺមហារីកយូរហើយ នាងចេះតែថាគ្រូចាមធ្វើរហូតអស់សង្ឃឹមក្នុងជីវិត ។

ចាប់តាំងពីព្យាបាលនាង សុផល ជាមកមានពាក្យចចាមអារ៉ាមតៗគ្នា ធ្វើឱ្យលោក អៃ សម្បត្តិ មានឈ្មោះល្បី រហូតដល់សព្វថ្ងៃ តាមរយៈវេទមន្តដ៏អស្ចារ្យនេះ ៕

## ដល់ថ្ងៃភ្ជាប់ពាក្យរត់តាមសង្សារចាស់

*ដោយ : សម្ផស្ស*

នាងមេម៉ាយក្តៅស្រួយម្នាក់ ដែលទើបតែលែងថ្មីៗ ក៏យល់ព្រមភ្ជាប់ពាក្យជាមួយកំលោះនៅក្នុងអូរកណ្តាល ឃុំដងទង់ ស្រុកកំពត ខេត្តកំពត ។

ប៉ុន្តែ ការរៀបចំពិធីភ្ជាប់ពាក្យនោះ ពុំបានសំរេចទេ ដោយសារតែកូនក្រមុំរត់ចោលកូនកំលោះ ហើយទៅក្រេបទឹកឃ្មុំជាមួយសង្សារបាត់ទុកឱ្យក្រុមគ្រួសារខ្មាសអ្នកស្រុកពេញភូមិ ។

ស្ត្រីឈ្មោះ ស្រី អាយុ៤០ឆ្នាំ ដែលត្រូវជាម្តាយបានរៀបរាប់ថា គាត់ មានកូន២នាក់ គឺស្រី១ ឈ្មោះ អន និងកូនប្រុសម្នាក់ទៀត ដែលត្រូវ ប្តីស្លាប់ចោលជាច្រើនឆ្នាំមកហើយ ។

ស្ត្រីជាម្តាយបានបន្តថា នៅពេលស្រី អន អាយុ១៦ឆ្នាំ មានរូបរាង ស្រស់ស្អាត ក៏មានកំលោះក្នុងភូមិចូលស្តីដណ្តឹង ហើយគាត់ក៏រៀបការឱ្យ ។ នៅពេលរៀបការបាន៤ខែ ពួកគេទាំងពីរ នៅក្មេងពេកក៏ឈ្លោះទាស់ទែងលែងលះ ធ្វើឱ្យកូនគាត់មេម៉ាយទាំងវ័យក្មេងខ្ចី ។

ស្ត្រីរូបនោះបានបន្តទៀតថា ក្រោយពេលលែងលះគ្នាបាន១០ថ្ងៃ កំលោះ ចាន់ណា អាយុ២០ឆ្នាំ ក៏មកសុំស្នេហ៍ ហើយចូលដណ្តឹងតាមច្បាប់ ចំណែកកូនស្រីគាត់ក៏យល់ព្រមដែរ ។ នៅពេលនោះកូនស្រីគាត់ទៅធ្វើការនៅរោងចក្រក្រុងភ្នំពេញ ចំណែកកូនប្រសាមកបំរើការងារមិនឱ្យទាស់ចិត្តនោះទេ ។

លុះដល់ថ្ងៃភ្ជាប់ពាក្យមកដល់ ស្រី អន នោះបាននាំកម្មករមកពីភ្នំពេញ ឈ្មោះ រ៉ា អាយុ២៦ឆ្នាំ មានស្រុកកំណើតនៅខេត្តតាកែវ ដើម្បីចូលរួមក្នុងពិធីនោះដែរ ។

ប៉ុន្តែ នៅពេលរសៀលថ្ងៃរៀបចំភ្ជាប់ពាក្យ ស្រាប់តែកូនក្រមុំមេម៉ាយក្តៅស្រួយនោះ រត់តាមសង្សារទៅក្រេបទឹកឃ្មុំនៅភ្នំពេញបាត់ ។ ចំណែកឯកូនកំលោះ ចាន់ណា បានត្រឹមតែទឹកភ្នែក ហើយបាននិយាយថា គេនៅតែស្រលាញ់នាងដដែល ៕

# អ្នកនយោបាយផ្លាស់ប្តូរ...

ថា ពួកគេគ្មានតម្លៃ ។

លោក សម រង្ស៊ី បន្តថា នៅពេលថ្ងៃក្រោយ ពួកគេនឹងនិយាយថា គណបក្សប្រជាជនកម្ពុជាអាក្រក់ទៀតហើយ ។

លោក ជាម យៀប សមាជិកសភាគណបក្សប្រជាជនកម្ពុជា បានអះអាងថា គោលនយោបាយបច្ចុប្បន្នអ្នកដែលផ្តាច់ខ្លួននយោ-បាយម្នាក់មកចូលជាមួយយើង ដែលជាសមាជិកសភា ឬគណៈ-កម្មាធិការនាយកនឹងទទួលបានតួនាទីជាទីប្រឹក្សារដ្ឋាភិបាល ។

ដោយឡែកលោក ហង្ស ពុទ្ធា នាយកគណៈកម្មាធិការអព្យា-ក្រឹត្យ និងឯករាជ្យសំរាប់ការបោះឆ្នោត ដោយសេរីនៅកម្ពុជាបានឱ្យដឹងថា ការផ្តាច់ខ្លួនរបស់អ្នកនយោបាយទាំងនោះ មិនធ្វើឱ្យប៉ះពាល់ដល់គណបក្សប៉ុន្មាននោះទេ ។ ប៉ុន្តែ បើមានកាន់តែច្រើន នឹងធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់អ្នកបោះឆ្នោតមួយចំនួនដែរ ។

ការផ្តាច់ខ្លួនរបស់អ្នកនយោបាយទាំងនេះ ត្រូវអ្នកវិភាគនយោ-បាយមួយចំនួនថា គឺជាការដឹកកប់ខ្លួនឯង នៅពេលអនាគតអ៊ីចឹង ។ ពេលនេះ គណបក្សប្រជាជនកម្ពុជាបានរកយុទ្ធសាស្ត្រជាច្រើន ដើម្បីបំបែកកំលាំងអ្នកប្រជាធិបតេយ្យ តាមរយៈផ្តល់លាភសក្ការៈ និងតួនាទីក្នុងរាជរដ្ឋាភិបាល ។

ចលនានៃការរត់ចាកចេញពីបក្សមួយទៅបក្សមួយជា ពិសេសអ្នកតំណាងមកពីគណបក្ស សម រង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច ទៅចុះចូលជាមួយគណបក្សប្រជាជន ។ ទង្វើរនេះ មិនខុសប្លែកពីលោក ដួង ខែម, ទន់ ចាយ, អ៊ុង ផន បំបែកខ្លួន ពីគណបក្សហ៊្វុនស៊ិនប៉ិច និងលោក ងួន សឿ, គង់ មុនី បំបែកខ្លួនពីបក្ស សម រង្ស៊ី ទីបំផុតពួកគេគ្មានសល់អ្វីបន្តិចនោះទេ ។

ពួកអ្នកផ្តាច់ខ្លួនចេញពីបក្សដែលធ្លាប់តែស្មោះ និងមានប្រវត្តិជូរចត់ពីអតីតកាល ហើយទៅចុះចូលជាមួយគណបក្សប្រជាជនទៅវិញ ។ ពួកគេធ្លាប់បានសន្យាជាមួយប្រជាពលរដ្ឋថា នឹងស្វែងរកលទ្ធិប្រជាធិបតេយ្យជូនជាតិមាតុភូមិស្អប់ខ្ពើមរបបកុម្មុយនីស្តផ្តាច់ការរាប់ឆ្នាំមកហើយ ។ មិនទាន់បានប៉ុន្មានឆ្នាំផង ពួកគេក្បត់នឹងការសន្យាក្បត់នឹងឧត្តមគតិរបស់ខ្លួនអស់ ។ បញ្ហានេះ ប្រជា-ពលរដ្ឋពិបាកជឿអ្នកនយោបាយណាស់ ម្តងថាល្អ ម្តងថាអាក្រក់ ។

ការចុះចូលរបស់អ្នកតំណាងរាស្ត្រ និងមន្ត្រីជាន់ខ្ពស់នៃគណបក្សទាំងពីរ ទៅរស់នៅជាមួយគណបក្សប្រជាជននេះ ជាយុទ្ធសាស្ត្ររបស់ពួកកុម្មុយនីស្ត ក្នុងការបំបែកកំលាំងអ្នកប្រជាធិបតេយ្យមួយចំនួន ដែលសម្លឹងបុណ្យស័ក្តិ និងអំណាចប៉ុណ្ណោះ ។

ពួកគេមើលពីចំណុចខ្លាំងរបស់អ្នកតំណាងរាស្ត្រមួយចំនួននោះ ដែលមានភាពជិតស្និតជាមួយប្រជាជន យុវជន និងធ្វើឱ្យបក្សមានប្រជាប្រិយភាពគណបក្សប្រជាជនកម្ពុជាក៏រកវិធីបំបែកតែម្តង ។

លោក ទូវ សុវត្ថិ៍ អ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិចបានឱ្យដឹងថា ការដើរចេញពីបក្សរបស់បុគ្គលមួយចំនួននោះ វាមិនខុសប្លែកពីត្រី ដែលចង់បំផ្លាស់ទី ដើម្បីចង់ដឹងពីរសជាតិថ្មីនោះទេ ។ មនុស្សក៏មិនខុសប្លែកពីសត្វដែរ គេផ្លាស់ប្តូរនយោបាយ ដើម្បីចង់ដឹងពីរសជាតិនយោបាយថ្មីប៉ុណ្ណោះ ។

លោកស្រី មូរ សុខហួរ អគ្គលេខាធិការរងគណបក្ស សម រង្ស៊ី បានធ្វើការចោទប្រកាន់ថា គណបក្សប្រជាជនកម្ពុជា កំពុងតែមានយុទ្ធសាស្ត្របំផ្លាញគណបក្សដទៃ ។

លោកស្រីបន្តថា គណបក្ស សម រង្ស៊ី មិនធ្លាក់ចូលទៅក្នុងអន្ទាក់នេះទេ ។ អ្នកដែលចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា គឺត្រូវទទួលខុសត្រូវនេះជាអសីលធម៌ណាស់ ។ លោក រស់ ចន្ទ្រាបុត្រ អនុប្រធានរាជបណ្ឌិត សភាកម្ពុជាបាននិយាយថា អ្នកនយោបាយខ្មែរ ហាក់ដូចជានៅមិនទាន់ចាស់ទុំ ដូចអ្នកនយោបាយ នៅប្រទេសជឿនលឿនសោះ ។ ការផ្លាស់ប្តូរជំហររបស់អ្នកនយោបាយមួយចំនួននោះ គឺជាការក្បត់នឹងឧត្តមគតិខ្លួនឯងទៅវិញទេ ៕

# ចាប់ខ្លួនជនគំរាមស្ថានទូត...

ជួលផ្ទះស្នាក់នៅរយៈពេលវែង ។ ប៉ុន្តែនៅបន្ទាប់ពីចេញពីកន្លែងអ៊ីនធើរណិត ត្រូវសមត្ថកិច្ច ចាប់ខ្លួនតែម្តង ។

លោក ចូសេហ្វ មូសូមេលី ឯកអគ្គរដ្ឋទូតអាមេរិក បានឱ្យដឹងថា នៅពេលគាត់ទទួលបានព័តិមានភ្លាម ក៏រាយការណ៍ប្រាប់សមត្ថកិច្ចជាបន្ទាន់ ដើម្បីស្រាវជ្រាវចាប់ខ្លួនជនសង្ស័យ ។

លោក ប៊ូសេហ្វ មូសូមេលី បន្តថា ទោះបីជាមានការគំរាមកំហែងយ៉ាងនេះក្តី លោកគ្មានការព្រួយបារម្ភទេ ពីព្រោះនេះជារឿងកំប៉ិកកំប៉ុកប៉ុណ្ណោះ ។ ពេលនេះជនល្មើសត្រូវបានចាប់ខ្លួនឃុំនៅជំរំអន្តោប្រវេសន៍បណ្តោះអាសន្នចង់ចាំបញ្ជូនខ្លួនទៅសហរដ្ឋអាមេរិកវិញ ។

បញ្ហាចាប់ខ្លួនអ្នកគំរាមតាមអ៊ីម៉ែលទៅលើស្ថានទូតនេះ ទាំងលោកឯកអគ្គរដ្ឋទូត ក៏ដូចជាមន្ត្រីអ្នកនាំពាក្យដែរ គឺសុំមិនធ្វើអត្ថាធិប្បាយទេ ពីព្រោះ នេះជាសិទ្ធិរបស់បុគ្គលដរាបណាគ្មានការអនុញ្ញាតពីសាម៉ីជន ៕

# ជួបអ្នកនិពន្ធបទ...

នៅក្នុងវគ្គទី៣ និងទី៤ ដែលបង្ហាញនូវឃ្លាថា "ខ្ញុំលើកហត្ថាទាំង២ប្រណម សូមអស់ឥន្ទ្រព្រហ្មៗ មេត្តាករុណាដល់ជីវិតសត្វលោករស់ក្នុងលោកា ឈឺផ្សាឥតល្ហែៗ ឥតមានឈប់ឈរ ។ សូមលោកប្រមើលមើលសព្វទិស តើសត្វលោកណាៗ កំពុងវេទនា សូមប្រោសប្រទានៗឱ្យបានភ្លឺថ្លា ប្រាថ្នាសូមរស់ៗក្នុងសន្តិភាព" ។ អ្នកនិពន្ធចង់ប្រាប់ដែរថា សូមឱ្យប្រទេសកម្ពុជាមានសុខសន្តិភាព ដើម្បីខ្មែរគ្រប់រូបរស់រានមានជីវិតក្នុងភាពសុខសាន្ត រួចចាកផុតពីទុក្ខសោកចង្រៃនៃការភៀសខ្លួនក្នុងភ្លើងសង្គ្រាម ។

ពិសេសអតីតជនភៀសខ្លួនខ្មែរ នៅតាមជំរំព្រំដែនថៃ ដែលមនុស្សរាប់សែននាក់ បានជ្រកកោន តាមគុម្ពោធព្រៃភ្នំ ដោយភាពឈឺផ្សារងទុក្ខយ៉ាងវេទនាក្នុងជីវភាពរស់នៅ ដែលអ្នកផងទាំងពួងបានបាត់បង់ជីវិត ព្រោះតែការរត់កាត់គ្រាប់រំសេវ និងការដើរជាន់គ្រាប់មីន រួមទាំងការធ្វើបាបពីសំណាក់ពួកសៀមយ៉ាងព្រៃផ្សៃទៀតផងនោះ ។

ដោយអតីតបងប្អូនខ្មែរ ត្រូវរស់ក្រោមពាក្យសុភាសិតមួយពោលថា "ចុះទឹកក្រពើឡើងលើខ្លា" ។ ពេលនោះជាទឹកភ្នែកនៃក្តីវេទនា ពេលនឹកស្រុកម្តងៗ លុះមកដល់តាំងទីលំនៅថ្មីលើទឹកដីគេក្នុងការកសាងជីវិតថ្មី ទឹកភ្នែកបានស្រក់ម្តងទៀត ដែលជីវិតកាន់តែរសាត់ឆ្ងាយទៅៗ ដូច "ចករសាត់តាមទឹក" ។

ក្នុងក្តីរលឹកនឹកស្រុក មិនដឹងថ្ងៃណាមួយនឹងមានវាសនាទៅនៅ ឬទៅលេងស្រុកកំណើត ព្រោះនយោបាយប្រទេសជាតិត្រូវធ្លាក់ក្នុងកណ្តាប់ដៃយួនត្រួតត្រា ដែលគ្មានអ្វីក្រៅពីលើដៃប្រណមបន់ស្រន់ព្រះឥន្ទ្រ ព្រះព្រហ្ម សូមប្រោសប្រទាននូវសុខសន្តិភាព ឱ្យខ្មែរមានសេរីភាពរស់នៅជួបជុំ ដោយការសប្បាយក្នុងជីវិត ។

អ្នកនិពន្ធបទនេះ គឺលោក ឆាន ឈូ បច្ចុប្បន្នជាអ្នកគ្រប់គ្រងបញ្ចូលសម្លេងកុនថៃ "មយូរា" ដោយលោកលើកឡើងថា បំណងនៃការនិពន្ធបទចម្រៀងនេះ គឺចង់បង្ហាញ និងប្រាប់ថា ពីការអស់សង្ឃឹមក្នុងឆាកជីវិត ដែលគ្មានថ្ងៃវិលត្រឡប់ទៅស្រុកកំណើតខ្លួនវិញទេ។

ក្នុងផ្លូវលំបាកនៃជីវភាពគ្រួសារ និងការឃ្លាតឆ្ងាយ ស្រុកព្រាត់ញាតិផៅសន្តាន ដើម្បីឱ្យធូរទ្រូងពីការគិតតែប៉ុណ្ណោះ ដោយមិនដឹងថា បទចម្រៀងនេះ មកដល់សព្វថ្ងៃត្រូវបានកំពុងពេញនិយមផ្សាភ្ជាប់ក្នុងបេះដូងខ្មែរ ដែលផ្តិតទុកជាប្រវត្តិសាស្ត្រពីអតីតកាលយ៉ាងដូច្នេះនោះទេ ។

ប្រទេសកម្ពុជា បានទទួលនូវសន្តិភាពឡើងវិញ ក្រោយពីសង្គ្រាមកើតមានរ៉ាំរ៉ៃជាង២០ឆ្នាំ ត្រូវបញ្ចប់ដោយកិច្ចព្រមព្រៀងក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ នៃភាគីខ្មែរទាំង៤បក្ស គឺចតុភាគី "សីហនុ, សឺន សាន, ហ៊ុន សែន, ខៀវ សំផន" ។

រហូតកើតមាននូវការបោះឆ្នោតសកលបែបសេរីពហុបក្សក្នុងផ្លូវលទ្ធិប្រជាធិបតេយ្យ ក្រោមការត្រួតត្រាដោយអង្គការសហប្រជាជាតិ ហៅកាត់ថា UNTAC ក្នុងអំឡុងឆ្នាំ១៩៩៣ ដែលជាថ្ងៃនៃមនុស្សម្នារីករាយក្នុងផ្លូវចិត្តឡើងវិញ បន្ទាប់ពីភាពប្រេះស្រាំក្នុងបេះដូង ដែលជួបតែភាពខ្លោចផ្សាក្នុងជីវិត ក្រោមជម្រកនៃភ្លើងសង្គ្រាម ។

ជនភៀសខ្លួនដែលបន្សល់ពីអ្នកចំណាកស្រុក ដូចគ្នា បានទៅរស់នៅក្រៅប្រទេសមានអាមេរិក បារាំង កាណាដា អូស្ត្រាលី ។ល។ និង ។ល។ និងក៏បានធ្វើមាតុភូមិនិវត្តន៍ចូលទៅកាន់ស្រុកកំណើតវិញដោយក្តីរំភើប ព្រោះតែស្រុកត្រូវចប់សង្គ្រាមហើយ យួនបានដកចេញពីស្រុកខ្មែរហើយដែរ ការច្បាំងនៅតាមជំរំក៏ត្រូវបញ្ចប់ លែងមានការរត់លូនគេចគ្រាប់រំសេវ និងបាត់ការហិតក្លិនឈ្ងៀមរំសេវបន្តទៀតនោះ ។ ពីពេលនោះ មកគេឃើញឯកសារជាប្រវត្តិសាស្ត្រ ជា CD, VCD ឬ DVD ក្តី គ្មានឯកសារអតីតកាលណា ដែលថា មិនដាក់បញ្ចូលនូវបទចំម្រៀង **"ស្រណោះដីខ្មែរ"** នោះទេ ។ ព្រោះជាមនោរម្មណ៍ ដែលផ្តិតជាប់ក្នុងខួរក្បាល និងបេះដូងខ្មែរគ្រប់ៗរូប ដែលឆ្លងកាត់ក្នុងឆាកជីវិតដ៏វេទនាបំផុត ស្ទើរតែមិនមានជីវិតរស់នៅមកដល់សព្វថ្ងៃ ពិសេសក្នុងរបបបនប្រល័យពូជសាសន៍ គ្មានអ្នកណាមួយគិតថា "ខ្លួនអាចគេចផុតពីសេចក្តីស្លាប់នឹងត្បូងចប, ការប្រើធ្វើការហួសកំលាំង, បង្អត់បាយក្រហាយទឹក ជាមួយទារុណកម្មយ៉ាងព្រៃផ្សៃ ក្នុងរនាំងគុកឥតជញ្ជាំងនោះ ។ ដូច្នេះ បទនេះ គឺជាអនុស្សាវរីយ៍នៃយើងគ្រប់រូបមិនអាចបំភ្លេចបាន ។

ឆាន ឈូ បានក្លាយខ្លួនជាអ្នកនិពន្ធបទចម្រៀងនេះ ឱ្យលោក កែវ សារ៉ាត់ ច្រៀង ក្នុងឆ្នាំ១៩៨៥ ជាមួយបទចម្រៀងមួយបទទៀតគឺ **"បទពិសាខដើមឆ្នាំ ខ្មែរតែងចំណាំធ្វើស្រែចំការ"** ដែលបទទាំងពីរ បានធ្វើឱ្យជីវិតគាត់ បានកែប្រែជីវិតថ្មីទៀត ដោយរស់ក្នុងភាពហ៊ឺហារ សប្បាយចាយវាយ ក្នុងទឹកប្រាក់ដែលលក់បទចម្រៀង បានពីគំនិតបញ្ញាញាណជាអ្នកនិពន្ធ ។

ឆាន ឈូ បានបោះបង់ចោល នូវជីវិតជាអ្នកបេះផ្លែឈើស៊ីឈ្នួលគេ នៅតំបន់ Stockton ដែលមានខ្មែររស់នៅរាប់ម៉ឺននាក់ ឱ្យក្លាយខ្លួន ជាអ្នកបញ្ចូលសម្លេងកុនឱ្យក្រុមដទៃ រហូតឱ្យក្រុមហ៊ុនខ្លួនឯងផ្ទាល់តែម្តង។

ដោយ ឆាន ឈូ បានដាក់ឈ្មោះក្រុមហ៊ុនបញ្ចូលសម្លេង **"មយូរា"** ជាឈ្មោះមានលាភជោគជ័យ តាំងពីបង្កើតរកស៊ីកាសែតចម្រៀង ម៉ាញ៉េ ។

បទចម្រៀងជាង៤០បទ ដែលរូបលោកបាននិពន្ធឱ្យលោក កែវ សារ៉ាត់ ច្រៀងក្នុងទសវត្សរ៍ពាក់កណ្តាលឆ្នាំ៨០ និងដើមទសវត្សរ៍ឆ្នាំ៩០ មុនការលាចាកឋានទៅរបស់លោក កែវ សារ៉ាត់ ក្នុងឆ្នាំ១៩៩១ នោះ ។

ជាអ្នកស្រុកស្រែចំការ នៅតំបន់គាស់ក្រឡ ខេត្តបាត់ដំបង ឆាន ឈូ បានដាក់ចិត្ត ដាក់កាយ ក្លាយជាអ្នកបួសអ្នករៀនចំនួន៦ព្រះវស្សា ចុង

( តទៅទំព័រទី២៩ )

# ចាប់ខ្លួនជនគំរាមស្ថានទូតអាមេរិក តាមអ៊ីម៉ែល

**កម្ពុជា : គីម សារឿន**

អតីតទាហានអាមេរិកចូលនិវត្តន៍ម្នាក់ ដែលមានការអាក់អន់ស្រពន់ចិត្តនឹងរដ្ឋាភិបាលរបស់ខ្លួនថា មិនបានគិតគូរពីប្រាក់ចូលនិវត្តន៍ ក៏សរសេរអ៊ីម៉ែលគំរាមវាយប្រហារស្ថានទូតអាមេរិកប្រចាំនៅក្រុងភ្នំពេញ ។



លោក ចូសេហ្វ មូសូមេលី ឯកអគ្គរដ្ឋទូតអាមេរិក

ការគំរាមកំហែងតាមអ៊ីម៉ែលនេះ ត្រូវបានបែកធ្លាយ ហើយសមត្ថកិច្ចប៉ូលិសក៏បានឃាត់ខ្លួនជនសង្ស័យនោះ នៅយប់ថ្ងៃទី១៩ខែកុម្ភៈ រួចធ្វើរៀបចំបញ្ជូន ខ្លួនមកកាន់សហរដ្ឋអាមេរិកវិញ ។

ប៉ូលិសក្រសួងមហាផ្ទៃបានឱ្យដឹងថា បន្ទាប់ពីទទួលបានព័ត៌មានពីស្ថានទូតអាមេរិក ប្រចាំក្រុងភ្នំពេញថា មានការគំរាមកំហែងចង់ធ្វើការវាយប្រហារស្ថានទូតរួចមក ។ សមត្ថកិច្ចក៏បានសហការគ្នាការពារសណ្តាប់ធ្នាប់ស្ថានទូត និងស្រាវជ្រាវរកចាប់ខ្លួនជនល្មើស បាននៅយប់ថ្ងៃទី១៩ ខែកុម្ភៈ ហើយបញ្ជូនទៅនាយកដ្ឋានអន្តោប្រវេសន៍ ។

ប្រភពខាងលើបន្តថា ជនល្មើសនោះឈ្មោះ Gerald Fores អាយុ៦៣ឆ្នាំ ជាអតីតកងទ័ពអាមេរិក ។ នៅពេលចាប់ខ្លួនប្រភពខាង លើបន្តថា ជនល្មើសនោះឈ្មោះ Gerald Fores បានសារភាពថា គាត់ពិតជាបានសរសេរអ៊ីម៉ែលគំរាមកំហែងស្ថានទូតមែន ។ ដោយសារតែខឹងនឹងរាជរដ្ឋាភិបាលអាមេរិក ដែលពុំបានគិតគូរពីប្រាក់សោធនិវត្តន៍របស់គាត់ឱ្យបានត្រឹមត្រូវ ។

លោក Gerald Fores បន្តថា គាត់មកប្រ-ទេសកម្ពុជា ក្នុងនាមជាអ្នកទេសចរ ហើយបាន

( តទៅទំព័រទី៣១ )

# គណបក្សខ្មែរមួយយក...

បើទោះបីការបង្ហាញនោះ ជាទស្សនៈ ឬជាការមើលឃើញពីអ្នកនយោបាយ ឬអ្នកសេដ្ឋកិច្ចខុសៗគ្នាពីកម្ពុជាថា កំពុងតែរីកចំរើនផ្នែកសេដ្ឋកិច្ចជាតិក្នុងវិស័យវិនិយោគទុន និងវិស័យទេសចរណ៍ ។ នៅខណៈដែលស្ថានការណ៍រីករាលនៃជម្លោះរំលោភដីធ្លី, ការកាប់បំផ្លាញព្រៃឈើ និងអំពើពុករលួយជាមួយការហូរចូលជនជាតិយួនខុសច្បាប់ មករស់នៅកម្ពុជាមិនទាន់ត្រូវបានដោះស្រាយក៏ដោយ ។

ប៉ុន្តែ សំរាប់នយោបាយការទូតក្រៅប្រទេស ដូចជាសហរដ្ឋអាមេរិក មានការខកចិត្តណាស់ចំពោះល្បឿននៃដំណើរការកែទម្រង់នៅក្នុងប្រ-ទេសកម្ពុជា ។

កាលពីថ្ងៃពុធ ពីរសប្តាហ៍កន្លងទៅ រដ្ឋមន្ត្រីក្រសួងការបរទេស ដ៏មានឥទ្ធិពលនយោបាយក្នុង និងក្រៅប្រទេសអ្នកស្រី ខុន ដូលីហ្សារ៉ាយស៍ បានជំរាបអ្នកតំណាងរាស្ត្រថា សហរដ្ឋអាមេរិក ចង់ឃើញប្រទេសកម្ពុជា មានការរីកចំរើនប្រសើរជាងសព្វថ្ងៃនេះ ។

ប៉ុន្តែ សំដីរដ្ឋមន្ត្រីការបរទេសអាមេរិកនេះ ត្រូវអ្នកនាំពាក្យរាជរដ្ឋាភិបាលលោក ហ៊ុន សែន ច្រានចោលថា ការសន្និដ្ឋានរបស់លោកស្រី រ៉ាយស៍ គឺធ្វើឡើងតាមប្រភពព័ត៌មានខុស ។ ដោយលោកព្រមានថា គួរតែពិនិត្យឡើងវិញ បើសិនជាប្រ-ទេសខ្មែរ បើសិនរដ្ឋាភិបាលឥឡូវផ្លាស់ប្តូរបានតិចតួច មិនងាយបានឈ្នះសន្លឹកឆ្នោត រហូតដល់ឥឡូវនេះនោះទេ ។ ដោយចោទប្រកាន់ថា ការលើកឡើងរបស់រដ្ឋមន្ត្រីការបរទេសអាមេរិក គឺអាចធ្វើឡើងតាមការជំរុញរបស់អ្នកប្រឆាំងរដ្ឋា-ភិបាល នៅមុនការបោះឆ្នោតជិតចូលមកដល់ ។ ក្រុមអង្គការក្រៅរដ្ឋាភិបាល និងគណបក្សប្រឆាំងបានអះអាងថា យើងគួរតែមើលជុំវិញខ្លួនឯង ពីការកែទម្រង់ ការដឹកនាំរបស់ខ្លួន ជាជាងការឆ្លើយតបប្រតិកម្មបញ្ច្រាស់ទិសដៅ ។ ខណៈដែលកម្ពុជានៅតែត្រូវការពឹងជំនួយបរទេស ដើម្បីអភិវឌ្ឍន៍ និងដោះស្រាយបញ្ហាក្រីក្រ ដែលកំពុងតែញាំញីនៅឡើយ ។

ប្រជារាស្ត្រខ្មែរកំពុងប្រឈមមុខ នាពេលបច្ចុប្បន្ននេះដែរ គឺអតុល្យភាពរវាងប្រាក់ចំណូល និងសេចក្តីត្រូវការ ក្នុងការផ្គត់ផ្គង់ជីវភាព ដែលទំនិញសព្វសារពើ នៅលើទីផ្សារកំពុងឡើងថ្លៃខ្ពស់ ។ ធនាគារពិភពលោក ធ្លាប់បានក្រើនរំឭកឱ្យរដ្ឋាភិបាល ត្រូវតែតាមដានដោយយកចិត្តទុកដាក់ អំពីការកើនឡើងនៃវិសមភាពរវាងអ្នកមាន និងអ្នកក្រ ជាពិសេសនៅតាមទីជនបទ ។ ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាប្រទេសក្រីក្រមួយ ក្នុងចំណោមប្រទេសក្រីក្រនៅលើពិភពលោក ដែលត្រូវបានគេរកឃើញថា មានជាប់ពាក់ព័ន្ធទៅនឹងអំពើពុករលួយ ដែលជាមូលហេតុនៃភាពក្រីក្ររបស់ប្រទេស ។

ក្រោយពីការបោះឆ្នោតអាណត្តិទី៤ គេពុំដឹងថា រដ្ឋាភិបាលថ្មី ពិតជាមានឆន្ទៈកសាងជាតិ ឬចង់កែទម្រង់របៀបដឹកនាំយ៉ាងណានោះទេ ? ដើម្បីបំបាត់ភាពក្រីក្ររបស់ប្រជាជន អំពើបំពានដីធ្លី ដែលជាដង្ហើមជីវិតសំរាប់រស់ក្នុងនាមជាមនុស្សអ្នកស្រែចំការ ៕

# ចិន_យួនដេញខ្មែរ ..

បើដីនៅជាប់ផ្លូវលំតំលៃពី១៥០០ទៅ៣០០០ដុល្លារ។

ចំណែកផ្ទះនៅទីប្រជុំជនមួយល្វែងតំលៃចាប់ពី ៥ ម៉ឺនទៅ១៥ម៉ឺនដុល្លារអាមេរិក។

ដោយសារតែមានគំរូវការសាងសង់ច្រើន បានធ្វើឱ្យតំលៃដី និងផ្ទះ កើនឡើងយ៉ាងខ្ពស់ ។ សព្វថ្ងៃនេះ មានក្រុមហ៊ុនដែលចូលមកវិនិយោគផ្នែកសាងសង់យ៉ាងច្រើន ជាពិសេសក្រុមហ៊ុនកូរ៉េ ។ ការកើនឡើងនេះ ត្រូវបានអ្នកជំនាញសន្និដ្ឋានថា ដី និងផ្ទះឡើង រយៈពេល៥ឆ្នាំជាប់ៗគ្នា ប៉ុន្តែមិនខ្លាំងដូចឆ្នាំនេះទេ ។

យោងតាមទស្សនាវដ្ដីសេដ្ឋកិច្ចថ្ងៃនេះ បានបញ្ជាក់ថា ការកើនឡើងនៃតំលៃផ្ទះ និងដី នៅក្នុងប្រទេសកម្ពុជាបណ្ដាលមកពីមានចលនានៃការទិញ និងលក់ដីធ្លី ច្រើនឥតឈប់ឈរ និងសំណង់អគារការិយាល័យកាន់តែច្រើន ដោយអ្នកទិញខ្លះ ទិញទុកសំរាប់ចំណេញបន្ត ។

លោក សឹង ប៊ុណ្ណា នាយកប្រតិបត្តិរបស់ក្រុមហ៊ុនប៊ុណ្ណារៀលធី ក្រុមហ៊ុនប្រចាំប្រទេសកម្ពុជារបស់ក្រុមង៉ុយមួយឃ្លាថា "នគរថ្មើងប្លែកសប្បាយតែភ្នែកក្នុងចិត្តរងកម្ម" ។ មានន័យថា ប្រជាជនខ្មែរសព្វថ្ងៃកំពុងភ័យផង អរផង ចំពោះការអភិវឌ្ឍទាំងនេះ ។

ជនបរទេសមួយចំនួន ជាកម្មសិទ្ធម្ចាស់ដី ម្ចាស់សំណង់ ហើយខ្មែរដែលជាម្ចាស់ស្រុក កំពុងប្រឈមមុខនឹងបញ្ហានេះ ។ ដោយអ្នកក្រុងបានលក់ដី និងផ្ទះទៅទិញនៅតាមជនបទ រីឯអ្នកជនបទលក់ដីទៅរស់នៅក្នុងព្រៃគួរឱ្យខ្លាច ។

ការដែលពួកបរទេសមករកស៊ីស្រុកខ្មែរ វាជារឿងល្អមួយឱ្យយើងជាម្ចាស់ស្រុកកាន់តែមានការងារធ្វើច្រើន ។ ប៉ុន្តែ ការជួលដីធ្លីខ្មែររបស់ជនបរទេសសំរាប់រកស៊ី វាជារឿងមួយស្របតាមច្បាប់ទីផ្សារសេរី ។

សព្វថ្ងៃគេឃើញជនបរទេសខ្លះ មានសិទ្ធិកាន់កាប់ដីធ្លី វាហាក់ដូចជា ធ្វើអត្តឃាត និងប្រមាថចំពោះជាតិសាសន៍ខ្មែរអីចឹង។ មិនយូរមិនឆាប់ទីក្រុងភ្នំពេញ និងតំបន់មួយចំនួន សំបូរទៅដោយជនបរទេស ព្រោះពួកគេមានលុយអាចធ្វើអ្វីៗសព្វបែបយ៉ាង ។



ប្រជាកសិករកំពុងស្ទូងស្រូវនៅលើដីរបស់ក្រុមហ៊ុន

បានឱ្យដឹងថា ដីធ្លី ផ្ទះល្វែង និងការសាងសង់ផ្ទះល្វែងសំណង់អគារកាន់តែមានសន្ទុះខ្លាំងក្លាឡើង ។ ដំណើរនេះ នឹងបន្តរយៈពេល៥ឆ្នាំខាងមុខទៀត មិនមានការប្រែប្រួលទេ បើទោះបីមានការថយចុះនូវតំលៃ ក៏ល្បឿននោះមិនលឿនដែរ ។

លោក សឹង ប៊ុណ្ណា បានបន្តថា អគារល្វែងនៅតាមដងវិថីព្រះស៊ីសុវត្ថិ ជួរមាត់ទន្លេ អគារកំពស់ ៤ទៅ៥ជាន់ គឺមានតំលៃមធ្យមពី៣០០.០០០ ទៅ ៤០០.០០០ដុល្លារ ។ ចំណែកអគារផ្ទាល់ដីមានតំលៃចាប់ពី១២០.០០០ ទៅ១៨០.០០០ដុល្លារ ។ រីឯជាន់លើតំលៃពី៥០.០០០ទៅ៧០.០០០ដុល្លារ ។

លោក អ៊ុំ វុត្ថា តំណាងផ្នែកលក់អចលនទ្រព្យនៃក្រុមហ៊ុនអង្គររៀលធី បានឱ្យដឹងថា រយៈពេលប៉ុន្មានខែចុងក្រោយនេះ តំលៃអចលនទ្រព្យបានកើនឡើងប្រមាណ១០ទៅ១៥% ។ ការកើនឡើងនេះ បណ្ដាលមកពីមូលហេតុ៣យ៉ាង គឺ ១-សុវត្ថិភាពសង្គម, ២-សេដ្ឋកិច្ចមានការកើនឡើង និងទី៣-ចំនួនអ្នកវិនិយោគចូលមកប្រទេសកម្ពុជាច្រើន ។

លោកបន្តថា អ្នកទិញដីនៅស្រុកខ្មែរ គេចែកជា ៤ប្រភេទគឺ អ្នកទិញទុកលក់៥% មន្ត្រីរាជការ១០% អានិកជនខ្មែរនៅបរទេស៥% អ្នករកស៊ីផ្នែកអចលនទ្រព្យ៣០% និងប្រជាជនធម្មតា៥០% ។

នៅពេលដែលសំណង់ផ្ទះល្វែង និងអគារខ្ពស់ៗរីកព្រោងព្រាតនេះ យើងនឹកឃើញដល់ពាក្យទូន្មាន

ដោយសារតែដីឡើងថ្លៃ តុលាការមិនសូវយកច្បាប់ជាគោលនោះទេ គេសង្កេតឃើញប្រជាជននៅគ្រប់ខេត្ត-ក្រុង មានទំនាស់ដីធ្លីមិនចេះចប់ជាមួយអ្នកមានលុយមានអំណាច ។ ទីបំផុតពួកគាត់រត់ចុះឡើងប្ដឹងផ្ដល់ចាញ់ក្ដី អត់ទាំងផ្ទះសំបែងមកប្ដឹងដល់រដ្ឋសភា នៅតែពុំឈ្នះពួកនាយទុនទៀត ។ ប្រជាពលរដ្ឋខ្លះ ត្រូវគេចាប់ដាក់គុក គេបាញ់ ធ្វើទារុណកម្ម និងបង្ខំឱ្យរុះរើលំនៅដ្ឋានជាដើម ។

ជាឧទាហរណ៍ យោងតាមរបាយការណ៍របស់សមាគម អាដហុក បានបញ្ជាក់ថា មានដីទំនាស់យ៉ាងក្ដៅគគុករវាងអាជ្ញាធរ និងប្រជាពលរដ្ឋចំនួន ៣១៧គ្រួសារ នៅភូមិអូរឈើទាល ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧នោះ កម្លាំងសមត្ថកិច្ចបានបាញ់ប្រជាពលរដ្ឋស្លាប់២នាក់, ៦នាក់រងរបួសធ្ងន់ និង១៨នាក់ជាប់ពន្ធនាគារ ។

ចំណែកឯបងប្អូនជនជាតិព្នង និងជនជាតិផ្សេងៗ នៅខេត្តមណ្ឌលគិរី និងរតនគិរី ក៏មានទំនាស់រឿងដីធ្លីដូចគ្នាដែរ ។ ពួកគេក៏បានលើកគ្នាមកប្ដឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យជួយដល់ភ្នំពេញ ។

បើយោងតាមទស្សនាវដ្ដីសេដ្ឋកិច្ចថ្ងៃនេះ បានដកស្រង់សំដីសេដ្ឋវិទូ និងអង្គការសង្គមស៊ីវិលថា គឺដល់ពេលវេលា បើកយុទ្ធនាការអប់រំប្រជាពលរដ្ឋពីផលលំបាកនៃការលក់ដីស្រែចំការហើយ ។ គេមិនអាចហាមឃាត់ប្រជាពលរដ្ឋមិនឱ្យលក់ដីបានទេ ប៉ុន្តែ ត្រូវណែនាំពួកគេឱ្យយល់ដឹងពីផលវិបាកនៃការលក់ដីស្រែចំការវាស់ ។

លោក សឹង ប៊ុណ្ណា នាយកភ្នាក់ងារអចលនទ្រព្យឈ្មោះ ប៊ុណ្ណារៀលធី បានសំណូមពរថា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល គួរបង្កើតកម្មវិធីអប់រំដល់កសិករ ដើម្បីឱ្យពួកគាត់ចេះកែច្នៃលុយដែលបានមកពីដីសំរាប់ថ្ងៃអនាគត ។

លោក សុខ ស៊ីណា សេដ្ឋវិទូឯករាជ្យ បានបញ្ជាក់ជា

( តទៅទំព័រទី២៨ )

## សមាគមអរិយធម៌ខ្មែរ

មានកិត្តិយសនឹងជូនដំណឹងដល់បងប្អូនខ្មែរយើងដែលមានភាពអត្តខាត់ ហើយមានកូនចៅកំពុងសិក្សារៀនសូត្រនៅតាមសាលានានា ចាប់តាំងពីថ្នាក់ទី១ ដល់ ថ្នាក់ទី១២ ថា សមាគមយើងមានបំណងនឹងចែកជូននូវ សម្ភារៈប្រើប្រាស់ជាច្រើនមុខ ដូចជា សម្ភារៈសិក្សា និង សម្ភារៈការិយាល័យ ជាដើម ជារៀងរាល់ខែ ដោយឥតគិតថ្លៃ ។

ដូច្នេះ ដើម្បីរក្សា ភាពទៀងទាត់ ភាពថ្លៃថ្នូរ និង ភាពងាយស្រួល សូមបងប្អូនជាមេគ្រួសារ មេត្តាអញ្ជើញមកចុះឈ្មោះចំនួនកូនចៅរបស់អស់លោកដែលត្រូវការចង់បាននូវសម្ភារៈដូចខាងលើនេះ ជាមុនសិន និង ឲ្យបានឆាប់ជាទីបំផុត (អំណោយមានកំណត់) នៅទីស្នាក់ការសមាគមអរិយធម៌ខ្មែរ ដែលបើកទ្វាររៀងរាល់ថ្ងៃ លើកលែងតែថ្ងៃអាទិត្យ

CAMBODIAN CIVILIZATION ASSOCIATION
744 REDONDO AVE. , LONG BEACH , CA 90804
MONDAY.......SATURDAY ( 10:00 AM ....6:00 PM )

សមាគមអរិយធម៌ខ្មែរ សូមសម្ដែងស្វាគមន៍ចំពោះបងប្អូនញាតិមិត្រខ្មែរយើងទាំងអស់ដែលមានភាពខ្សត់ខ្សោយខ្វះខាតក្នុងការជួយឧបត្ថម្ភទំនុកបម្រុងកូនចៅឲ្យសិក្សារៀនសូត្រ ពីគ្រប់ទិសទី ។

ប្រធានសមាគម
បណ្ឌិត **ឈួន ខាំសេង**




ក្រុមហ៊ុន មយូរា បានបើកហាងលក់រាយ និងជួលកុន មយូរា ជូនភ្ញៀវដោយខ្លួនឯងផ្ទាល់ចាប់តាំងពីថ្ងៃនេះតទៅហើយ នៅទីក្រុង Long Beach ក្នុងតម្លៃថោកសមរម្យ ។

1295 E. Anaheim Street. Long Beach, CA 90813
Tel: (562) 818-0863 • (562) 761-3515

( កាច់ជ្រុង Anaheim Street & Orange Avenue ជិតភោជនីយដ្ឋាន ROSEMANEE និងទល់មុខភោជនីយដ្ឋានឋានសួគ៌ថ្មី ) ។

ហាង MAYURA VIDEO មានលក់រាយ និងជួល DVD របស់ក្រុមហ៊ុនផ្សេងៗផងដែរ ។

សូមអញ្ជើញដោយមេត្រីភាព ពីក្រុមហ៊ុនមយូរាយើងខ្ញុំ!


M.L.K MARKET
▸ ហាងខ្មែរលក់ទំនិញមានសំលៀកបំពាក់ជា
ឯកសណ្ឋានសិស្ស (Uniform), រឿងកុនថៃ,
ចិន, កូរ៉េ ផ្នែកមនោសញ្ចេតនា បាញ់ប្រហារ
កាប់ចាក់ និងក្បាច់គុណបុរាណ កំពុងចេញ
លក់ថ្មីៗមានបកប្រែជាភាសាខ្មែរ ។
▸ ហាងខ្មែរ M.L.K ក៏មានកន្លែងលក់ទឹកផងដែរ ។
▸ ហាងយើងខ្ញុំក៏មានលក់ដូរនូវសំលៀកបំពាក់
ជាច្រើនផ្នែកទៀត ទាំងសំភារៈផ្ទះបាយ,
សំភារៈដំណេក, សំភារៈបន្ទប់ទឹក និង
ឧបភោគគ្រឿងទេស, ភេសជ្ជៈជាដើម ។
ទទួលយក Card EBT
TALK
TALK
LOS ANGELES
SEOUL RAIDERS
Call Cambodia
Call Cambodia
Clear easy calling worldwide
SIN FIN
មានលក់ Phone Card
Number one in the world
សូមអញ្ជើញជា
មួយហាងថ្មីយើងខ្ញុំ
ដោយរីករាយ
ហាងយើងខ្ញុំមានលក់កុនថៃពីក្រុមហ៊ុនមយូរា
1821 M.L.K.JR Ave, Long Beach, CA 90806
Tel: (562) 591-4295



# ហោរាសាស្ត្រប្រចាំខែ មីនា ថ្ងៃទី ១-១៥



### ឆ្នាំជូត : (ពពួកទេព្តាប្រុស ធាតុទឹក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺមុននឹងហាមាត់និយាយស្តីអ្វីត្រូវចេះប្រយ័ត្នប្រយែងក្រែងមានពាក្យសម្តីភ្លាំងភ្លាត់ប៉ះសិទ្ធិអ្នកដទៃអាចបង្កជារឿងទំនាស់ឥតប្រយោជន៍ ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះមិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯង ឡើយ ៕



### ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើមានបងប្អូនញាតិមិត្តស្គាត់មកបបួលរកស៊ីចូលហ៊ុនជាមួយតោង ចេះត្រិះរិះពិចារណាឱ្យបានល្អិតល្អន់ ទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ ប្រសិនបើបានស្គាល់ចិត្តថ្លើមគ្នាហើយ គឺអាចគិតគូររឿងអាពាហ៍ពិពាហ៍បាន ៕



### ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបបញ្ហា លំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកប្រកបកិច្ចការងារអ្វីក៏ ដោយចូរមានការប្រុងប្រយ័ត្នជាប់ជានិច្ចជាពិសេសចំពោះអ្នកជំនួញជួញដូរមុននឹងប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ត្រូវចេះពិនិត្យមើលគុណភាព និងរាប់ចំនួនឱ្យបានត្រឹមត្រូវ ទើបមិនចាញ់បោកគេ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះច្រើនពាក់មុខយក្សដាក់គ្នា ៕



### ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹង ឧបសគ្គច្រើន ។ ក្នុងរយៈពេលនេះ ដោយសារតែឃើអ៊ុនកំពុងតែដាក់ស្រាប់នោះ ដូច្នេះលោកអ្នកមិនត្រូវហ៊ានប្រថុយប្រថានក្នុងការបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំ ឬក៏ប្រព្រឹត្តល្បែងស៊ីសងឡើយ ប្រយ័ត្នភ្លាត់ស្នៀតអាចវិនាសអន្តរាយទ្រព្យអស់រលីងពីខ្លួន ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះមានរឿងរកាំរកូសច្រើន ៕



### ឆ្នាំរោង : (ពពួកទេព្តាប្រុស ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លាតំនិត ប្រាជ្ញាឈ្លាសវៃ ទោះបានប្រកបកិច្ចការងារអ្វីៗ ក៏អាចដំណើរការបានស្រួលដែរ ជាពិសេសបើបានជួបពិគ្រោះពិភាក្សាការងារផ្សេងៗ គឺឆាប់និយាយត្រូវរ៉ូវ និងឆាប់ចុះសម្រុងនឹងគ្នា ។ ចំពោះគូស្នេហ៍មានការយល់ចិត្តគ្នាល្អណាស់ ៕



### ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះរាល់ចង្រៃឧបទ្រពបានលុកលុយ ចូលក្នុងកិច្ចការងាររកស៊ី ដូច្នេះទោះជាបានប្រកបការងារអ្វីក៏ដោយ តែងប្រយ័ត្នប្រយែងក្រែងមានការភ្លាំងភ្លាត់អាចបង់ខាតទ្រព្យច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមាន ភាពស្និទ្ធដូចធម្មតា ៕



### ឆ្នាំមមី : (ពពួកទេព្តាស្រី ធាតុភ្លើង)

រាសីលោកអ្នកល្អជាធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះអ្វីៗច្រើនមានការប្រែប្រួលពុំទៀងទាត់ឡើយ ដូច្នេះបើលោកអ្នកមានលក់ដី ធ្លី ផ្ទះសម្បែង ឬវត្ថុមានតម្លៃផ្សេងៗចូរធ្វើលិខិតស្នាមជាលាយល័ក្ខអក្សរដោយមានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃឱ្យបានត្រឹមត្រូវទើបទៅថ្ងៃមុខ ពុំមានបញ្ហាចោទឡើង ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះមានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



### ឆ្នាំមមែ : (ពពួកទេព្តាស្រី ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿង រកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងជម្លោះកើតឡើង ចូរចេះ អត់ធ្មត់ និងរំងាប់ចិត្តឱ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់និងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ចំពោះគូស្វាមីភរិយាក្នុងរយៈពេលនេះមានគេអុជអាលឱ្យបែកបាក់ ដូច្នេះតោងប្រយ័ត្នទើបបានសុខ ៕



### ឆ្នាំវក : (ពពួកទេព្តាប្រុស ធាតុដែក )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងរឿង រកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកនឹងបានជួបរឿងឈ្លោះវិវាទមួយហើយមួយទៀតឥតឈប់ឈរ ។ ដូច្នេះចូរចេះរម្ងាប់ចិត្តឱ្យបានត្រជាក់ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ចំពោះគូ ស្នេហ៍ក្នុងរយៈពេលនេះមិនសូវចុះសម្រុងនិងគ្នាទេ ៕



### ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ គឺរមែងតែងតែបានទទួលផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ក្នុងរយៈពេលនេះបុរសត្រូវប្រយ័ត្ន ចំពោះមនុស្សស្រីដែលមានសម្តីផ្អែមត្រជាក់អាចរលាយទ្រព្យឆាប់ ។ ចំពោះគូស្នេហ៍ប្រកបតែសេចក្តីសុខក្សេមក្សាន្ត ៕



### ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏ត្រូវបានបងប្អូនញាតិមិត្តជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ដូច្នេះចូរញាប់ដៃញាប់ជើងបន្តិច ព្រោះការងារជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះស្គាល់តែភាពផ្អែមល្ហែមដូចទឹកឃ្មុំ ៕



### ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គបានសាបរលាបបាត់ស្រមោលអស់រលីង ដូច្នេះលោកអ្នកអាចប្រកបកិច្ចការងារបានពេញដៃពេញជើង តែនៅពេលជាប់មមាញឹកខ្លាំងចូរប្រយ័ត្នប្រយែងក្រែងមានការភ្លាំងភ្លាត់នាំឱ្យខាតបង់លាភសក្ការៈ ។ ចំពោះគូស្នេហ៍ពេលនេះប្រកបតែសេចក្តីសុខក្សេមក្សាន្ត ៕

## ទីតាំងដង្ហើមចុងក្រោយ...

រូបចម្លាក់, ទីតាំងផលិតមីន និងតំបន់វិទ្យុទាក់ទង ។

-តំបន់ទី៣ ផ្ទះតាម៉ុក, ផ្ទះសុន សេន, ផ្ទះនួន ជា, ចំការស្វាយ តាម៉ុក, ផ្ទះសំណាក់, សាលាប្រជុំនយោបាយ, ទឹកធ្លាក់ និងផ្ទះកណ្តាលលើ ។

-តំបន់ទី៤ ផ្ទះប៉ុល ពត ទី១, ផ្ទះខៀវ សំផន, ផ្ទះប៉ុល ពត ទី២, កន្លែងវិទ្យុទាក់ទង, ការិយាល័យខៀវ សំផន, រោងយាមទី១ និងរោងយាមទី២ ។

កេរដំណែលទាំងអស់នេះ ត្រូវបានគេអភិរក្សទុកឱ្យមនុស្សជំនាន់ក្រោយបានឃើញ បើតាមការអះអាងរបស់មន្ត្រីជំនាញបញ្ជាក់ថា ក្នុងមួយថ្ងៃមានភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទៅទស្សនាប្រ-មាណពី៥០ទៅ១០០នាក់ ដែលភ្ញៀវខ្លះចូលតាមច្រកជាំព្រំដែនកម្ពុជា-ថៃ ។ ខ្លះទៀតមកពីខេត្ត សៀមរាប បន្ទាប់ពីទស្សនាប្រាង្គប្រាសាទអង្គរវត្តរួចមក ។

ចាប់តាំងពីផ្លូវថ្នល់រៀបចំជួសជុលឱ្យស្អាតលែងមានជង្ហុករួច មកភ្ញៀវទេសចរបាននាំគ្នាទៅទស្សនាកាន់តែច្រើនជាងមុនជាលំដាប់ ហើយម្នាក់ៗលាន់មាត់កោតសរសើរពីសម្រស់ធម្មជាតិជួរភ្នំដងរែក និងកេរដំណែលរបស់ពួកខ្មែរក្រហមដែលបានបន្សល់ទុក ។

ទន្ទឹមនឹងការចេញចូលរបស់អ្នកទេសចរ គេសង្កេតឃើញមានប្រជាពលរដ្ឋប្លែកៗមកតាំងលំនៅដ្ឋាន ប្រកបរបរសិប្បកម្មចម្លាក់ ឈើកែច្នៃគ្រឿងសង្ហារឹម សេវាកម្មផ្ទះសំណាក់អាហារដ្ឋាន ។ ជាពិសេស ធ្វើឱ្យដីនៅតំបន់នោះកាន់តែមានតំលៃខ្ពស់ បង្កលក្ខណៈងាយស្រួលដល់អ្នកស្រុកដែលរស់នៅទីនោះ កាន់តែមានក្តីសង្ឃឹមមួយកំរិតទៀត ។

កេរដំណែលទាំងនេះ ត្រូវបានប្រជាពលរដ្ឋខ្មែរ ភ្ញៀវទេសចរ ចំរុះជាតិសាសន៍មួយចំនួន ចំណាយពេលវេលាទៅទស្សនា និងស្វែងយល់ឱ្យកាន់តែស៊ីជំរៅ ក៏ដូចជាចង់ជំរុះទុក្ខសោកដែលមានពីមុនឱ្យអស់នៅទីនោះតែម្តង ។

ការចេញចូលរបស់អ្នកទេសចរនេះ បានជួយឱ្យអ្នកស្រុកមានការងារធ្វើលើកស្ទួយជីវភាពរស់នៅមានភាពកក់ក្តៅ និងធ្វើឱ្យសេវាកម្មទេសចរណ៍កាន់តែប្រសើរឡើង ។ ជាពិសេសដីនៅតំបន់នោះកាន់តែមានហាងឆេង មិនចាញ់ខេត្ត-ក្រុងមួយចំនួនទេ ៕

# SPP VIDEO & GIFT SHOP







## ហាងសិលាផ្កាយព្រឹកវីដេអូ និងលក់វត្ថុអនុស្សាវរីយ៍

-ក្រុមហ៊ុនសិលាផ្កាយព្រឹក (SILA PKAY PREK VIDEO ) បានបើកហាងលក់ដុំ,រាយ,និងជួលកុន ជូនដល់អតិថិជនពីក្រុមហ៊ុនយើងខ្ញុំ , ក្រុមហ៊ុនថៃសេង និងក្រុមហ៊ុន(SILA PKAY PREK VIDEO ) ផងដែរ ។

-ហាងយើងខ្ញុំក៏មានលក់នូវសំលៀកបំពាក់ ស្បែកជើង វត្ថុក្មេងលេង កាបូបរៀន ខោអាវកូនសិស្ស និងវត្ថុអនុស្សាវរីយ៍ផ្សេងៗទៀត ។

សូមអញ្ជើញដោយមេត្រីភាពពីហាងសិលាផ្កាយព្រឹកយើងខ្ញុំ ចាប់បើកពីថ្ងៃនេះតទៅហើយ ។











1001E Pacific Coast Hwy, Ste 125
Long Beach, CA 90806 , Cell: (562) 682 2544

# ដំណើរមកកាន់ការវះកាត់បេះដូង


កុមារី ដារិក ដើរចេញពីព្រលានយន្តហោះ L.A.X


កុមារី ដារិក ថតជាមួយចាងហ្វាងកាសែតខ្មែរប៉ុស្តិ៍

នាងបានអង្រួនទាមទារជីវិតទៅរកសេចក្តី ស្លាប់ក្នុងថ្ងៃណាមួយជាមិនខាននោះ ខណៈដែលក្រុមវេជ្ជបណ្ឌិតគ្មានលទ្ធភាពព្យាបាលនៅក្នុងមាតុភូមិរបស់នាង ។

ការគិតរវើរវាយជាអ្នកជំងឺបានផ្ទុយស្រឡះ ដោយជំនួសនូវវាចាថ្មី ពេលដែលនាងជាន់ជើងលើទឹកដីអាមេរិក កុមារីរូបនេះ បានថ្លែងប្រាប់អ្នកកាសែតខ្មែរប៉ុស្តិ៍យើងដោយសម្លេងខ្សាវៗ ហាក់គ្មានកំលាំងកំហែងថា "ខ្ញុំមិនស្លាប់ទេ... អាមេរិកផ្តល់ក្តីសង្ឃឹមឱ្យខ្ញុំហើយ... បេះដូងដ៏ប្រហោងធំ ដែលញាំញីជីវិតខ្ញុំរៀងរាល់ថ្ងៃ ដោយភាពចុកចាប់ និងឈឺផ្សា ពិតជាជាសះស្បើយនឹងក្លាយខ្លួនដូចកុមារដ៏ទៃដែលគ្មានជំងឺ ពួកគេរត់លេងសប្បាយ និងទៅសាលារៀនដោយសុខភាពល្អមាំមួន ។ ផ្ទុយពីខ្ញុំដែលរៀងរាល់ខែទៅសាលារៀនតែ៤ទៅ៥ថ្ងៃប៉ុណ្ណោះ ព្រោះតែសុខភាពលំបាក" ។

កុមារី តេង ដារិក ដែលយើងមើលឃើញតាមច្រកទ្វារដើរចេញពីព្រលានយន្តហោះ កាលពីថ្ងៃសុក្រចុងសប្តាហ៍កន្លងមកនេះ នាងបានបង្ហាញទឹកមុខញញឹម តោងរទេះអូសអីវ៉ាន់ជាមួយបុរសចំណាស់ម្នាក់អាយុជាង៥០ឆ្នាំ ត្រូវបានគេស្គាល់ថា Peter Chhun ជាផលិតករឱ្យទូរទស្សន៍ដ៏ល្បីមួយ របស់អាមេរិក ឈ្មោះ NBC និងជាប្រធានអង្គការ បេះដូងគ្មានព្រំដែនផងនោះ ។

បុរសរូបនេះ គឺជាអ្នកផ្តួចផ្តើមជួយយ៉ាងពេញទំហឹង ទាំងកម្លាំងកាយចិត្ត ថវិកា ក្នុងការស្វះស្វែង ធានារូបនាង ដារិក មកព្យាបាលធ្វើការវះកាត់ជំងឺបេះដូងរបស់នាងនៅក្នុងសហរដ្ឋអាមេរិកនេះ ។


កុមារី ដារិក និង Peter Chhun

ម្តាយកុមារី និងក្រុមបេសកកម្មអ្នកកាសែត Press Telegram ដើរពីក្រោយកុមារី ដារិក ។ ដារិក បានបង្ហាញភាពស្និតស្នាលជាមួយបុរស Peter Chhun ដែលអ្នកមិនដឹងរឿងគិតថា ជាឪពុកហើយ ។ ប៉ុន្តែធាតុពិតការស្និតស្នាលដោយក្តីស្រឡាញ់ទៅលើបុរសដូចជាកូន និងឪពុក នោះ កុមារី ដារិក និយាយប្រាប់ថា "គ្មានគុណឯណាធំជាងគុណ ដែលគាត់បានកំពុងជួយស្រោចស្រង់ជីវិតឱ្យរួចពីការស្លាប់របស់ខ្ញុំនោះទេ... គាត់ជាឪពុកទីពីរសំរាប់ជីវិតខ្ញុំ... ។ ដោយក្នុងសំដីនិយាយបានក្បោះក្បាយ នាងបន្ថរថា គ្មានជីវិតមួយនាទីណាបំភ្លេចរូបគាត់បានទេ" ។


កុមារីអាមេរិកនិយាយថា "អ្នកត្រូវតែរស់ជីវិតឡើងវិញ" កុំអស់សង្ឃឹមណា...!

ទន្ទឹមនោះ កុមារី ដារិក និយាយបន្តថា នាងក៏មិនភ្លេចបុរសពីរនាក់ ដែលទៅពីអាមេរិកបានឃើញរូបនាង ហើយក៏ចាប់អារម្មណ៍ និងអាណិតចំពោះនាង ដែលបុរសពីរនាក់នេះឈ្មោះ ចន្ថា និង ច័ន្ទលី បានធ្វើការទំនាក់ទំនងជួយដល់រូបនាងក្នុងការព្យាបាលជំងឺបេះដូងផងដែរ ។

ម្តាយនាងឈ្មោះ ឈុន ស៊ីន អាយុ៣៨ឆ្នាំ បានរំភើបចិត្តបង្ហាញនូវស្នាមញញឹម ដែលស្ទើរតែមិនធ្លាប់មានក្រៅពីការបង្ហូរទឹកភ្នែកសម្រក់ចេញមក ព្រោះតែក្តីអាណិតចំពោះកូន ដោយថ្លែងថា វាសនាគាត់ក៏ដូចជាវាសនាកូនស្រីដ៏អភ័ព្វពីជីវិតដែលរង់ចាំតែសេចក្តីស្លាប់នៅចំពោះមុខនោះ បានរុញច្រានឱ្យរូបគាត់សង្ឃឹមមកវិញ នូវជីវិតកូនស្រីគាត់ ពិតជាមិនស្លាប់នោះទេ។

ដោយពឹងលើក្រុមគ្រូពេទ្យអាមេរិក ជាមួយបច្ចេកវិជ្ជាទំនើបៗ ក្នុងការវះកាត់ និងព្យាបាលកូនស្រីគាត់ ។ ឈុន ស៊ីន ដែលជាអ្នកម្តាយមេម៉ាយរបស់កុមារី ដារិក បន្តថា "ខ្ញុំស្ទើរតែពុំជឿខ្លួនឯងទាល់តែសោះពីវាសនាល្អដែលកើតមាននៅថ្ងៃនេះ..." ។

ខ្ញុំធ្លាប់មើលរឿងកុន ឬស្ថានភាពជាក់ស្តែងក្នុងសង្គមខ្មែរក្រក្រី អ្នកមានទ្រព្យសម្បត្តិ ហើយមានជម្ងឺឈឺស្កាត់ធ្ងន់ធ្ងរ ត្រូវធ្វើដំណើរចេញក្រៅប្រទេសដើម្បីព្យាបាល ធ្វើឱ្យជីវិតរស់រានបន្តទៀត ។ ចុះបើខ្ញុំក្រីក្រលំបាកតោកយ៉ាកយ៉ាងដូច្នេះ ? ដែលក្នុងមួយថ្ងៃៗ ធ្វើការជាកម្មករសំណង់បានត្រឹមតែ១.៥០ដុល្លារប៉ុណ្ណោះ តើមានសមត្ថភាពអ្វីក្នុងការព្យាបាលឱ្យកូនបានជាសះស្បើយនោះ ។ ការពិតទៅក្នុងទិដ្ឋភាពនៃជីវភាពជាក់ស្តែង ខ្ញុំបានប្រាប់គេថា នេះជាគុណបុណ្យដ៏ល្អសំរាប់គ្រួសារខ្ញុំ ដែលបានជួបប្រទះនូវមនុស្សល្អៗ កំពុងជួយកូនខ្ញុំ... ខណៈដែលខ្ញុំ និងកូនអង្គុយបង្ហូរទឹកភ្នែកទល់មុខគ្នាបង្ហើបត្រឹមតែពាក្យថា "ម៉ែមិនដឹងជួយកូនយ៉ាងម្តេចទេ ។ បើយើងក្រម្លឹងៗ... ចំណែកកូនវិញបានត្រឹមតែស្រែកថ្ងូរ ដោយក្តីឈឺចាប់ ដង្ហើមដង្ហក់ប្រាប់ម្តាយថា កូនមិនអាចរស់រានមានជីវិតយូរទេ... ថ្ងៃណាមួយកូនពិតជាស្លាប់ចោលម៉ែហើយ" ។





កុមារី ដារិក ជាមួយសប្បុរសជនក្នុងភោជនីយដ្ឋានសុគី

កុមារី តេង ដារិក បានឆ្លងកាត់ការព្យាបាលជម្ងឺបេះដូងចំនួន៥ដង នៅក្នុងមន្ទីរពេទ្យអង្គរ ខេត្តសៀមរាប និងមន្ទីរពេទ្យកាល់ម៉ែត ក្រុងភ្នំពេញ ។ ប៉ុន្តែការទទួលព្យាបាលនោះ មិនមានលទ្ធភាពឱ្យនាងជាសះស្បើយបានទេ ព្រោះបញ្ហាបច្ចេកទេស និងសំភារៈមិនសមល្មមនឹងធ្វើការវះកាត់បាន ក្រៅតែពីបញ្ជូនចេញទៅព្យាបាលក្រៅប្រទេស ទើបកុមារីរូបនេះ នឹងមានជីវិតរស់ ហើយសុខភាពដូចមនុស្សដ៏ទៃ ដែលមិនមានបញ្ហាផ្នែកបេះដូងនោះ ។

**●នៅគេហដ្ឋានអ្នកស្គាល់ កាលនៅស្រុកខ្មែរ នាក្រុង Long Beach:**

អ្នកកាសែតយើងបានទៅដល់ផ្ទះរបស់អ៊ំស្រីម្នាក់ឈ្មោះ ទឹម កែ អាយុ៦៣ឆ្នាំ អ៊ំស្រីរូបនោះ បានប្រាប់យើងថា ភាពរីករាយ និងក្តីរំភើបជាមួយបំណងរបស់គាត់បានសម្រេចហើយ "ជារៀងរាល់យប់ខ្ញុំតែងតែ អុជធូបបន់ស្រន់ព្រះសំពះទេវតា សូមមេត្តាឱ្យកុមារី ដារិក មានវាសនា និងឱកាសបានឆ្លងទ្វីបមកព្យាបាលជម្ងឺបេះដូងនៅអាមេរិក ព្រោះគ្រូពេទ្យពូកែសក្តិសិទ្ធិជាមួយបច្ចេកវិជ្ជាទំនើប... ខ្ញុំស្រក់ទឹកភ្នែក ដោយរំភើបមិនស្មានដល់ថា មានថ្ងៃនេះ ដែលវាសនានាងនឹងផុតពីសេចក្តីស្លាប់... ទេវតាពិតជាមានភ្នែក...ព្រះពុទ្ធពិតជាមានក្តីសណ្តោស ( តនៅទំព័រទី១២ )


អ៊ំស្រីកំពុងចិតក្រូចឱ្យកុមារី ដារិក ញាំ


កុមារី ដារិក កំពុងតែផាត់ពណ៌រូបផ្កាជាមួយក្មេងអាមេរិក


ភោជនីយដ្ឋានឋានសួគ៌ថ្មី
New Paradise Restaurant
1350 EAST ANAHEIM STEET, LONG BEACH ,CA 90813
TEL: (562) 218-0066
NEW PARADISE RESTAURANT
NEW PARADISE RESTAURANT
LIVE SEAFOOD
ជួបជាមួយអ្នកចំរៀងល្បីៗពិរោះៗ
សូមអញ្ជើញមកពិសារម្ហូបពិសេសសំរាប់គ្រួសារ ពេលបាយថ្ងៃត្រង់ និងពេលល្ងាច ចាប់ពីថ្ងៃ ច័ន្ទ ដល់ ថ្ងៃ ព្រហស្បត្តិ៍
A : $ 19.95
សម្លម្ជូរត្រី ( Hot & Sour Fish Soup )
សាច់គោអាំង ( Beef Stick )
ប្រហុកខ្ទិះ ( Ground Pork Curry & Fresh Vegetable )
B : $ 29.95
សម្លម្ជូរគ្រឿងឆ្អឹងជំនីជ្រូក ( Spare Rib Green Hot & Sour Soup )
ញាំមាន់តាំងហ៊ុន ( Chicken Salad )
ត្រីប្រម៉ាចំហុយ ( Steam Pork Cake & Fresh Vegetable)
សាច់គោអាំង ( Beef Stick)
C : $ 38.95
សម្លម្ជូរត្រី ( Hot & Sour Fish Soup )
សាច់គោអាំង ( Beef Stick )
អាម៉ុក (Steam Fish Cake with Coconut Milk)
សាច់មាន់ឆាប៊ឺរ (Sauteed Chicken with Butter Sauce )
ញាំមាន់តាំងហ៊ុន
D : $ 59.95
សម្លម្ជូរបង្កង និង ត្រី ( Hot & Sour Langostinos & Fish Soup )
សាច់គោអាំង ( Beef Stick)
ក្ដាមឆាប៊ឺរ ( Crab with Special Sauce)
លាសឆាជីនាងវងម្ទេស ( Clam w/Sweet Basil & Jalopenos )
ត្រីខ្នៅចំហុយ ( Tilapia Steamed with Ginger Sauce)
មាន់ឆាគ្រឿង ( Sauteed Chicken with Green Herb & Spices )
E : $ 78.95
សម្លម្ជូរបង្កង និងត្រី ( Hot & Sour Langostinos & Fish Soup )
ភ្លាជើងទា (Bonelees Duck Feet Salad )
សាច់គោអាំង ( Beef Stick )
លាសឆាជីនាងវងម្ទេស ( Clam w/Sweet Basil & Jalopenos )
ត្រីក្រម៉ាឆៀនជូរអែម ( Sauteed Rock Cod w/Pineapple & Bell Pepper)
សាច់គោឡុកឡាក់ ( Beef Cub Salad )
F : $ 119.95
ញាំមាន់តាំងហ៊ុន ( Chicken Salad )
សម្លម្ជូរបង្កង និង ត្រី ( Hot & Sour Langostinos & Fish Soup )
ត្រីក្រម៉ាចំហុយ ( Steam pork Cake & Fesh Vegetable )
ឆាក្ដាម ( Sauteed Crab )
សាច់គោឡុកឡាក់ ( Beef Cub Salad )
ឆាបង្កង ( Lobster )
BEER , WINE , COCKTAIL
ភោជនីយដ្ឋានយើងខ្ញុំមានទីកន្លែងស្អាត មានអនាម័យល្អ មានផាសុខភាព សេវាកម្មរហ័សទាន់ចិត្ត មានមុខម្ហូបឈ្ងុយឆ្ងាញ់
ជួបជាមួយចុងភៅចំណាន១ ហើយមានស្រាល្បីៗមកពីជុំវិញពិភពលោក កំដរដោយតារាចំរៀងល្បីៗមានសំនៀងពិរោះ


First AMERICAN TEAM REALTY TM
ជំនាញឯកទេសជាទីទុកចិត្តនិងស្មោះត្រង់ចំពោះលោកអ្នក
▶ ពន្យល់ណែនាំពីកិច្ចការទូទៅដែលទាក់ទងនឹងការលក់, ទិញផ្ទះ, ហាងជំនួញ និងដីធ្លី ។
▶ បង្ហាញលោក-អ្នកឱ្យយល់នូវពិធីខ្ចីប្រាក់សាងសង់ ឬជួសជុលផ្ទះជាដើម ។
▶ បើលោក-អ្នកមានចម្ងល់ជុំវិញការលក់ផ្ទះ និងទិញផ្ទះ សូមអញ្ជើញទាក់ទង ខ្ញុំបាទគ្រប់ពេលវេលា តាមអាស័យដ្ឋាន ខាងក្រោម :
Mr. Monorom Neth
Licensed Realtor
2501 Cherry Ave.,#100 • Signal Hill, CA 90755
Office (562) 427-7765 Ext.333
Cell (562) 483-7333 Fax (562) 427-0767


ALL TRANSMISSION & CLUTCH
មាន ទទួលធ្វើ
complete Auto RePair
- Engine
- Tune Up
- Brakes
-ជួសជុលគ្រប់ប្រភេទប្រអប់លេខ រថយន្តលោកអ្នក ដែលបើកមិនទៅ មុខមិនថយក្រោយ ឬនៅពេលលោកអ្នក បញ្ចូលលេខ.ឡានរបស់លោកអ្នកត្រូវកញ្ឆក់ខ្លាំង ឬឮ សម្លេងរោទិ៍ជា
Rebuild
Automatic Transmission (Front Wheel Drive & Over Drive ) MANUAL Transmission
TRANSMISSIONS & CLUTCH 494-6968
AUTOMATIC - STANDARD - CLUTCH FOREIGN DOMESTIC
TRANSMISSION PARTS
MOTOR TUNE-UP
(562)494-6968
2800E .PCH Hwy . Long Beach . CA 90804


HILLSIDE CHIROPRACTIC & REHAB CENTER
AUTO COLLISION . WORK INJURY . SPORT INJURY
មន្ទីរពេទ្យចាប់សរសៃ
Dr. Rene Uong D.C
Receptionist
Alfredo Munoz Jr. LMT Massage Therapy
Dr. Hanh Bullee, D.C.
សូមអញ្ជើញ ដោយមេត្រីភាព
ទទួលព្យាបាលជំងឺដូចជារោគៈ
.ឈឺក្បាល . វិលមុខ. ឈឺក . ឈឺចង្កេះ. ឈឺស្មា .ដៃជើង . ចុករោយសាច់ដុំ . ស្ពឹកដៃជើង .
អស់កម្លាំងខ្សោយ . ធ្វើសរសៃ . គ្រោះថ្នាក់ចរាចរ ។ល។ ខ្ញុំ Dr. Rene E.Uong និយាយភាសាខ្មែរ
2760E. SPRING STREET, SUITE 150 , LONG BEACH, CA 90806
PHONE : (562) 424-1200, FAX : (562) 424-1214
FULL SERVICE TREATMENT
▸Personal Injury /Sports Injury
▸Wellness Care ▸Work Related Injuries
▸Chronic Care ▸Chiropratic Care
▸Chronic Pain Syndromes
▸Physical Therapy
▸Customize Rehabilitation ▸Massage Therapy
▸Program ▸Complete physical Exams
▸Posture/Body Mechanics ▸Athletes-DMV / DOT
▸Per / Post Operation Care ▸Nutritional Analysis
▸Neck and Back School
▸Auto Accident Care Specialist
▸Therapy Products
CHIROPRACTIC IS PROVEN EFFECTIVE IN THE TREATMENT OF MANY COMMON AILMENTS INCLUDING...
▸Headaches ▸Neck Pain ▸Back Pain
▸Shoulder and Arm Pain ▸Leg Pain ( Sciatica )
▸Carpal Tunnel Syndrome
▸Numbness & Tingling
▸And Many Other Common Health Issues
▸Joint Stiffness ▸Muscle Spasms ▸Disc Herniation
▸Scoliosis ▸Low Energy ▸Stress


សូមស្វាគមន៍!
ភោជនីយដ្ឋាន សុភី
Sophy´s CAMBODIAN & THAI CUISINE
ភោជនីយដ្ឋានជាទីពេញចិត្តរបស់លោក-អ្នក ជាមួយម្ហូបខ្មែរ
ថៃ ចំរុះគ្រប់មុខដែលមានរសជាតិឈ្ងុយឆ្ងាញ់គួរឱ្យពិសារ ។
3720E. Anaheim St., 102 . Long Beach, CA 90804
Tel: (562) 494-1763 Delivery FREE with Purchase of $15.00 or More